«នេះគឺជាសៀវភៅដ៏មានប្រយោជន៍មួយក្បាល ដែលនិយាយអំពីបញ្ហាដ៏សំខាន់ពិតប្រាកដ។ សៀវភៅនេះសង្ខេបខ្លី ងាយស្រួលអាន យល់ និងស្មោះត្រង់ ព្រមទាំងមានគំរូដ៏មានប្រយោជន៍ជាច្រើនពីជីវិតសព្វថ្ងៃ និងប្រវត្តិសាស្ត្រនៃក្រុមជំនុំ។ មានអ្វីច្រើននៅក្នុងកូនសៀវភៅដ៏តូចនេះ៖ ជាសៀវភៅដែលខ្ញុំពិតជាចង់ណែនាំដល់លោកអ្នកណាស់!»។

**Alasdair Paine**, Vicar, St. Andrew the Great, Cambridge, UK; speaker and author

«ជាមួយនឹងសមត្ថភាពពិសេសរបស់គាត់សម្រាប់ភាពច្បាស់លាស់ និងចំៗ លោកគ្រូ ធីម ឆេស្ទើរ (Tim Chester) បានផ្តល់នូវការពន្យល់ប្រកបដោយគតិបណ្ឌិត និងជាក់ស្តែងអំពីសិទ្ធិអំណាចកំពូលនៃព្រះគម្ពីរ។ គ្រីស្ទបរិស័ទគ្រប់គ្នា មិនថាថ្មី ឬចាស់ គួរតែអានសៀវភៅនេះ»។

**Martin Salter**, Lead Pastor of Bedford Community Church, UK; conference speaker and author

«ជាមួយនឹងសមត្ថភាពពិសេសរបស់គាត់សម្រាប់ភាពច្បាស់លាស់ និងចំៗ លោកគ្រូ ធីម ឆេស្ទើរ (Tim

Scripture is supreme INDD interior - Khmer 1.9.indd 1 14/8/26 3:55 in the afternoon

Chester) បានផ្ដល់នូវការពន្យល់ប្រកបដោយគតិបណ្ឌិត និងជាក់ស្ដែងអំពីសិទ្ធិអំណាចកំពូលនៃព្រះគម្ពីរ។ គ្រីស្ទបរិស័ទគ្រប់គ្នា មិនថាថ្មី ឬចាស់ គួរតែអានសៀវភៅនេះ»។

**J. Stephen Yuille**, Professor of Spiritual Formation and Pastoral Theology, Southwestern Baptist Theological Seminary, Fort Worth, TX

Scripture is supreme INDD interior - Khmer 1.9.indd 2 14/8/26 3:55 in the afternoon

ផ្លូវពិត
plovpit.com

# ព្រះគម្ពីរមានសិទ្ធិ
# អំណាចកំពូល

លោកគ្រូ ធីម ឆេស្ទើរ

Scripture is supreme INDD interior - Khmer 1.9.indd 3 14/8/26 3:55 in the afternoon

*Scripture Is Supreme*
*ព្រះគម្ពីរមានសិទ្ធិអំណាចកំពូល*
© 2023 by Tim Chester
រក្សាសិទ្ធិ ©2023 by Tim Chester

www.UnionPublishing.org
Bridgend, Wales, United Kingdom

This edition in Khmer copyright ©2026 by ACTION Cambodia Organization

All rights reserved.
រក្សាសិទ្ធិគ្រប់បែបយ៉ាង ©២០២៦
ផលិតដោយ៖ អង្គការសកម្មភាពកម្ពុជា resources@actioncambodia.org
ប្រអប់សំបុត្រលេខ ១១៧៨ រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
បកប្រែដោយ៖ លោក ជឿន ជីវិចន្ទា
ជំនួយការបកប្រែ៖ លោក ឈាង បូរ៉ា
ពិនិត្យផ្ទៀងផ្ទាត់ដោយ៖ លោក ឯក សត្យា, លោក ទេព រ៉ូ, លោក ខែម បូឡុង,  លោក ហុង សម្ភស, លោក ឡង់ គីមឡុង, លោកស្រី ឡូញ ស្រីរ័ត្ន, កញ្ញា រិន ខារីសា និងលោកស្រី ថាវ ប៊ុនរី
អ្នករចនាអត្ថបទភាសាខ្មែរ៖ លោក រ៉េល ណាថាន និងលោក  ខែម បូឡុង

យើងខ្ញុំបានរក្សាអក្ខរាវិរុទ្ធនៃសម្រង់ខគម្ពីរដែលមាននៅក្នុងព្រះគម្ពីរបកប្រែចាស់ រក្សាសិទ្ធិ©ឆ្នាំ១៩៥៤ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរសញ្ញាថ្មី កែសម្រួល រក្សាសិទ្ធិ ©ឆ្នាំ២០១៤, ២០១៦ (គកស) ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរដ៏វិសុទ្ធជាភាសាខ្មែរបច្ចុប្បន្ន រក្សាសិទ្ធិ ©ឆ្នាំ២០០៥ (គខប) ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ រក្សាសិទ្ធិ ©ឆ្នាំ២០១៤ (គគខ) ដោយព័ន្ធកិច្ចព្រះបន្ទូលនៃជីវិត, ក៏ដូចជាអសាធារណនាមមួយចំនួន ប៉ុន្តែសំណេរនៅក្នុងអត្ថបទទាំងមូលយើងខ្ញុំបានខិតខំព្យាយាមគោរពតាមអក្ខរាវិរុទ្ធនៃវចនានុក្រមខ្មែររបស់សម្តេចសង្ឃរាជ ជួន ណាត។

*For ordering information please visit: plovpitshop.com*
ប្រសិនបើលោកអ្នកចង់ជាវសៀវភៅនេះ សូមចូលទៅកាន់គេហទំព័រ៖
*plovpitshop.com*

បោះពុម្ពលើកទី១ ចំនួន ៣.០០០ ក្បាល ២០២៦ នៃគ.ស.
ISBN : 978-9924-566-33-5

Scripture is supreme INDD interior - Khmer 1.9.indd 4 14/8/26 3:55 in the afternoon

# មាតិកា


បុព្វកថាអំពីស៊េរីសំខាន់ៗ ៧

១ តើសម្លេងរបស់អ្នកណាសំខាន់ជាងគេ? ១១

២ ហេតុអ្វីបានជាព្រះគម្ពីរមានសិទ្ធិអំណាចកំពូល? ៣១

៣ តើព្រះគម្ពីរមានសិទ្ធិអំណាចកំពូលនៅពេលណា? ៥៥

៤ ហេតុអ្វីបានជាសិទ្ធិអំណាចកំពូលនៃព្រះគម្ពីរសំខាន់? ៧១

៥ តើសិទ្ធិអំណាចកំពូលនៃព្រះគម្ពីរដំណើរការយ៉ាងដូចម្តេច? ១០៣

លិបិក្រមតាមព្រះគម្ពីរ ១២១



Scripture is supreme INDD interior - Khmer 1.9.indd 5 14/8/26 3:55 in the afternoon

Scripture is supreme INDD interior - Khmer 1.9.indd 6 14/8/26 3:55 in the afternoon

# បុព្វកថាអំពីស៊េរីសំខាន់ៗ

ស៊េរីនេះ ណែនាំពីសេចក្ដីពិតសំខាន់ៗដែលមិនអាចចរចាបាននៃដំណឹងល្អ។

ហើយតើសេចក្ដីពិតទាំងនោះមានអ្វីខ្លះ? នេះជារបៀបដែលសាវ័ក ប៉ុល និយាយអំពីដំណឹងល្អនៅក្នុងប្រយោគដំបូងនៃសំបុត្ររបស់គាត់ទៅកាន់ក្រុមជំនុំនៅទីក្រុង រ៉ូម៖

> «សំបុត្រប៉ុលខ្ញុំ ជាបាវបម្រើរបស់ព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់បានហៅមកធ្វើជាសាវ័ក ទាំងញែកចេញទុកសំរាប់ដំណឹងល្អនៃព្រះ (ជាដំណឹងល្អដែលទ្រង់បានសន្យាពីដើម ដោយសារពួកហោរាទ្រង់ ទុកក្នុងគម្ពីរបរិសុទ្ធ គឺពីព្រះរាជបុត្រានៃព្រះ ដែលខាងឯសាច់ឈាម ទ្រង់បានចាប់កំណើតក្នុងព្រះវង្សាហ្លួងដាវីឌ តែខាងឯព្រះវិញ្ញាណនៃសេចក្ដីបរិសុទ្ធ នោះបានសំដែងមកច្បាស់ថា ទ្រង់ជាព្រះរាជបុត្រារបស់ព្រះពិត ទាំងមានព្រះចេស្ដាផង ដោយទ្រង់បានរស់



Scripture is supreme INDD interior - Khmer 1.9.indd 7 14/8/26 3:55 in the afternoon

ពីស្លាប់ឡើងវិញ គឺជាព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់
នៃយើងរាល់គ្នា» (រ៉ូម ១:១-៤ ពគប)។

សម្រាប់សាវ័ក ប៉ុល ដំណឹងល្អគឺជាសារដែល ផ្ដោតលើព្រះជាម្ចាស់៖ វាគឺជា «ដំណឹងល្អរបស់ព្រះជាម្ចាស់»។ វាគឺជាសារអំពីព្រះត្រៃឯក៖ ព្រះវរបិតា បើកសម្ដែងពីព្រះរាជបុត្រារបស់ទ្រង់ដោយអំណាចនៃព្រះវិញ្ញាណ។ វាគឺជាសារនៃព្រះគម្ពីរ៖ ត្រូវបានប្រកាស «នៅក្នុងព្រះគម្ពីរបរិសុទ្ធ»។ វាទាក់ទងនឹងព្រះគ្រីស្ទ ដែលជាព្រះរាជបុត្រានៃព្រះ និងកិច្ចការនៃការប្រោសលោះរបស់ទ្រង់។ ហើយវាជាសារដ៏មានប្រសិទ្ធភាពក្នុងព្រះចេស្ដានៃព្រះវិញ្ញាណក្នុងការផ្ដល់កំណើតជាថ្មី។ ម្យ៉ាងវិញទៀត ដំណឹងល្អរបស់គ្រីស្ទបរិស័ទគឺជាដំណឹងដ៏ល្អអំពីព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណ និងកិច្ចការរបស់ព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណ នៅក្នុងការបើកសម្ដែង ការប្រោសលោះ និងការកើតជាថ្មី។[១]

---

១ លោកគ្រូ Michael Reeves បានប្រើប្រាស់ និងពន្យល់ជាលើកដំបូងអំពីតារាងមួយនេះនៅក្នុងសៀវភៅ Gospel People: A Call for Evangelical Integrity (Wheaton, IL: Crossway, ឆ្នាំ២០២២), ទំព័រ២០ និង ១១៩។



Scripture is supreme INDD interior - Khmer 1.9.indd 8 14/8/26 3:55 in the afternoon




សេចក្ដីពិតទាំងនេះសុទ្ធតែមានទំនាក់ទំនងគ្នាទៅវិញទៅមក។ សេចក្ដីពិតទាំងនេះរួមគ្នាបង្កើតបានជាដំណឹងល្អដ៏ស្រស់ស្អាតមួយរបស់យើង ដែលដំណឹងល្អនេះគឺតាមព្រះគម្ពីរ មានមូលដ្ឋានលើព្រះត្រៃឯក ផ្ដោតលើព្រះគ្រីស្ទ និងផ្ដល់ជីវិតថ្មីដោយព្រះវិញ្ញាណ។ ស៊េរីនេះនឹងណែនាំដំណឹងល្អនេះដល់អ្នកអាន ព្រមទាំងផ្ដល់ចំណេះដឹងពីដំណឹងល្អនេះឡើងវិញដល់ពួកគេ។ សៀវភៅខ្លីៗចំនួនដប់ក្បាលនេះនិយាយផ្ដោតលើប្រធានបទជាមូលដ្ឋានបំផុតនៃដំណឹងល្អ ដូចដែលបានបង្ហាញនៅក្នុងរង្វង់នៃដ្យាក្រាមនេះ។



Scripture is supreme INDD interior - Khmer 1.9.indd 9 14/8/26 3:55 in the afternoon

សៀវភៅនីមួយៗនឹងនិយាយអំពីប្រធានបទរបស់វា ហើយទោះជាយ៉ាងណាក៏ដោយ គោលបំណងនៃស៊េរីនេះមិនមែនគ្រាន់តែដើម្បីបង្រៀនខ្លឹមសារមេរៀននោះទេ។ យ៉ាងណាមិញ ដំណឹងល្អមិនមែនគ្រាន់តែជាការបើកសម្ដែងប៉ុណ្ណោះ ប៉ុន្តែដំណឹងល្អគឺជាការបើកសម្ដែងដ៏ប្រោសលោះ និងផ្ដល់កំណើតជាថ្មី។ ដូច្នេះហើយ សូមឲ្យលោកអ្នកទទួលបានការកែប្រែជាថ្មី នៅពេលដែលលោកអ្នកបានអាន ហើយសូមឲ្យលោកអ្នកទទួលការដឹកនាំឲ្យថ្វាយបង្គំ ហើយរីករាយនឹង «សិរីល្អនៃព្រះដ៏មានពរ» (១ធីម៉ូថេ ១:១១) ។

លោកគ្រូ ម៉ៃខល រីវស៍ (Michael Reeves)
អ្នកកែសម្រួលស៊េរី



Scripture is supreme INDD interior - Khmer 1.9.indd 10 14/8/26 3:55 in the afternoon

១

# តើសម្លេងរបស់អ្នកណាសំខាន់ជាងគេ?

## សិទ្ធិអំណាចកំពូល

ខ្ញុំបានចាប់ផ្ដើមប្រើកម្មវិធីផែនទី ហ្គូហ្គល (Google Maps) យឺតជាងគេ។ ខ្ញុំកម្របានប្រើកម្មវិធីនេះណាស់។ នៅពេលដែលខ្ញុំធ្វើដំណើរតាមផែនទីក្រដាស (តើលោកអ្នកចងចាំវាទេ?) ខ្ញុំយល់ថា ខ្ញុំអាចចាំផ្លូវពេលធ្វើដំណើរលើកក្រោយបាន។ ប៉ុន្តែ កម្មវិធីផែនទីហ្គូហ្គលហាក់ដូចជាបានធ្វើឲ្យផ្នែកខួរក្បាលដែលគ្រប់គ្រងផ្នែករុករកផ្លូវរបស់ខ្ញុំដេកលក់។ ដូច្នេះហើយ បើខ្ញុំប្រើកម្មវិធីមួយនេះ នោះខ្ញុំមិនអាចចងចាំផ្លូវធ្វើដំណើរបានទេ ហើយពេលខ្ញុំធ្វើដំណើរតាមផ្លូវនោះម្ដងទៀត ខ្ញុំក៏មិនអាចធ្វើដំណើរដោយគ្មានជំនួយពីកម្មវិធីនេះលើកក្រោយទៀតបាននោះដែរ។

ប៉ុន្តែ បន្តិចម្ដងៗការតយុទ្ធរបស់ខ្ញុំកាន់តែខ្សោយទៅៗ។ ខ្ញុំគិតថា ភាពខ្ជិលច្រអូសបានជ្រៀតចូលក្នុង



Scripture is supreme INDD interior - Khmer 1.9.indd 11 14/8/26 3:55 in the afternoon

ជីវិតខ្ញុំ។ ការប្រើកម្មវិធីផែនទីហ្គូហ្គល គឺងាយស្រួលជាងការស្វែងរកផ្លូវដោយខ្លួនឯង ជាពិសេសនៅពេលដែលខ្ញុំគ្មានមិត្តភក្តិអង្គុយកាន់ផែនទីឲ្យខ្ញុំ។ សព្វថ្ងៃនេះ ខ្ញុំប្រើកម្មវិធីផែនទីហ្គូហ្គលស្ទើរតែគ្រប់ពេល។ ហើយខ្ញុំក៏រីករាយនឹងធ្វើតាមការណែនាំផ្លូវរបស់វា។

គឺធ្វើតាមច្រើនដង។ ប៉ុន្តែ មានពេលមួយ ខ្ញុំមិនបានធ្វើតាមការណែនាំឲ្យបត់ស្តាំរបស់វានោះទេ។ ខ្ញុំប្រើកម្មវិធីនោះដោយព្រោះខ្ញុំធ្វើដំណើរត្រឡប់មកពីកន្លែងដែលខ្ញុំមិនស្គាល់ច្បាស់។ តែពេលយើងបានធ្វើដំណើរជិតមកដល់ផ្ទះទៅហើយ ហើយក៏មកដល់តំបន់ដែលខ្ញុំធ្លាប់ស្គាល់វិញ។ ខ្ញុំនៅតែបន្តប្រើកម្មវិធីផែនទីហ្គូហ្គល ហើយភ្លាមៗនោះវាប្រាប់ខ្ញុំឲ្យទៅតាមផ្លូវមួយដែលខ្ញុំមិនធ្លាប់ធ្វើដំណើរពីមុនមកទេ។

ខ្ញុំមិនបានអើពើនឹងវាទេ។ មួយសន្ទុះក្រោយមកខ្ញុំក៏បានជាប់គាំងក្នុងការកកស្ទះចរាចរណ៍។ ពេលវេលាប៉ាន់ស្មាននៃការទៅដល់របស់ខ្ញុំបានកើនឡើងចំនួនសាមសិបនាទី។ ខ្ញុំគិតថា ខ្ញុំដឹងច្បាស់ជាងកម្មវិធីផែនទីហ្គូហ្គល ហើយឥឡូវនេះខ្ញុំកំពុងទទួលផលវិបាកដែលមិនធ្វើតាមការណែនាំរបស់វាវិញ។

យើងតែងរីករាយនឹងគិតអំពីខ្លួនឯងថាជាមនុស្សដែលមានសេរីភាព យើងអាចជ្រើសរើសធ្វើអ្វីដែល



Scripture is supreme INDD interior - Khmer 1.9.indd 12 14/8/26 3:55 in the afternoon

ចង់ធ្វើ។ ប៉ុន្តែ តាមពិតទៅយើងចំណាយពេលច្រើនក្នុងជីវិតរបស់យើងនៅក្រោមសណ្ឋាននៃសិទ្ធិអំណាចមួយចំនួន។ ពេលខ្លះ យើងធ្វើអ្វីដែលម្តាយរបស់យើងប្រាប់យើង។ យើងអនុវត្តតាមច្បាប់ចរាចរណ៍។ យើងទទួលយកការណែនាំពីចៅហ្វាយនាយរបស់យើង។ យើងធ្វើតាមសៀវភៅណែនាំផ្សេងៗ។ យើងធ្វើតាមការណែនាំពីកម្មវិធីផែនទីហ្គូហ្គលជាដើម។

ពេលខ្លះ យើងប្រហែលជាមិនចូលចិត្តអាជ្ញាធរ។ ជាក់ស្តែងទៅ តើអ្នកណាខ្លះចូលចិត្តឲ្យគេប្រាប់ពីអ្វីដែលគេត្រូវធ្វើនោះ? យើងត្អូញត្អែរអំពីច្បាប់របស់រដ្ឋាភិបាល ឬការទាមទារស្តីពីការងារដែលមិនសមហេតុផលមួយចំនួន។ ប៉ុន្តែ យើងនឹងត្អូញត្អែរថែមទៀត ប្រសិនបើគ្មានរដ្ឋាភិបាលទាល់តែសោះ។ ពិតណាស់ មានច្បាប់មួយចំនួនដែលយើងមិនចូលចិត្ត ប៉ុន្តែយើងនៅតែយល់ពីតម្រូវការឲ្យមានច្បាប់ និងសណ្តាប់ធ្នាប់នោះ។ ឧទាហរណ៍ ខ្ញុំអាចនឹងបើកបរបញ្ច្រាសនៅលើដងផ្លូវ ព្រោះគ្មានអ្វីមួយរារាំងខ្ញុំក្នុងការបើកបរឆ្លងផ្លូវនោះទេ។ ប៉ុន្តែ ការសម្រេចចិត្តនោះពិតជាធ្វើឲ្យខ្ញុំប្រឈមនឹងគ្រោះមហន្តរាយហើយ។

ក្នុងការបើកបរទៅកាន់ទីក្រុងថ្មីណាមួយ យើងត្រូវមានទាំងផែនទីហ្គូហ្គលដើម្បីបង្ហាញផ្លូវ និងការគោរព



Scripture is supreme INDD interior - Khmer 1.9.indd 13 14/8/26 3:55 in the afternoon

ច្បាប់ចរាចរណ៍ នោះទើបយើងអាចទៅដល់គោលដៅដោយសុវត្ថិភាពបាន។

ប៉ុន្តែ ចុះដំណើរជីវិតយើងវិញ? តើយើងអាចស្វែងរកផ្លូវនៃដំណើរជីវិតយើងដោយរបៀបណា? ចុះបើខ្ញុំចង់ទៅឯព្រះអម្ចាស់? តើខ្ញុំគួរធ្វើដំណើរតាមផែនទីមួយណា? តើប្រព័ន្ធនាំផ្លូវមួយណាអាចនឹងផ្តល់ទិសដៅត្រឹមត្រូវដល់ខ្ញុំបាន?

ចម្លើយនោះគឺសាមញ្ញណាស់៖ ព្រះគម្ពីរគឺជាអ្នកនាំផ្លូវដែលអាចទុកចិត្តបានតែមួយគត់សម្រាប់ដំណើរជីវិតរបស់យើង។ នៅពេលដែលគ្រីស្ទបរិស័ទនិយាយថា ព្រះគម្ពីរគឺមានសិទ្ធិអំណាចកំពូល នោះមានន័យថា ព្រះគម្ពីរ គឺជាអ្នកនាំផ្លូវដ៏មានសិទ្ធិអំណាចទៅកាន់ព្រះជាម្ចាស់។ ព្រះគម្ពីរ គឺប្រៀបដូចជាកម្មវិធីផែនទីហ្គូហ្គល ដែលផ្តល់ឲ្យយើងនូវទិសដៅសម្រាប់ជីវិត។ វាប្រៀបដូចជាច្បាប់ចរាចរណ៍ដែលបង្ហាញយើងពីអ្វីដែលព្រះជាម្ចាស់បានតម្រូវ។

## សិទ្ធិអំណាចក្នុងការនិយាយ

ព្រះគម្ពីរគឺជាសិទ្ធិអំណាចកំពូល។ នេះមានន័យថា ព្រះគម្ពីរមានសិទ្ធិអំណាច ហើយការស្តាប់ដោយយកចិត្តទុកដាក់ចំពោះអ្វីដែលព្រះគម្ពីរបានចែងជាការ



Scripture is supreme INDD interior - Khmer 1.9.indd 14 14/8/26 3:55 in the afternoon

សំខាន់ខ្លាំងណាស់។ នេះគឺដោយសារតែអ្វីដែលព្រះគម្ពីរបានចែង គឺពិតប្រាកដ។ ព្រះគម្ពីរមានសិទ្ធិអំណាចពីព្រោះយើងអាចទុកចិត្តលើព្រះគម្ពីរបាន។

តើកម្មវិធីហ្គូហ្គលមានសិទ្ធិអំណាចដែរឬទេ? ជាការពិតណាស់ កម្មវិធីហ្គូហ្គល គឺមានសិទ្ធិអំណាចនៅក្នុងទិដ្ឋភាពមួយ។ វាអាចជាប្រភពនៃព័ត៌មានពិត។ សូមស្រមៃថា លោកអ្នក និងមិត្តសម្លាញ់ម្នាក់កំពុងតែជជែកគ្នា ថាតើក្រុមបាល់ទាត់ប្រទេសណាបានឈ្នះការប្រកួតពានរង្វាន់បាល់ទាត់ពិភពលោកក្នុងឆ្នាំ ២០១៤។ លោកអ្នកនិយាយថា គឺប្រទេសប្រេស៊ីល ហើយមិត្តរបស់លោកអ្នកនិយាយថា គឺប្រទេសអាល្លឺម៉ង់។ ការប្រកែកគ្នានេះអាចដោះស្រាយបានយ៉ាងងាយ។ ដោយគ្រាន់តែមាននរណាម្នាក់ក្នុងចំណោមអ្នកទាំងពីរអាចយកទូរស័ព្ទចេញមក ហើយពិនិត្យមើលក្នុងកម្មវិធីហ្គូហ្គល។ លោកអ្នកអាចដឹងបានថា មិត្តរបស់លោកអ្នកនិយាយត្រូវ៖ គឺជាប្រទេសអាល្លឺម៉ង់ (ខ្ញុំក៏ធ្លាប់មានការប្រកែកគ្នាបែបដូចគ្នានេះពីមុនមកដែរ)។

កម្មវិធីហ្គូហ្គល មានសិទ្ធិអំណាចក្នុងការដោះស្រាយការប្រកែកគ្នារវាងមិត្តភក្តិ។ ប៉ុន្តែ កម្មវិធីហ្គូហ្គលមិនមែនតែងតែអាចទុកចិត្តបាន ១០០% នោះទេ។ វា



Scripture is supreme INDD interior - Khmer 1.9.indd 15 14/8/26 3:55 in the afternoon

អាស្រ័យថាតើអ្នកណាជាអ្នកផ្សព្វផ្សាយព័ត៌មាននោះផងដែរ។ ពេលខ្លះ មានមនុស្សបន្ថែមព័ត៌មានមិនពិតនៅលើវេបសាយនោះ។ ដូច្នេះ ក្នុងនាមជាសមាជិកសាស្ត្រាចារ្យដ៏ប្រុងប្រយ័ត្នម្នាក់នៃវគ្គបណ្ដុះបណ្ដាលក្រស់លែនស៍ (Crosslands Training) ខ្ញុំបានដាស់តឿនសិស្សរបស់ខ្ញុំកុំឲ្យជឿទុកចិត្តលើអ្វីៗគ្រប់យ៉ាងតាមប្រព័ន្ធអ៊ីនធឺណិតពេក។ បើយើងត្រូវវាយតម្លៃលើភាពជឿជាក់បាននៃប្រព័ន្ធអ៊ីនធឺណិត នោះយើងអាចផ្ដល់ពិន្ទុឲ្យវា ៨០ភាគរយប៉ុណ្ណោះ។

ចុះចំណែកឯសៀវភៅសិក្សានៅសកលវិទ្យាល័យវិញ? តើវាមានសិទ្ធិអំណាចដែលយើងអាចទុកចិត្តបានដែរឬទេ? យើងសង្ឃឹមថា សៀវភៅនោះត្រូវបានសរសេរឡើងដោយអ្នកជំនាញទទួលបាននូវការកែសម្រួលដោយប្រុងប្រយ័ត្ន ហើយប្រហែលជាបានត្រួតពិនិត្យឡើងវិញ ដោយអ្នកជំនាញជាច្រើនរូបទៀតផង។ វាប្រហែលជាអាចទុកចិត្តបានជាងកម្មវិធីហ្គូហ្គល ។ ប៉ុន្តែ សៀវភៅជាច្រើនមានកំហុសតូចតាច ដូចជាការសរសេរអក្សរខុស ឬកាលបរិច្ឆេទខុសជាដើម។ លើសពីនេះទៅទៀត ព័ត៌មានមួយចំនួននៅក្នុងសៀវភៅតែងតែត្រូវការកែសម្រួល។ ពីពេលមួយទៅពេលមួយ គេតែងរករបកគំហើញ និងគំនិតថ្មីៗ។ ដូច្នេះ ទោះបើ



Scripture is supreme INDD interior - Khmer 1.9.indd 16 14/8/26 3:55 in the afternoon

សៀវភៅសិក្សារបស់យើងនឹងទទួលបានពិន្ទុខ្ពស់ជាងនៅក្នុងកម្រិតដែលអាចជឿទុកចិត្តបានក៏ដោយ ក៏យើងមិនអាចផ្ដល់ពិន្ទុឲ្យវា ១០០/១០០ បាននោះដែរ។ សៀវភៅនោះប្រហែលជាអាចមានសិទ្ធិអំណាចច្រើនជាងកម្មវិធីហ្គូហ្គល ប៉ុន្តែសិទ្ធិអំណាចរបស់វានៅមានកម្រិតនៅឡើយ។

ទោះជាយ៉ាងណាក៏ដោយ ព្រះគម្ពីរគឺពិតប្រាកដ ១០០% ដូច្នេះព្រះគម្ពីរមានសិទ្ធិអំណាច ១០០%។ លោក វីល្លាម ធីនដេល (William Tyndale) (១៤៩៤-១៥៣៦) ដែលត្រូវគេសម្លាប់ដោយសារការបកប្រែព្រះគម្ពីរទៅជាភាសាអង់គ្លេសបានលើកឡើងថា ព្រះគម្ពីរជា «ស្ដង់ដារ» ដែលជួយយើងឲ្យស្គាល់ពីភាពខុសគ្នារវាងគោលលទ្ធិខុសឆ្គង និងគោលលទ្ធិត្រឹមត្រូវ។[២]

ពាក្យ «ព្រះបន្ទូល» នៅក្នុងឃ្លា «ព្រះបន្ទូលគឺមានសិទ្ធិអំណាចកំពូល» សំដៅលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលគេបានសរសេរឡើង ដែលយើង

២ លោក William Tyndale, "Prologue to the Book of Genesis," នៅក្នុង *Works of William Tyndale,* កែសម្រួលដោយលោក Henry Walter (Edinburgh: Banner of Truth, ឆ្នាំ២០១០), ភាគ១, ទំព័រ៣៩៨។



Scripture is supreme INDD interior - Khmer 1.9.indd 17 14/8/26 3:55 in the afternoon

មាននៅក្នុងព្រះគម្ពីរ។ «ព្រះបន្ទូល» ដែលមានសិទ្ធិអំណាចកំពូល ក៏អាចរួមបញ្ចូលទាំងការប្រកាសដំណឹងល្អ និងការអធិប្បាយព្រះគម្ពីរផងដែរ ប៉ុន្តែលុះត្រាតែព្រះបន្ទូលទាំងនោះឆ្លុះបញ្ចាំងយ៉ាងស្មោះត្រង់នឹងអ្វីដែលបានបង្រៀននៅក្នុងបទគម្ពីរ។ ព្រះគម្ពីរគឺជាខ្នាតដែលយើងវាស់វែងសេចក្តីពិតនៃអ្វីៗផ្សេងទៀត។

## សិទ្ធិអំណាចក្នុងការគ្រប់គ្រង

សិទ្ធិអំណាចនៃព្រះគម្ពីរមានវិសាលភាពធំជាងនេះទៅទៀត ពីព្រោះព្រះគម្ពីរមានវិសាលភាពលើសហួសពីប្រភពព័ត៌មានដែលអាចទុកចិត្តបានទៅទៀត។ ព្រះគម្ពីរបង្រៀនយើងពី «អ្វី» ពោលគឺអ្វីដែលល្អ និងអ្វីដែលពិតជាដើម។ ប៉ុន្តែ ព្រះគម្ពីរក៏ប្រាប់យើងពី «របៀប» ផងដែរ ពោលគឺរបៀបដែលយើងស្គាល់ព្រះជាម្ចាស់ និងរបៀបដែលយើងអាចរស់នៅក្នុងជីវិតដែលព្រះជាម្ចាស់សព្វព្រះទ័យឲ្យយើងរស់នៅ។ ព្រះគម្ពីរគឺជាសៀវភៅមួយក្បាលដែលទាមទារឲ្យមាន «ការឆ្លើយតប»។ លោកអ្នកមិនអាចអានព្រះគម្ពីរហើយ រួចនិយាយថា «គួរឲ្យចាប់អារម្មណ៍ណាស់!» ជាមួយនឹងឥរិយាបថដ៏ធុញទ្រាន់នោះទេ។ លោកអ្នក



Scripture is supreme INDD interior - Khmer 1.9.indd 18 14/8/26 3:55 in the afternoon

មិនអាចនៅដាច់ដោយឡែកបានពីព្រះគម្ពីរបានទេ។ លោកអ្នកត្រូវធ្វើអ្វីមួយជាមួយនឹងព្រះគម្ពីរនៅពេលអានរួចហើយ៖ ទោះបីជាស្រឡាញ់ ឬស្អប់ ទទួលយក ឬបដិសេធ ស្តាប់តាម ឬមិនស្តាប់តាមព្រះគម្ពីរក៏ដោយ។ ប៉ុន្តែ លោកអ្នកមិនអាចជ្រើសរើសនៅជាកណ្តាលបាននោះទេ។

មែនហើយ! ព្រះគម្ពីរគឺជាសៀវភៅមួយក្បាលដែលផ្ទុកនូវការពិតជាច្រើន។ ប៉ុន្តែ ព្រះគម្ពីរក៏មានអ្វីៗជាច្រើនលើសជាងនោះទៅទៀតផងដែរ។ ព្រះគម្ពីរជាសៀវភៅមួយក្បាលដែលមានទាំងពាក្យបង្គាប់បញ្ជានិងការអញ្ជើញផងដែរ។ ពាក្យពេចន៍នៃព្រះគម្ពីរគឺមានឥទ្ធិពល។ ទោះបីជាព្រះគម្ពីរមិនបានបង្គាប់អ្វីមួយក៏ដោយ ក៏សារនៃព្រះបន្ទូលគឺនាំមកនូវផលប៉ះពាល់ដ៏ធំផងដែរ។

ការអះអាងដ៏ចម្បងមួយនៃព្រះគម្ពីរគឺថា ព្រះយេស៊ូវបានមានព្រះជន្មរស់ពីសុគតឡើងវិញ ហើយព្រះអង្គជាព្រះអម្ចាស់លើទាំងអស់ (រ៉ូម ១:១-៤; ១កូរិនថូស ១៥:៣-៤ )។ នៅពេលដែលមើលមួយភ្លែត នេះគ្រាន់តែជាការអះអាងដ៏សាមញ្ញមួយប៉ុណ្ណោះ។ ប៉ុន្តែ ការអះអាងនេះទាមទារឲ្យមានការឆ្លើយតប។ ប្រសិនបើលោកអ្នកគ្រាន់តែឆ្លើយតបដោយនិយាយថា «ការ



Scripture is supreme INDD interior - Khmer 1.9.indd 19 14/8/26 3:55 in the afternoon

នោះគួរឲ្យចាប់អារម្មណ៍» នោះលោកអ្នកពិតជាមិនយល់ច្បាស់អំពីអត្ថន័យនៃការមានព្រះជន្មរស់ពីសុគតឡើងវិញរបស់ព្រះយេស៊ូវនោះទេ។ ការមានព្រះជន្មរស់ពីសុគតឡើងវិញ គឺជាការបញ្ជាក់ថា ព្រះយេស៊ូវ គឺជាក្សត្រដែលមកពីព្រះ។ ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវ ហៅឲ្យលោកអ្នកចុះចូលជាមួយនឹងភាពជាព្រះអម្ចាស់របស់ព្រះគ្រីស្ទ ហើយពឹងផ្អែកទាំងស្រុងលើព្រះយេស៊ូវ ដើម្បីឲ្យទ្រង់ថែរក្សាលោកអ្នក។

នៅក្នុងការធ្វើដំណើរត្រឡប់ទៅផ្ទះនាពេលថ្មីៗនេះ កម្មវិធីផែនទីហ្គូហ្គលរបស់ខ្ញុំបានប្រាប់ខ្ញុំឲ្យបត់ស្តាំ។ ខ្ញុំបានព្រងើយកន្តើយនឹងការប្រាប់ទិសដៅនោះ ហើយការធ្វើដំណើររបស់ខ្ញុំត្រូវចំណាយពេលជាងសាមសិបនាទីទៀត។ ប៉ុន្តែ នោះមិនមែនជាផលប៉ះវិបាកធំដុំនោះទេ។ ជាធម្មតា វាជារឿងសមហេតុសមផលណាស់ក្នុងការចុះចូលទៅនឹងសិទ្ធិអំណាចរបស់កម្មវិធីផែនទីហ្គូហ្គល ប៉ុន្តែនៅទីបញ្ចប់វាមិនជះឥទ្ធិពលខ្លាំងដល់ជីវិតនោះទេ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលគេប្រាប់នរណាម្នាក់ឲ្យដើរតាមព្រះគ្រីស្ទ ហើយជឿលើទ្រង់សម្រាប់ជីវិតរបស់ពួកគេ នោះគឺជាស្ថានភាពខុសគ្នាខ្លាំងណាស់។ ផលវិបាកធំធេងណាស់ ពោលគឺផលវិបាកទាំងនោះ ប៉ះពាល់ដល់គ្រប់ផ្នែកនៃជីវិត ហើយ



Scripture is supreme INDD interior - Khmer 1.9.indd 20 14/8/26 3:55 in the afternoon

លើសពីជីវិតនេះទៅទៀតនោះ គឺរហូតដល់អស់កល្ប ជានិច្ច។

ការនិយាយថា ព្រះបន្ទូលគឺមានសិទ្ធិអំណាច កំពូល គឺមានន័យថា ព្រះគម្ពីរមានសិទ្ធិអំណាចលើ អ្វីគ្រប់យ៉ាងដែលសំខាន់រួមមាន៖ ពេលវេលា និង ភាពអស់កល្បជានិច្ច ផែនដី និងស្ថានសួគ៌ មនុស្ស ជាតិ និងព្រះជាម្ចាស់។ ព្រះគម្ពីរមិនដូចគ្នាទៅនឹង កម្មវិធីផែនទីហ្គូហ្គល ដែលប្រាប់លោកអ្នកពីរបៀប ទៅដល់ទីក្រុងឡុងដ៍នោះទេ។ ព្រះគម្ពីរក៏មិនដូចទៅ នឹងកម្មវិធីហ្គូហ្គល ដែលប្រាប់លោកអ្នកថា តើក្រុម បាល់ទាត់ប្រទេសណាបានឈ្នះការប្រកួតពានរង្វាន់ បាល់ទាត់ពិភពលោកក្នុងឆ្នាំ២០១៤ នោះដែរ។ ប៉ុន្តែ ព្រះគម្ពីរមានសិទ្ធិអំណាចទៅលើថា តើព្រះជាម្ចាស់ ជានរណា? តើអ្វីជាគោលបំណងរបស់ទ្រង់? តើពួក យើងជានរណា? តើយើងអាចស្គាល់ទ្រង់បានដោយ របៀបណា? តើយើងអាចទទួលបានការសង្គ្រោះពីការ ជំនុំជម្រះរបស់ទ្រង់? និងថាតើយើងអាចរស់នៅក្នុង ជីវិតមួយដែលគាប់ព្រះហឫទ័យទ្រង់ បានដោយរបៀប ណា?



Scripture is supreme INDD interior - Khmer 1.9.indd 21 14/8/26 3:55 in the afternoon

«សូមបង្ហាញខ្ញុំថា គេបានសរសេរពីការនេះនៅត្រង់កន្លែងណា»

កាលពីក្មេង ស្ត្រីអភិជនជនជាតិបាវ៉ារៀម្នាក់ឈ្មោះ អាហ្គូឡា វ៉ុន ហ្គ្រាមបាច (Argula von Grumbach) (ឆ្នាំ១៤៩២-១៥៥៤ នៃគ.ស.) បានទទួលព្រះគម្ពីរមួយក្បាលពីឪពុករបស់នាង។ នៅពេលដែលគំនិតកំណែទម្រង់របស់ប្រូតេស្តង់ចាប់ផ្ដើមរីករាលដាល នាងបានក្លាយជាអ្នកគាំទ្រដ៏សំខាន់ម្នាក់ ទោះស្វាមីរបស់នាងនៅមានការសង្ស័យក៏ដោយ។

នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៥២៣ នាង អាហ្គូឡា បានសរសេរសំបុត្រមួយច្បាប់ ដោយជំរុញឲ្យសាស្ត្រាចារ្យ នៃ សាកលវិទ្យាល័យ អ៊ីនហ្គូលស្ដាត (Ingolstadt) ឲ្យមានកិច្ចពិភាក្សាដេញដោលជាសាធារណៈមួយ។ នាងបានការពារនិស្សិតអាយុដប់ប្រាំបីឆ្នាំម្នាក់ឈ្មោះ អារសាស៊ុស ស៊ីហូហ្វឺរ (Arsacius Seehofer )។ លោក អារសាស៊ុស បានទទួលការគំរាមកំហែងដោយការធ្វើទារុណកម្ម ដើម្បីបង្ខំគាត់ឲ្យបដិសេធជំនឿ «តាមដំណឹងល្អ» ដែលគាត់ទើបតែរកឃើញ។

សំបុត្ររបស់នាង អាហ្គូឡា មានការចាប់អារម្មណ៍យ៉ាងខ្លាំង ហើយត្រូវបានគេបោះពុម្ពឡើងវិញចំនួនដប់



Scripture is supreme INDD interior - Khmer 1.9.indd 22 14/8/26 3:55 in the afternoon

ប្អូនដងក្នុងរយៈពេលពីរខែដំបូង។ នាងបាននិយាយថា «ខ្ញុំមិនអាចរកឃើញពាក្យពេចន៍ណាមួយក្នុងព្រះគម្ពីរអំពីវិហាររ៉ូម៉ាំងកាតូលិកនេះឡើយ។ ខ្ញុំនឹងសប្បាយចិត្ត ប្រសិនបើអ្នកអាចបង្ហាញខ្ញុំពីអ្វីដែលព្រះជាម្ចាស់មានបន្ទូលអំពីវិហាររ៉ូម៉ាំងកាតូលិក»។ នាង អាហ្គូឡា បានពន្យល់អំពីភាពខុសឆ្គង ដែលគេបានចោទប្រកាន់ដល់លោក អារសាស៊ុស យ៉ាងដូច្នេះថា៖ «ខ្ញុំមិនបានឮអ្វីពីអ្នកណាម្នាក់ក្នុងចំណោមអ្នករាល់គ្នាបានជជែកវែកញែកលើចំណុចណាមួយដោយប្រើព្រះគម្ពីរនោះទេ» ។ នាង អាហ្គូឡា បាននិយាយថា៖ «តើលោក ម៉ាធិន លូសើរ (Martin Luther) និងលោក ភីលីព ម៉េឡាញថុន (Philip Melanchthon) បានបង្រៀនអ្នកអ្វីខ្លះដែលពួកគាត់មិនយោងលើព្រះបន្ទូលរបស់ព្រះជាម្ចាស់នោះ? អ្នករិះគន់ពួកគាត់ ដោយមិនមានអ្វីប្រកែកនឹងពួកគាត់។ តើព្រះគ្រីស្ទបានបង្រៀនអ្នកឲ្យធ្វើដូច្នេះឬទេ? ឬតើពួកសាវ័ក ពួកហោរា ឬអ្នកផ្សាយដំណឹងល្អរបស់ទ្រង់បានបង្រៀនអ្នកឲ្យធ្វើដូច្នេះឬទេ? សូមបង្ហាញខ្ញុំថាគេបានសរសេរពីការនេះនៅត្រង់កន្លែងណា!»

ការអះអាងរបស់នាង អាហ្គូឡា ត្រូវបានគេច្រានចេញនៅសាកលវិទ្យាល័យអ៊ីនហ្គូលស្តាត ហើយ



Scripture is supreme INDD interior - Khmer 1.9.indd 23 14/8/26 3:55 in the afternoon

បណ្ដាជនបានហៅនាងថា «មនុស្សល្ងីល្ងើ» និង «អារក្សស្រី»។ ប៉ុន្ដែ ការថ្លែងរបស់នាងថា «សូមបង្ហាញខ្ញុំថាគេបានសរសេរពីការនេះនៅត្រង់កន្លែងណា» បានក្លាយជានិមិត្តរូបនៃជំនឿរបស់អ្នកជឿពិតប្រាកដគ្រប់រូប។ យើងនឹងទទួលយកនូវអ្វីដែលនរណាម្នាក់កំពុងនិយាយ ប្រសិនបើគាត់អាចបង្ហាញយើងពីកន្លែងដែលព្រះគម្ពីរបានបង្រៀនអំពីចំណុចនោះ។[៣]

## សិទ្ធិអំណាចដែលធំជាងគ្រប់ទាំងសិទ្ធិអំណាចដទៃទៀត

«ព្រះបន្ទូលគឺជាសិទ្ធិអំណាចកំពូល» មានន័យថា ព្រះគម្ពីរមាននូវសិទ្ធិអំណាច។ ប៉ុន្ដែ វាជាការអះអាងមួយដែលធំសម្បើមជាងនេះទៅទៀត។ ការដែលនិយាយថាអ្វីមួយមានសិទ្ធិអំណាច គឺមិនមែនជាការអស្ចារ្យដោយខ្លួនឯងនោះទេ។ មានប្រភពនៃសិទ្ធិអំណាចជាច្រើន នៅក្នុងជីវិតរស់នៅរបស់យើង។

៣ លោក Peter Matheson, កែសម្រួលដោយលោក៖ *Argula von Grumbach: A Woman's Voice in the Reformation* (Edinburgh: T&T Clark, ឆ្នាំ១៩៩៥), ទំព័រ៧៥-៩៥ បោះពុម្ពលើត្រង់ចំណុចដែលបានជ្រើសរើសរួច, សម្រង់សម្ដីលោក Timothy Theorge, *Reading the Scriptures with the Reformers* (Grand Rapids, MI: IVP, ឆ្នាំ២០១១), ទំព័រ៤៨-៥០។



Scripture is supreme INDD interior - Khmer 1.9.indd 24 14/8/26 3:55 in the afternoon

ឧបមាថា លោកអ្នកចង់ទិញឡានថ្មីមួយគ្រឿង។ តើលោកអ្នកត្រូវធ្វើអ្វីខ្លះ? លោកអ្នកប្រហែលជាត្រូវពឹងផ្អែកលើបទពិសោធន៍ពីអតីតកាលរបស់លោកអ្នក។ ប្រហែលជារថយន្តចុងក្រោយរបស់លោកអ្នក គឺជារថយន្តម៉ាកហ្វដ (Ford) ហើយវាដំណើរការល្អ ដូច្នេះលោកអ្នកជ្រើសរើសទិញរថយន្តម៉ាកហ្វដផ្សេងទៀត។ ឬលោកអ្នកប្រហែលជាពឹងផ្អែកលើគំនិតរបស់មិត្តភក្តិរបស់លោកអ្នក។ ឧទាហរណ៍ មិត្តភក្តិរបស់អ្នកឈ្មោះចន គាត់ដឹងច្រើនអំពីរថយន្ត ដូច្នេះអ្នកប្រាប់គាត់អំពីគម្រោងថវិកាដែលចង់ចំណាយទៅលើយានយន្ត ហើយសុំការណែនាំពីគាត់។ ឬប្រហែលជាលោកអ្នករកមើលតាមប្រព័ន្ធអ៊ីនធឺណិត ដើម្បីដឹងថាតើអ្នកជំនាញនិយាយអ្វីខ្លះទាក់ទងនឹងរថយន្ត។ ឬលោកអ្នកក៏អាចចូលទៅមើលកំណត់ត្រាលក់ ហើយជ្រើសរើសម៉ូដែលដែលពេញនិយម។ ជម្រើសនីមួយៗ មានកម្រិតជាក់លាក់ទាក់ទងនឹងភាពប្រាកដប្រជា។ វាជារឿងសមហេតុផលក្នុងការស្តាប់យោបល់ពីប្រភពផ្សេងៗពីគ្នា។ ប៉ុន្តែ តើនឹងមានអ្វីកើតឡើង ប្រសិនបើអ្នកជំនាញលើកឡើងខុសគ្នា? តើនឹងមានអ្វីកើតឡើង ប្រសិនបើពួកគេម្នាក់ៗណែនាំម៉ូដែលផ្សេងគ្នា? បន្ទាប់មក លោកអ្នកត្រូវសម្រេចថា តើនរណាមានសិទ្ធិអំណាច*ច្រើនជាងគេ*។ តើលោកអ្នកនឹងជឿលើគំនិតយោបល់របស់អ្នក



Scripture is supreme INDD interior - Khmer 1.9.indd 25 14/8/26 3:55 in the afternoon

ណា? តើលោកអ្នកនឹងធ្វើតាមដំបូន្មានរបស់អ្នកណា? តើលោកអ្នកជ្រើសរើសដំបូន្មានដែលល្អបំផុតដោយរបៀបណា?

ការនិយាយថា «ព្រះបន្ទូលគឺជាសិទ្ធិអំណាចកំពូល» មានន័យថា ព្រះគម្ពីរមានសិទ្ធិអំណាច ហើយក៏មានសិទ្ធិអំណាច*ខ្ពស់បំផុត*ផងដែរ។ ព្រះគម្ពីរជាសម្លេងមួយដ៏សំខាន់បំផុត។ គ្រីស្ទបរិស័ទក៏ទទួលស្គាល់ពីសិទ្ធិអំណាចផ្សេងទៀតផងដែរ។ មានសម្លេងផ្សេងទៀតដែលសំខាន់។ ប៉ុន្តែ ព្រះបន្ទូលតែងតែជាសម្លេងដែលឈ្នះលើសម្លេងដទៃផ្សេងៗទៀត។ បើយើងត្រូវជ្រើសរើស យើងនឹងជ្រើសរើសធ្វើតាមព្រះគម្ពីរជានិច្ច។ *នោះហើយ*ជាអត្ថន័យនៃគោលលទ្ធិស្ដីពីសិទ្ធិអំណាចកំពូលរបស់ព្រះបន្ទូល។ យើងអាចតម្រូវឲ្យមនុស្សគោរពតាមសេចក្ដីបង្គាប់ណាមួយបាន លុះត្រាតែសេចក្ដីបង្គាប់នោះមានបង្រៀននៅក្នុងព្រះគម្ពីរ។ អ្នកកំណែទម្រង់ម្នាក់ឈ្មោះលោក ម៉ាធិន លូសើរ (Martin Luther) (ឆ្នាំ១៤៨៣-១៥៤៦) មានប្រសាសន៍ថា «អ្វីដែលគេនិយាយដោយគ្មានខគម្ពីរយោង ឬការបើកសម្ដែងដែលមានការបញ្ជាក់ច្បាស់លាស់ គឺយើងអាចរាប់បានថាវាជាគំនិតមួយ



Scripture is supreme INDD interior - Khmer 1.9.indd 26 14/8/26 3:55 in the afternoon

ប៉ុន្តែយើងមិនចាំបាច់ត្រូវជឿនោះទេ»។[៤] ប៉ុន្តែ អ្វីដែលគេអាចបង្ហាញចេញពីព្រះគម្ពីរ នោះយើងត្រូវតែជឿ។ ទេវវិទូជនជាតិហូឡង់ម្នាក់ឈ្មោះលោក ហើរម៉ែន បាវីក (Herman Bavinck) (ឆ្នាំ១៨៥៤-១៩២១) បានសន្និដ្ឋានថា៖

> «សិទ្ធិអំណាចនៃព្រះបន្ទូល គឺខ្ពង់ខ្ពស់ជាងសិទ្ធិអំណាចរបស់មនុស្សទាំងអស់នៅក្នុងសង្គម ប្រទេសជាតិ វិទ្យាសាស្ត្រ និងសិល្បៈ។ អ្វីៗទាំងអស់ផ្សេងទៀត ត្រូវចុះចូលជាមួយនឹងព្រះបន្ទូល។ មនុស្សត្រូវកោតខ្លាចព្រះជាម្ចាស់ជាជាងកោតខ្លាចមនុស្សផ្សេងទៀត...សិទ្ធិអំណាចនៃព្រះបន្ទូល គឺមកពីព្រះជាម្ចាស់ ដូច្នេះវាគឺជាសិទ្ធិអំណាចកំពូល។ យើងត្រូវជឿទុកចិត្ត និងកោតខ្លាចលើសិទ្ធិអំណាចនៃព្រះបន្ទូលគ្រប់ពេលវេលា»។[៥]

---

៤ លោក Martin Luther, "The Babylonian Captivity of the Church," in The Annotated Luther, ភាគ៣ Church and Sacraments, កែសម្រួលដោយលោក Paul R. Robinson (Minneapolis, MN: Fortress Press, ឆ្នាំ២០១៦), ទំព័រ៣១។

៥ លោក Herman Bavinck, Reformed Dogmatics, ភាគ១, Prolegomena, កែសម្រួលដោយលោក John Bolt, បកប្រែដោយលោក John Vriend (Grand Rapids, MI: Baker Academic, ឆ្នាំ២០០៣), ទំព័រ៤៦៥។



Scripture is supreme INDD interior - Khmer 1.9.indd 27 14/8/26 3:55 in the afternoon

## លោក បាស៊ីល (Basil) បានបញ្ចប់ជម្លោះនោះ

លោក បាស៊ីល មកពីក្រុងសេសារា (Basil of Caesarea ឆ្នាំ៣៣០-៣៧៩ នៃគ.ស.) គឺជាអ្នកការពារដំបូងនៃគោលលទ្ធិព្រះត្រៃឯក។ ប៉ុន្តែអ្នកប្រឆាំងរបស់គាត់បានចោទប្រកាន់គាត់ថាបានបង្កើតគោលលទ្ធិថ្មីទៅវិញ។ ពួកគេបាននិយាយថា៖ «ទំនៀមទម្លាប់របស់យើងមិនទទួលយកគោលលទ្ធិនេះទេ» ។

លោក បាស៊ីល បាននិយាយថា៖ «ខ្ញុំមិនជឿថាវាយុត្តិធម៌នោះទេ ដែលចាត់ទុកទំនៀមទម្លាប់របស់ពួកគេ ដូចជាច្បាប់នៃគោលលទ្ធិនោះ។ ប្រសិនបើយើងប្រើទំនៀមទម្លាប់ជាសំអាង នោះខ្ញុំក៏អាចសំអាងទៅលើទំនៀមទម្លាប់របស់យើងបានដូចគ្នាដែរ»។ នេះនឹងធ្វើឲ្យមានទំនៀមទម្លាប់ពីរប្រកួតប្រជែងគ្នាដោយគ្មានវិធីក្នុងការសម្រេចថា តើមួយណាល្អជាងនោះទេ។

តើអ្វីជាដំណោះស្រាយរបស់លោក បាស៊ីល ចំពោះការលើកឡើងនេះ? លោកបានស្នើឲ្យសួរសិទ្ធិអំណាចដែលខ្ពស់ជាង។ «ដូច្នេះ ចូរយើងអនុញ្ញាតឲ្យព្រះគម្ពីរដែលព្រះជាម្ចាស់បណ្ដាលឲ្យតែង ធ្វើការសម្រេចរវាងភាគីយើងទាំងពីរ។ ចូរឲ្យសេចក្ដីពិតគាំទ្រដល់ភាគីណាមួយដែលយល់ស្របតាមព្រះបន្ទូល



Scripture is supreme INDD interior - Khmer 1.9.indd 28 14/8/26 3:55 in the afternoon

របស់ព្រះជាម្ចាស់»។[៦] សូមកត់សម្គាល់ពីរបៀបដែល លោក បាស៊ីល ហៅព្រះគម្ពីរថាជា «ព្រះបន្ទូលដែលព្រះជាម្ចាស់បណ្ដាលឲ្យតែង»។ យើងគួរជ្រើសរើសព្រះគម្ពីរ ព្រោះព្រះគម្ពីរគឺមកពីព្រះជាម្ចាស់ (២ធីម៉ូថេ ៣:១៦)។ ព្រះគម្ពីរដែលព្រះជាម្ចាស់បណ្ដាលឲ្យ នោះតែងតែឈ្នះលើទំនៀមទម្លាប់ និងគំនិតរបស់មនុស្ស។ ពិតមែន គឺឈ្នះគ្រប់ពេលទាំងអស់។

៦ សេចក្ដីពន្យល់របស់អ្នកនិពន្ធស្ដីពី Basil of Caesarea, «សំបុត្រលេខ ១៨៩» ផ្នែកទី៣ នៅក្នុងគោលលទ្ធិNicene and Post-Nicene Fathers ស៊េរីទី២ កែសម្រួលដោយ លោក Philip Schaff និងលោក Henry Wace (Peabody, Massachusetts: Hendrickson, ឆ្នាំ១៩៩៤) ទំព័រ២២៩។



Scripture is supreme INDD interior - Khmer 1.9.indd 29 14/8/26 3:55 in the afternoon

## ការឆ្លុះបញ្ចាំង ឬការពិភាក្សា

១. «ខ្ញុំគិតថា ខ្ញុំដឹងច្បាស់ជាងកម្មវិធីផែនទីហ្គូហ្គល ហើយឥឡូវនេះខ្ញុំកំពុងទទួលផលវិបាក»។ តើលោកអ្នកអាចស្រមៃដល់គ្រាណាមួយ ដែលលោកអ្នកមានភាពត្រឹមត្រូវជាងគម្ពីរបានដែរឬទេ? តើលទ្ធផលយ៉ាងណាដែរ?

២. តើលោកអ្នកនឹងពណ៌នាអំពីសិទ្ធិអំណាចកំពូលនៃព្រះបន្ទូលយ៉ាងដូចម្តេច៖

ក) ចំពោះអ្នកមិនជឿ និង

ខ) ចំពោះគ្រីស្ទបរិស័ទថ្មី? តើការពណ៌នារបស់លោកអ្នកផ្លាស់ប្តូរដែរឬទេ? តើនឹងមានការផ្លាស់ប្តូរដោយរបៀបណា ហើយហេតុអ្វី?

៣. «លោកអ្នកត្រូវធ្វើអ្វីមួយជាមួយនឹងព្រះគម្ពីរនៅពេលអាន...ប៉ុន្តែ លោកអ្នកមិនអាចជ្រើសរើសនៅជាកណ្តាលបាននោះទេ»។ តើលោកអ្នកបានឃើញសេចក្តីពិតនេះប៉ះពាល់ដល់ជីវិតរបស់លោកអ្នក ឬជីវិតរបស់មនុស្សដែលលោកអ្នកស្គាល់ដោយរបៀបណា?



Scripture is supreme INDD interior - Khmer 1.9.indd 30 14/8/26 3:55 in the afternoon

២

# ហេតុអ្វីបានជាព្រះគម្ពីរមានសិទ្ធិអំណាចកំពូល ?

## សិទ្ធិអំណាចដែលមានលក្ខណៈជាបុគ្គល

យើងបានយល់ឃើញថា «ព្រះគម្ពីរគឺជាសិទ្ធិអំណាចកំពូល» មានន័យថា ព្រះគម្ពីរគឺជាសិទ្ធិអំណាចខ្ពស់បំផុតរបស់យើង។ ប៉ុន្តែ ការនេះនាំឲ្យមានសំណួរមួយចោទសួរថា៖ *ហេតុអ្វី?* ហេតុអ្វីបានជាចាត់ទុកព្រះគម្ពីរជាសិទ្ធិអំណាចដ៏ខ្ពស់បំផុត? ហេតុអ្វីបានជាផ្តល់ភាពសំខាន់ដល់សៀវភៅមួយក្បាលនេះ ដែលមានគេសរសេរឡើងតាំងពីរាប់រយឆ្នាំកន្លងទៅហើយ ក្នុងស្ថានភាពសង្គម និងប្រវត្តិសាស្ត្រផ្សេងៗគ្នា ដែលខុសប្លែកពីស្ថានភាពរបស់យើងនៅសម័យកាលនេះ?

ចម្លើយ៖ ព្រះគម្ពីរបានកើតចេញមកពីព្រះត្រៃឯក។ សម្លេងដែលលោកអ្នកឮក្នុងព្រះគម្ពីរ គឺជាសម្លេងរបស់ព្រះជាម្ចាស់។ ប្រយោគនៃ «សេចក្តីថ្លែងការណ៍អំពី



Scripture is supreme INDD interior - Khmer 1.9.indd 31 14/8/26 3:55 in the afternoon

សេចក្ដីជំនឿនៅវ៉េស្ទមីនស្ទើរ» ក្នុងឆ្នាំ១៦៤៧ (The ១៦៤៧ Westminster Confession of Faith) បានចែងថា៖ «សិទ្ធិអំណាចនៃព្រះគម្ពីរបរិសុទ្ធ ដែលយើងត្រូវតែជឿ និងគោរពប្រតិបត្តិតាម គឺមិនអាស្រ័យលើទីបន្ទាល់របស់មនុស្សណាម្នាក់ ឬក្រុមជំនុំណាមួយឡើយ ប៉ុន្តែអាស្រ័យទាំងស្រុងលើអ្នកនិពន្ធនៃព្រះគម្ពីរ ពោលគឺព្រះជាម្ចាស់ (ដែលជាសេចក្ដីពិតនោះឯង)។ ដូច្នេះ យើងគួរតែទទួលស្គាល់សិទ្ធិអំណាចនោះ ព្រោះព្រះគម្ពីរគឺជាព្រះបន្ទូលរបស់ព្រះជាម្ចាស់»។[៧]

## ព្រះជាម្ចាស់បានមានបន្ទូលតាមរយៈព្រះគម្ពីរ

ព្រះដ៏ជាព្រះវរបិតាបានជ្រើសរើសក្នុងការបើកសម្ដែងអង្គទ្រង់ផ្ទាល់។ ព្រះវរបិតាបើកសម្ដែងអង្គទ្រង់នៅក្នុងព្រះរាជបុត្រា។ ព្រះគ្រីស្ទត្រូវបានហៅថា «ព្រះបន្ទូល» ឬ «ព្រះបន្ទូលនៃជីវិត» (យ៉ូហាន ១:១, ១៤; ១យ៉ូហាន ១:១) ។ ក្នុងន័យម្យ៉ាង ព្រះគ្រីស្ទគឺជាភាសាដែលព្រះជាម្ចាស់ប្រើដើម្បីមានបន្ទូល។ កណ្ឌគម្ពីរហេព្រើរ ១:៣ ចែងថា «ទ្រង់ជារស្មីភ្លឺមកពីសិរីល្អនៃព្រះ ហើយជារូបភាពនៃអង្គទ្រង់»។ ព្រះរាជបុត្រាធ្វើឲ្យមនុស្សលោកស្គាល់ព្រះជាម្ចាស់ ហើយទ្រង់ធ្វើការ

៧ *Westminster Confession of Faith* ១.៤។



Scripture is supreme INDD interior - Khmer 1.9.indd 32 14/8/26 3:55 in the afternoon

នេះយ៉ាងល្អឥតខ្ចោះ។ ព្រះជាម្ចាស់បានបើកសម្ដែងអង្គទ្រង់តាមវិធីជាច្រើនដូចជា ក្នុងទេសភាពដ៏ស្រស់ស្អាត ក្នុងសេចក្ដីលម្អិតដ៏ស្មុគស្មាញនៃស្រទាប់ផ្កា ក្នុងព្រឹត្តិការណ៍អស្ចារ្យផ្សេងៗ ការថែរក្សា និងការផ្គត់ផ្គង់របស់ព្រះជាម្ចាស់ចំពោះជីវិតប្រចាំថ្ងៃ។ ប៉ុន្តែ វិធីដ៏សំខាន់បំផុតដែលព្រះជាម្ចាស់បានបើកសម្ដែងអង្គទ្រង់គឺនៅពេលដែលព្រះយេស៊ូវបានយកនិស្ស័យជាមនុស្ស។ នោះគឺនៅពេលដែល «ព្រះបន្ទូលក៏ត្រឡប់ជាសាច់ឈាម ហើយបានស្នាក់នៅជាមួយនឹងយើងរាល់គ្នា» (យ៉ូហាន ១:១៤) ។

យើងនឹងមើលមិនឃើញសេចក្ដីពិតទាំងអស់នេះទេ ប្រសិនបើយើងគ្មានព្រះវិញ្ញាណបរិសុទ្ធ។ ព្រះវិញ្ញាណជួយយើងឲ្យមើលឃើញអ្វីដែលព្រះជាម្ចាស់បានបើកសម្ដែងឲ្យយើងឃើញ ជាការបើកសម្ដែងមួយមកពីព្រះជាម្ចាស់។ បើមនុស្សមិនមានព្រះជាម្ចាស់ទេ នោះពួកគេ «បង្ខាំងសេចក្ដីពិត ដោយសេចក្ដីទុច្ចរិត» (រ៉ូម ១:១៨)។ ព្រះជាម្ចាស់បានបើកសម្ដែងអង្គទ្រង់ដល់យើង ប៉ុន្តែយើងបានព្រងើយកន្តើយនឹងទ្រង់វិញ។ យើងព្រងើយកន្តើយនឹងភស្តុតាង ដោយព្រោះយើងមិនចង់ទទួលយកផលវិបាក។ ឬយើងបង្វែររាជសាររបស់ព្រះជាម្ចាស់ឲ្យស្របតាមសេចក្ដីប៉ងប្រាថ្នា



Scripture is supreme INDD interior - Khmer 1.9.indd 33 14/8/26 3:55 in the afternoon

របស់យើងផ្ទាល់វិញ។ ដោយការធ្វើដូច្នេះ នោះយើងកំពុងបិទត្រចៀករបស់យើងហើយ។ ទោះបីជាព្រះយេស៊ូវបានក្លាយទៅជាមនុស្សក្ដី ក៏យើងមិនអាចយល់បាន យើងក៏នឹងមិនយល់ដែរ ប្រសិនបើព្រះវិញ្ញាណមិនបានជួយយើងឲ្យយល់ទេនោះ (យ៉ូហាន ៣:៣-៦; ២កូរិនថូស ៤:៦; ទីតុស ៣:៥-៦)។

ការបើកសម្ដែងរបស់ព្រះជាម្ចាស់អំពីអង្គទ្រង់ គឺមកពីព្រះវរបិតានៅក្នុងព្រះរាជបុត្រា តាមរយៈព្រះវិញ្ញាណ។ ដូច្នេះ តើព្រះគម្ពីរបង្រៀនពីការទាំងអស់នេះនៅត្រង់កន្លែងណា? ព្រះគម្ពីរគឺជាអំណោយទានពីព្រះជាម្ចាស់ដែលបានប្រទានមកតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ដើម្បីធានាបាននូវការពីរយ៉ាង៖

- *កំណត់ត្រា*ដ៏ត្រឹមត្រូវនៃការបើកសម្ដែងរបស់ព្រះជាម្ចាស់នៅក្នុងប្រវត្តិសាស្ត្រ ជាពិសេសការបើកសម្ដែងរបស់ទ្រង់នៅក្នុងការយកនិស្ស័យជាមនុស្សរបស់ព្រះយេស៊ូវ។
- *ការយល់ដឹង*ដ៏ត្រឹមត្រូវអំពីការបើកសម្ដែងរបស់ព្រះជាម្ចាស់នៅក្នុងប្រវត្តិសាស្ត្រ ជាពិសេសនៅពេលដែលព្រះជាម្ចាស់ត្រូវបានបើកសម្ដែងឲ្យឃើញនៅក្នុងការយកនិស្ស័យជាមនុស្សរបស់ព្រះយេស៊ូវ។



Scripture is supreme INDD interior - Khmer 1.9.indd 34 14/8/26 3:55 in the afternoon

ព្រះជាម្ចាស់បានបើកសម្តែងអង្គទ្រង់នៅក្នុងសាច់រឿងរបស់សាសន៍អ៊ីស្រាអែល ពាក្យទំនាយរបស់ពួកហោរា អំពីការយាងមករបស់ព្រះយេស៊ូវ និងទីបន្ទាល់របស់ពួកសាវ័ក។ ប៉ុន្តែ សូមស្រមៃមើលថា តើនឹងមានអ្វីកើតឡើងបើយើងមានភស្តុតាងតែប៉ុណ្ណឹង។ មកដល់ពេលនេះ យើងត្រូវពឹងផ្អែកលើការនិទានរឿងឡើងវិញនៃសាច់រឿងដែលនិទានឡើងវិញម្តងហើយម្តងទៀតៗ។ វានឹងប្រៀបដូចជាហ្គេមរបស់កុមារដែលគេខ្សឹបប្រាប់រឿងពីមនុស្សម្នាក់ទៅកាន់មនុស្សម្នាក់ទៀត ដោយហេតុការណ៍ពិតដើមដំបូងត្រូវគេបង្ខូចទ្រង់ទ្រាយបន្តិចម្តងៗរាល់ពេលដែលគេនិទានសាច់រឿងនោះឡើងវិញ។

ផ្ទុយទៅវិញ ព្រះជាម្ចាស់បានប្រទានឲ្យយើងនូវកំណត់ត្រាជាលាយលក្ខណ៍អក្សរច្បាស់លាស់អំពីអ្វីដែលបានកើតឡើង។ មួយវិញទៀត ព្រះអង្គបានធ្វើដូច្នេះដើម្បីបញ្ជាក់ថា សាក្សីដែលបានឃើញផ្ទាល់ភ្នែកនៅសម័យនោះបានសរសេរចុះនូវអ្វីដែលពួកគេបានមើលឃើញ។ នៅពេលដែលលោក ម៉ាថាយ ប្រាប់យើងថា ព្រះយេស៊ូវបានយាងនៅលើទឹក (ម៉ាថាយ ១៤:២២-៣៣) នោះយើងអាចជឿជាក់លើអ្វីដែលលោកបានលើកឡើងបាន ដោយព្រោះលោកនៅ



Scripture is supreme INDD interior - Khmer 1.9.indd 35 14/8/26 3:55 in the afternoon

កន្លែងនោះ ហើយនៅក្នុងទូកនោះផ្ទាល់។ ប៉ុន្តែ អ្វីដែលសំខាន់ជាងនេះទៅទៀតនោះ ព្រះវិញ្ញាណបរិសុទ្ធទ្រង់បានបញ្ជាក់ថា អ្វីដែលអ្នកសរសេរព្រះគម្ពីរបានសរសេរគឺត្រឹមត្រូវ ពោលគឺពិត ១០០%។

ព្រះវិញ្ញាណបរិសុទ្ធបានធ្វើការច្រើនជាងនេះទៅទៀត។ នៅពេលអ្នកសរសេរព្រះគម្ពីរបានគិតអំពីអ្វីដែលពួកគេបានឃើញ និងបានឮ នោះព្រះវិញ្ញាណបានជួយពួកគេឲ្យពន្យល់រឿងរ៉ាវទាំងនោះបានយ៉ាងត្រឹមត្រូវ។ ព្រះវិញ្ញាណបរិសុទ្ធបានធ្វើការ ខណៈពេលដែលអ្នកសរសេរព្រះគម្ពីរកំពុងតែសរសេរ ដើម្បីប្រាកដថា វាគឺជាការបើកសម្ដែងដ៏ត្រឹមត្រូវមកពីព្រះជាម្ចាស់។ នោះហើយជាមូលហេតុដែលយើងនិយាយថា ព្រះជាម្ចាស់បាន*បណ្ដាលឲ្យតែង*ព្រះគម្ពីរឡើង។ នេះមិនដូចជាប្រភពនៃការលើកទឹកចិត្ត ដែលជំរុញចិត្តដល់សិល្បករណាមួយនោះទេ។ ព្រះគម្ពីរគឺជាព្រះទ្រង់បណ្ដាលឲ្យតែងក្នុងន័យត្រង់ថា ព្រះគម្ពីរគឺចេញពីព្រះឱស្ឋរបស់ព្រះជាម្ចាស់ដោយផ្ទាល់ (២ធីម៉ូថេ ៣:១៦)។ សាវ័ក ពេត្រុស មានប្រសាសន៍ដូច្នេះថា៖ «ដ្បិតសេចក្ដីទំនាយមិនដែលមក ដោយបំណងចិត្តមនុស្សទេ គឺជាមនុស្សបរិសុទ្ធរបស់ព្រះ ដែលបានទាយ ដោយ



Scripture is supreme INDD interior - Khmer 1.9.indd 36 14/8/26 3:55 in the afternoon

សារព្រះវិញ្ញាណបរិសុទ្ធទ្រង់បណ្ដាលវិញ» (២ពេត្រុស ១:២១)។

មកដល់ពេលនេះ យើងគួរតែច្បាស់ហើយថា សិទ្ធអំណាចកំពូល ភាពសំខាន់អាចជឿជាក់បាន និងការបណ្ដាលឲ្យតែងនៃព្រះគម្ពីរគឺមានការទាក់ទងគ្នាទាំងអស់ ដូចជាតំណភ្ជាប់នៅក្នុងខ្សែច្រវាក់ ឬដូចជាធ្លុងនៃខ្សែពួរ (សូមមើល សាស្ដា ៤:១២)។[៨] ព្រះគម្ពីរគឺសំខាន់បំផុត ពីព្រោះយើងអាចជឿជាក់លើព្រះគម្ពីរបានទាំងស្រុង ហើយយើងអាចជឿជាក់លើព្រះគម្ពីរបានទាំងស្រុង ដោយសារព្រះជាម្ចាស់អង្គទ្រង់ផ្ទាល់បានបណ្ដាលឲ្យមានការតែងព្រះគម្ពីរឡើង។ ព្រះជាម្ចាស់បានធ្វើការតាមរយៈមនុស្សដើម្បីធ្វើឲ្យប្រាកដថា ព្រះគម្ពីរគឺត្រឹមត្រូវទាំងស្រុង។

## សិទ្ធិអំណាចកំពូលមានលក្ខណៈបុគ្គល

ព្រះគម្ពីរជាសិទ្ធិអំណាចកំពូល ក៏ប៉ះពាល់យើងផ្ទាល់ដែរ ព្រោះយើងឮព្រះសូរសៀងរបស់ព្រះជាម្ចាស់

---

៨ សូមអានសៀវភៅ *Scripture Is Inspired,* និពន្ធដោយ៖ លោក Steffen Jenkins, និងសៀវភៅ *Scripture Is Trustworthy,* និពន្ធដោយ៖ លោក Robert Yarbrough—មានសៀវភៅជាស៊េរីសំខាន់ៗ ពីរភាគផ្សេងទៀតផងដែរ។



Scripture is supreme INDD interior - Khmer 1.9.indd 37 14/8/26 3:55 in the afternoon

តាមរយៈព្រះគម្ពីរ។ យើងទទួលស្គាល់ថា ព្រះគម្ពីរជាសិទ្ធិអំណាចកំពូលដោយព្រោះយើងអាចសម្គាល់បានថា ព្រះជាម្ចាស់ជាសិទ្ធិអំណាចកំពូលរបស់យើង។ តាមរយៈការចុះចូលចំពោះព្រះគម្ពីរ នោះយើងកំពុងតែចុះចូលចំពោះព្រះជាម្ចាស់។ លោក ហឺម៉ែន បាវីក (Herman Bavinck) មានប្រសាសន៍ថា យើងមានភាពត្រឹមត្រូវក្នុងការគោរពនូវគំនិតដែលសរសេរឡើងដោយអ្នកជំនាញ ពីព្រោះពួកគេមានចំណេះដឹងច្រើនជាងយើងលើប្រធានបទជំនាញរបស់ពួកគេ។ ប៉ុន្តែយើងនៅតែអាចជជែកដេញដោលប្រឆាំងនឹងគំនិតរបស់ពួកគេបាន។ «អ្នកជំនាញខ្លះមានភាពល្បីល្បាញនិងពូកែ ប៉ុន្តែគំនិតរបស់ពួកគេមានតម្លៃស្មើត្រឹមសមត្ថភាពក្នុងការផ្តល់អំណះអំណាងគាំទ្រគំនិតរបស់ខ្លួនតែប៉ុណ្ណោះ»។[៩] នៅទីបំផុត សិទ្ធិអំណាចរបស់អ្នកជំនាញអាស្រ័យទៅលើអំណាចនៃការជជែកវែកញែករកហេតុផល និងភស្តុតាងរបស់ពួកគេតែប៉ុណ្ណោះ។

ប៉ុន្តែ សិទ្ធិអំណាចរបស់ព្រះជាម្ចាស់ គឺខុសគ្នាឆ្ងាយពីប្រភេទនៃសិទ្ធិអំណាចផ្សេងៗទៀត។ សិទ្ធិអំណាចរបស់ព្រះជាម្ចាស់ គឺជាសិទ្ធិអំណាចក្នុងនាមជាព្រះអាទិករលើអ្វីៗដែលទ្រង់បានបង្កើត។ ព្រះជាម្ចាស់

៩ លោក Bavinck, *Reformed Dogmatics, ភាគ១*, ទំព័រ៤៦៤។



Scripture is supreme INDD interior - Khmer 1.9.indd 38 14/8/26 3:55 in the afternoon

មានសិទ្ធិ «ដើម្បីទាមទារឲ្យមានការស្ដាប់បង្គាប់ដោយគ្មានលក្ខខណ្ឌ» ដោយព្រោះ «សិទ្ធិអំណាចរបស់ទ្រង់មកពីអង្គទ្រង់ផ្ទាល់មិនមែនមកពី «ហេតុផលផ្សេងៗ» នោះទេ»។ វាជាការពិតដែលសេចក្ដីបង្គាប់របស់ព្រះជាម្ចាស់មិនមែនមានដោយចៃដន្យដូច្នេះទេ។ ដូច្នេះយើងអាចសិក្សាពីសេចក្ដីបង្គាប់ទាំងនោះបាន ហើយពេលខ្លះយើងក៏អាចពន្យល់ពីសេចក្ដីបង្គាប់ទាំងនោះបានផងដែរ។ ប៉ុន្តែ សិទ្ធិអំណាចរបស់ព្រះជាម្ចាស់មិនអាស្រ័យលើអំណាចនៃការជជែកវែកញែករកហេតុផលណាមួយឡើយ។ សេចក្ដីបង្គាប់របស់ទ្រង់អាស្រ័យលើសិទ្ធិអំណាចរបស់ព្រះអង្គដែលថា ទ្រង់ជានរណា។ យើងមិនអាចបង្កើនសិទ្ធិអំណាចនៃសេចក្ដីបង្គាប់របស់ព្រះ នៅពេលយើងព្យាយាមពន្យល់អំពីមូលហេតុដែលព្រះជាម្ចាស់បានបង្គាប់វាមកនោះទេ។ ផ្ទុយទៅវិញ «កាលណាព្រះជាម្ចាស់មានព្រះបន្ទូល នោះការសង្ស័យទាំងអស់ត្រូវតែបញ្ឈប់»។[១០]

ជាក់ស្ដែង ពេលយើងនិយាយអំពីសិទ្ធិអំណាចកំពូលនៃព្រះគម្ពីរ យើងសំដៅទៅលើអ្វីស៊ីជម្រៅជាងនេះទៅទៀត។ ការនិយាយថា «ព្រះគម្ពីរគឺជាសិទ្ធិ

---

១០ លោក Bavinck, *Reformed Dogmatics, ភាគ១*, ទំព័រ៤៦៤។



Scripture is supreme INDD interior - Khmer 1.9.indd 39 14/8/26 3:55 in the afternoon

អំណាចកំពូល» គឺជាវិធីខ្លីមួយនៃការនិយាយថា៖ «ព្រះជាម្ចាស់គឺមានសិទ្ធិអំណាចកំពូល ហើយព្រះជាម្ចាស់មានព្រះបន្ទូលតាមរយៈព្រះគម្ពីរ»។ ឬយើងអាចនិយាយថា៖ «សិទ្ធិអំណាចរបស់*ព្រះជាម្ចាស់គឺកំពូល ហើយសិទ្ធិអំណាចកំពូលរបស់ព្រះជាម្ចាស់បានសម្ដែងចេញនៅក្នុងព្រះគម្ពីរ*»។ ព្រះគម្ពីរគឺមានសិទ្ធិអំណាចកំពូល ដោយសារព្រះជាម្ចាស់មានសិទ្ធិអំណាចកំពូល និងដោយសារតែព្រះជាម្ចាស់មានព្រះបន្ទូលនៅក្នុងព្រះគម្ពីរ។ ពេលខ្លះ យើងនិយាយអំពីការគោរពតាមអ្វីដែលព្រះគម្ពីរបានចែង។ នោះគឺជាសេចក្ដីសង្ខេបដែលអាចទទួលយកបាន និងមានប្រយោជន៍បំផុតនៃសេចក្ដីជំនឿយើង។ ប៉ុន្តែ វាគ្រាន់តែជាការសង្ខេបប៉ុណ្ណោះ។ អ្វីដែលយើងពិតជាចង់បញ្ជាក់នោះគឺថា យើងកំពុងគោរពតាមអ្វីដែល*ព្រះជាម្ចាស់*មានបន្ទូលក្នុងព្រះគម្ពីរ។

នេះមានន័យថា នៅពេលដែលយើងលើកទឹកចិត្តមនុស្សឲ្យជឿ ឬធ្វើតាមព្រះគម្ពីរ នោះយើងមិនបានជំរុញឲ្យមានការស្ដាប់បង្គាប់ទៅនឹងច្បាប់ដែលមិនមានលក្ខណៈជាបុគ្គលមួយចំនួននោះទេ។ ផ្ទុយទៅវិញ យើងកំពុងលើកកម្ពស់ការស្ដាប់បង្គាប់តាមគ្រប់ទាំងព្រះបន្ទូលវិញ។ សិទ្ធិអំណាចកំពូលនៃព្រះគម្ពីរ



Scripture is supreme INDD interior - Khmer 1.9.indd 40 14/8/26 3:55 in the afternoon

មានលក្ខណៈជាបុគ្គល។ ពិតណាស់ ក្នុងទិដ្ឋភាពខ្លះ ព្រះគម្ពីរបានបង្ហាញយើងពីលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់។ ព្រះគម្ពីរមិនមែនជាព្រះជាម្ចាស់ទេ ហើយក៏មិនមែនជាផ្នែកនៃព្រះជាម្ចាស់ដែរ ប៉ុន្តែព្រះគម្ពីរគឺជាព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ព្រះគម្ពីរ គឺជាការបើកសម្តែងពីអង្គព្រះជាម្ចាស់ ដោយអង្គទ្រង់ផ្ទាល់។

ជាធម្មតា យើងមិនបំបែកបុគ្គលណាម្នាក់ចេញពីពាក្យសម្តីរបស់គាត់នោះទេ។ វាជារឿងចម្លែកក្នុងការនិយាយថា «គាត់ជាមនុស្សទៀងត្រង់ ប៉ុន្តែខ្ញុំមិនជឿលើអ្វីដែលគាត់និយាយនោះទេ»។ បើបុគ្គលណាម្នាក់ប្រព្រឹត្តិមិនស្របតាមពាក្យសម្តីរបស់គាត់ទេ នោះយើងហៅគាត់ថាជាមនុស្សលាក់ពុត។ ទំនាក់ទំនងនេះរវាងចរិតលក្ខណៈរបស់បុគ្គលម្នាក់ និងអ្វីដែលគាត់និយាយកើតមានពីព្រោះមនុស្សប្រើពាក្យសម្តី ដើម្បីបើកសម្តែង និងបង្ហាញថា ពួកគេជានរណា។ ព្រះជាម្ចាស់ក៏បើកបង្ហាញតាមរបៀបដូចគ្នានេះផងដែរ។ យើងអាចស្គាល់អំពីលក្ខណសម្បត្តិព្រះជាម្ចាស់ តាមរយៈអ្វីដែលទ្រង់មានព្រះបន្ទូល។ ហើយអ្វីដែលព្រះជាម្ចាស់មានបន្ទូលបង្ហាញយើងថាព្រះជាម្ចាស់មានលក្ខណៈយ៉ាងណា។ ព្រះអង្គមិនមែនជាព្រះដែលលាក់ពុតនោះទេ។ ដូច្នេះ យើងទុកចិត្តព្រះជាម្ចាស់ ហើយយើងក៏ទុកចិត្ត



Scripture is supreme INDD interior - Khmer 1.9.indd 41 14/8/26 3:55 in the afternoon

លើព្រះបន្ទូលរបស់ទ្រង់ផងដែរ។ យើងទទួលស្គាល់សិទ្ធិអំណាចកំពូលនៃព្រះគម្ពីរ ដោយសារយើងទទួលស្គាល់សិទ្ធិអំណាចកំពូលនៃអ្នកនិពន្ធរបស់ព្រះគម្ពីរ ពោលគឺព្រះជាម្ចាស់នោះឯង។ អ្នកកំណែទម្រង់ម្នាក់ឈ្មោះលោក ចន ខិលវិន (John Calvin ឆ្នាំ១៥០៩-១៥៦៤ នៃគ.ស.) មានប្រសាសន៍ថា «យើងគួរតែកោតខ្លាចដល់ព្រះបន្ទូលដូចដែលយើងកោតខ្លាចដល់ព្រះជាម្ចាស់ផងដែរ ពីព្រោះព្រះទ្រង់បណ្ដាលឲ្យតែងព្រះគម្ពីរមក»។[១១]

បន្ទាប់ពីព្រះគ្រីស្ទមានព្រះជន្មរស់ពីសុគត ទ្រង់បានមានព្រះបន្ទូលថា «គ្រប់ទាំងអំណាចបានប្រគល់មកខ្ញុំនៅលើស្ថានសួគ៌ ហើយលើផែនដីផង» (ម៉ាថាយ ២៨:១៨)។ ព្រះគម្ពីរផ្ទាល់បានផ្ដល់សិទ្ធិអំណាចកំពូលដល់ព្រះគ្រីស្ទ។ ព្រះគ្រីស្ទ «ជាសិរសារបស់រូបកាយគឺជាពួកជំនុំ ទ្រង់ជាដើម ក៏បានរស់ពី

---

១១ លោក John Calvin, *Calvin's Commentaries: The Second Epistle of Paul the Apostle to the Corinthians and the Epistles to Timothy, Titus, and Philemon*, កែសម្រួលដោយ៖ លោក David W. Torrance និងលោក Thomas F. Torrance, បកប្រែដោយ៖ លោក T. A. Smail (Edinburgh: Oliver and Boyd, ឆ្នាំ១៩៦៤), អត្ថាធិប្បាយស្ដីពី៖ ២ធីម៉ូថេ ៣:១៦, ទំព័រ៣៣០។



Scripture is supreme INDD interior - Khmer 1.9.indd 42 14/8/26 3:55 in the afternoon

ស្លាប់ឡើងវិញមុនគេបង្អស់ ដើម្បីឲ្យទ្រង់បានជាប្រធានក្នុងគ្រប់ទាំងអស់» (កូឡុស ១:១៨)។ ដូច្នេះ តើយើងអាចនិយាយថា ព្រះគម្ពីរមានសិទ្ធិអំណាចកំពូលយ៉ាងដូចម្ដេចបាន បើសិទ្ធិអំណាចទាំងអស់ជារបស់ផងព្រះគ្រីស្ទ ហើយព្រះគ្រីស្ទតែមួយអង្គប៉ុណ្ណោះ គឺជាប្រធានក្នុងគ្រប់ទាំងអស់នោះ?

ចម្លើយគឺថា ព្រះគ្រីស្ទបានប្រទានសិទ្ធិអំណាចដល់ពួកសាវ័ក ហើយទ្រង់បានធ្វើដូច្នេះដើម្បីប្រាកដថា សិទ្ធិអំណាចទ្រង់នឹងស្ថិតនៅជាអចិន្ត្រៃយ៍នៅក្នុងបទគម្ពីរ។ ទេវវិទូម្នាក់ឈ្មោះលោក ខេវីន វ៉ានហ៊ូហ្សឺរ (Kevin Vanhoozer) បានលើកឡើងថា «ពួកសាវ័កគឺជាអ្នកកាត់ស្រាយដែលទទួលបានសិទ្ធិក្នុងការពន្យល់អំពីបុគ្គលភាព និងកិច្ចការរបស់ព្រះយេស៊ូវ។ ពួកសាវ័កជាអ្នកកត់ត្រាពីដំណើរជីវិតព្រះគ្រីស្ទ។ ការតាក់តែងនិពន្ធរបស់ពួកគេ គឺជាផ្នែកមួយពន្យល់អំពីព្រះត្រៃឯក។ ក្រុមជំនុំទទួលបានការអនុញ្ញាតពីព្រះជាម្ចាស់តែនៅក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ (និងជាអចិន្ត្រៃយ៍) ពីព្រះគម្ពីរប៉ុណ្ណោះ»។[១២]

១២ លោក Kevin J. Vanhoozer, *Biblical Authority After Babel: Retrieving the Solas in the Spirit of Mere Protestant Christianity* (Grand Rapids, MI: Brazos, ឆ្នាំ២០១៦), ទំព័រ៩១, ១០៩។



Scripture is supreme INDD interior - Khmer 1.9.indd 43 14/8/26 3:55 in the afternoon

មានអ្នកខ្លះប្រើសិទ្ធិអំណាចរបស់ព្រះគ្រីស្ទ ដើម្បីគ្រប់គ្រងលើសិទ្ធិអំណាចរបស់ព្រះគម្ពីរ។ ដោយពួកគេជ្រើសរើសផ្នែកខ្លះរបស់ព្រះគម្ពីរ ហើយប្រើព្រះបន្ទូលទុកដូចជាសេចក្ដីណែនាំប៉ុណ្ណោះ។ នោះអាចចោទជាសំណួរថា៖ តើយើងកំពុងតែដើរតាមព្រះគ្រីស្ទមួយណា? តើជាព្រះគ្រីស្ទដែលស្ថិតនៅក្នុងការយល់ដឹងរបស់អ្នក ឬក៏ជាព្រះគ្រីស្ទរបស់ខ្ញុំ?

ដំណឹងល្អគឺថា ព្រះគ្រីស្ទអង្គទ្រង់ផ្ទាល់បានរារាំងភាពច្របូកច្របល់នេះ។ ព្រះអង្គបានជ្រើសរើសពួកសាវ័កដើម្បីផ្ដល់ឲ្យសក្ខីភាពដ៏ត្រឹមត្រូវ និងការពន្យល់ដល់យើងឆ្លើយតបទៅកាន់សំណួរដែលថា តើព្រះអង្គជានរណា ហើយព្រះអង្គបានធ្វើអ្វីខ្លះ? (យ៉ូហាន ១៤:២៥-២៦; ១៥:២៦-២៧; ១៦:១៣-១៥) ។ ព្រះគ្រីស្ទពិត គឺជាព្រះគ្រីស្ទដែលយើងឃើញតាមរយៈព្រះគម្ពីរ។ ដូច្នេះ សិទ្ធិអំណាចកំពូលនៃព្រះគ្រីស្ទបានក្លាយជាសិទ្ធិអំណាចកំពូលនៃព្រះគម្ពីរ។

សូមស្រមៃមួយភ្លែតថា មានបុគ្គលម្នាក់ដែលមានអំណាចគ្រប់បែបយ៉ាង ដែលបានបង្កើតអ្វីៗគ្រប់យ៉ាង ហើយបុគ្គលនោះចង់និយាយមកកាន់មនុស្សយើងនេះ។ តើលោកអ្នកគិតថា បុគ្គលនោះអាចធ្វើបានទេ? ប្រាកដណាស់ បុគ្គលនោះអាចធ្វើបាន។ ដោយសារ



Scripture is supreme INDD interior - Khmer 1.9.indd 44 14/8/26 3:55 in the afternoon

តែបុគ្គលនោះមានអំណាចគ្រប់យ៉ាង។ គាត់អាចធ្វើអ្វីក៏បានដែរ។ ហើយតើលោកអ្នកគិតថា បុគ្គលបែបនេះនឹងធ្វើបានល្អឬទេ? ពិតណាស់ គាត់នឹងធ្វើបានល្អ។ គាត់អាចធ្វើអ្វីដែលគាត់ចង់ធ្វើ តាមរបៀបណាដែលគាត់ចង់ធ្វើ។

នេះគឺជាព្រះដ៏ជាអម្ចាស់នៃយើង៖ ព្រះអង្គដែលមានគ្រប់ទាំងអំណាច ហើយដោយសេចក្ដីស្រឡាញ់ ព្រះអង្គគាប់ព្រះទ័យចង់មានការប្រាស្រ័យទាក់ទងជាមួយនឹងមនុស្សជាតិ។ ហើយព្រះជាម្ចាស់បានប្រាស្រ័យទាក់ទងជាមួយនឹងយើងយ៉ាងល្អឥតខ្ចោះ។ ដូច្នេះ ការជឿលើព្រះដ៏ពេញដោយសេចក្ដីស្រឡាញ់ មានន័យថាការជឿលើសិទ្ធិអំណាចកំពូលនៃព្រះគម្ពីរ។ ព្រះជាម្ចាស់បានជ្រើសរើសបើកសម្ដែងអង្គទ្រង់តាមរយៈព្រះគម្ពីរ ហើយនៅពេលដែលព្រះអង្គបំពេញកិច្ចការអ្វីមួយ ទ្រង់ធ្វើបានយ៉ាងល្អឥតខ្ចោះ។

## ការចុះចូលគឺមានលក្ខណៈជាបុគ្គល

មានអត្ថន័យសំខាន់ៗមួយចំនួន ដែលយើងគប្បីយល់អំពីទំនាក់ទំនងរវាងសិទ្ធិអំណាចកំពូលនៃព្រះជាម្ចាស់ និងសិទ្ធិអំណាចកំពូលនៃព្រះគម្ពីរ។



Scripture is supreme INDD interior - Khmer 1.9.indd 45 14/8/26 3:55 in the afternoon

ទីមួយ យើងមិនថ្វាយបង្គំព្រះគម្ពីរនោះទេ។ យើងស្រឡាញ់ព្រះគម្ពីរ។ យើងគោរពឲ្យតម្លៃព្រះគម្ពីរ។ យើងស្ដាប់បង្គាប់តាមអ្វីដែលមានចែងនៅក្នុងព្រះគម្ពីរ។ យើងជឿជាក់លើព្រះគម្ពីរ។ ប៉ុន្តែយើងមិនថ្វាយបង្គំព្រះគម្ពីរនោះទេ។

ពេលខ្លះ គេចោទគ្រីស្ទបរិស័ទមួយចំនួនថា «ការថ្វាយបង្គំព្រះគម្ពីរ» (Bibliolatry)។ ការថ្វាយបង្គំព្រះគម្ពីរ គឺជាការយកព្រះគម្ពីរជារូបព្រះ ដើម្បីថ្វាយបង្គំ។ «ការថ្វាយបង្គំព្រះគម្ពីរ» មានន័យថា ការគោរពឲ្យតម្លៃរបស់លោកអ្នកចំពោះព្រះគម្ពីរ បានប្រែក្លាយទៅជាការថ្វាយបង្គំព្រះគម្ពីរទៅវិញ។ មានពេលមួយនោះ ខ្ញុំបានឮថា មានមនុស្សម្នាក់បានអធិស្ឋានអស់រយៈពេលដ៏យូរ ហើយគាត់បានអរព្រះគុណដល់ព្រះជាម្ចាស់ចំពោះការយកចិត្តទុកដាក់របស់ទ្រង់ ក្នុងនាមជាព្រះវរបិតា ដែលព្រះអង្គបានចាត់ព្រះយេស៊ូវឲ្យយាងមកលើផែនដី ហើយបានប្រទានព្រះគម្ពីរដល់យើង។ មិនមានអ្វីខុសឆ្គងជាមួយនឹងអ្វីដែលបុគ្គលនេះបាននិយាយនោះទេ ប៉ុន្តែស្ដាប់គាត់ទៅហាក់ដូចជាកំពុងអធិស្ឋានដល់ «ព្រះត្រៃឯក» ដែលមានព្រះវរបិតា ព្រះរាជបុត្រា និងព្រះគម្ពីរ។ នេះមិនមែនជាអ្វីដែលព្រះគម្ពីរបានបង្រៀនអំពីសារៈសំខាន់នៃព្រះគម្ពីរនោះទេ។



Scripture is supreme INDD interior - Khmer 1.9.indd 46 14/8/26 3:55 in the afternoon

ប៉ុន្តែ ដើម្បីកាត់បន្ថយគ្រោះថ្នាក់នៃការថ្វាយបង្គំព្រះគម្ពីរ យើងមិនត្រូវបន្ថយការគោរព ផ្តល់តម្លៃចំពោះព្រះគម្ពីរឡើយ។ ផ្ទុយទៅវិញ យើងត្រូវតែមើលទៅកាន់ព្រះគម្ពីរថាជាព្រះសូរសៀងរបស់ព្រះជាម្ចាស់។ លោកអ្នកមិនត្រូវក្រាបថ្វាយបង្គំដល់អ្នកនាំរាជសារឡើយ ប៉ុន្តែលោកអ្នកត្រូវក្រាបថ្វាយបង្គំដល់ស្តេចវិញ។ លោកអ្នកមិនត្រូវថ្វាយបង្គំព្រះគម្ពីរនោះទេ ប៉ុន្តែលោកអ្នកត្រូវថ្វាយបង្គំព្រះជាម្ចាស់វិញ។

ទីពីរ សិទ្ធិអំណាចកំពូលនៃព្រះជាម្ចាស់គឺជាមូលដ្ឋានគ្រឹះសម្រាប់សិទ្ធិអំណាចកំពូលនៃព្រះគម្ពីរ។ គំនិតទាំងពីរនេះគឺទាក់ទងគ្នា។ គ្រីស្ទបរិស័ទសេរីនិយមជាច្រើនឯកភាពលើសិទ្ធិអំណាចកំពូលរបស់ព្រះជាម្ចាស់ ប៉ុន្តែពួកគេសង្ស័យលើសិទ្ធិអំណាចកំពូលនៃព្រះគម្ពីរ។ ពួកគេយល់ថា ព្រះគម្ពីរគ្រាន់តែជាមធ្យោបាយមួយ ដែលព្រះជាម្ចាស់អាចនឹងមានព្រះបន្ទូលមកកាន់យើងប៉ុណ្ណោះ ប៉ុន្តែមិនមែនជាសិទ្ធិអំណាចកំពូលនោះទេ។ លើសពីនេះទៅទៀត គ្រីស្ទបរិស័ទខាងរ៉ូម៉ាំងកាតូលិក ពួកគេពិតជាទទួលយកសិទ្ធិអំណាចកំពូលរបស់ព្រះជាម្ចាស់ ប៉ុន្តែពួកគេមិនបានយល់ថា ព្រះគម្ពីរជាសិទ្ធិអំណាចកំពូលនោះទេ។ ផ្ទុយទៅវិញ ពួកគេចាត់ទុកព្រះគម្ពីរថា មាន



Scripture is supreme INDD interior - Khmer 1.9.indd 47 14/8/26 3:55 in the afternoon

តម្លៃស្មើនឹងទំនៀមទម្លាប់ និងប្រភពនៃសិទ្ធិអំណាចផ្សេងៗទៀតរបស់ពួកគេទៅវិញ។ ប៉ុន្តែ ព្រះគម្ពីរគឺជាមធ្យោបាយមួយដែលយើងស្តាប់ឮព្រះសូរសៀងរបស់ព្រះជាម្ចាស់។ ព្រះគម្ពីរគឺជាទីដែលព្រះជាម្ចាស់បានជ្រើសរើសបើកសម្ដែងសិទ្ធិអំណាចទ្រង់។ យើងមិនអាចនិយាយថា «ខ្ញុំគោរព ឲ្យតម្លៃដល់សិទ្ធិអំណាចរដ្ឋាភិបាល ប៉ុន្តែខ្ញុំមិនអើពើនឹងច្បាប់របស់រដ្ឋាភិបាលឡើយ»។ សិទ្ធិអំណាចរបស់រដ្ឋាភិបាល បានបង្ហាញឲ្យឃើញតាមរយៈមាត្រាច្បាប់ផ្សេងៗ ដូច្នេះយើងបង្ហាញការគោរពចំពោះរដ្ឋាភិបាល ដោយការគោរពតាមមាត្រាច្បាប់ទាំងនោះ។ យើងក៏ត្រូវអនុវត្តដូចគ្នាចំពោះព្រះគម្ពីរផងដែរ។ សិទ្ធិអំណាចរបស់ព្រះជាម្ចាស់បានបង្ហាញឲ្យឃើញនៅក្នុងព្រះបន្ទូលទ្រង់ ហើយការចុះចូលចំពោះព្រះជាម្ចាស់បានបង្ហាញឲ្យឃើញតាមរយៈការស្តាប់បង្គាប់តាមព្រះបន្ទូល។

ជាថ្មីម្តងទៀត លោកអ្នកមិនត្រូវក្រាបថ្វាយបង្គំចំពោះអ្នកនាំរាជសារឡើយ ប៉ុន្តែលោកអ្នកត្រូវថ្វាយបង្គំស្តេចដែលបានចាត់ឲ្យគាត់មកវិញ។ ហើយលោកអ្នកក៏មិនត្រូវព្រងើយកន្តើយនឹងអ្នកនាំរាជសារផងដែរ។ លោកអ្នកត្រូវធ្វើផ្ទុយពីនេះ។ លោកអ្នកត្រូវចុះចូលនឹងអ្វីដែលអ្នកនាំរាជសារបានថ្លែង ព្រោះគាត់



Scripture is supreme INDD interior - Khmer 1.9.indd 48 14/8/26 3:55 in the afternoon

បានប្រកាសរាជសារជំនួសស្ដេច។ លោកអ្នកមិនត្រូវនិយាយថា៖ «ខ្ញុំនឹងគោរពដល់មហាក្សត្រ ប៉ុន្ដែខ្ញុំនឹងសម្រេចធ្វើអ្វីដែលខ្ញុំចង់ធ្វើវិញ» បានឡើយ។ ទេ! មិនមែនបែបដូច្នេះទេ ស្ដេចទ្រង់សម្រេចអស់ទាំងអ្វីៗដែលព្រះអង្គសព្វព្រះទ័យចង់ធ្វើ និងរបៀបដែលព្រះអង្គមានបន្ទូលទៅកាន់អ្នកបម្រើទ្រង់អំពីព្រះទ័យទ្រង់។ ក្នុងករណីនេះ ព្រះអង្គមានបន្ទូលមកយើងតាមរយៈអ្នកនាំរាជសាររបស់ទ្រង់។ លោកអ្នកត្រូវមានភក្ដីភាពចំពោះស្ដេច ចំពោះពាក្យពេចន៍របស់អ្នកនាំរាជសាររបស់ទ្រង់ផងដែរ។

ដូចគ្នានេះដែរ យើងមិនអាចនិយាយថា យើងចុះចូលចំពោះព្រះជាម្ចាស់ ប៉ុន្ដែយើងនៅតែបន្តសម្រេចចិត្តតាមតែអំពើចិត្តគំនិតផ្ទាល់របស់យើងនោះទេ។ តើលោកអ្នកកំពុងតែចង់មានន័យយ៉ាងណា ចំពោះទង្វើបែបដូចនេះ? ព្រះជាម្ចាស់ទ្រង់ជាអង្គសម្រេចគ្រប់អ្វីដែលព្រះអង្គសព្វព្រះទ័យ ហើយព្រះជាម្ចាស់ក៏សម្រេចលើរបៀបដែលព្រះអង្គនឹងបង្ហាញឲ្យយើងឃើញពីព្រះទ័យរបស់ទ្រង់ផងដែរ។ វាមិនអាចទៅរួចទេ ដូចដែលមនុស្សខ្លះយល់ថា ព្រះគម្ពីរជាសិទ្ធិអំណាចកំពូល ហើយមនុស្សខ្លះទៀតបែរជាបដិសេធទៅវិញ។ ព្រះជាម្ចាស់ទេតើ ដែលជាអង្គដែលសម្រេចការទាំងនោះ



Scripture is supreme INDD interior - Khmer 1.9.indd 49 14/8/26 3:55 in the afternoon

វិញ។ *ព្រះជាម្ចាស់*បានជ្រើសរើសបើកសម្ដែងអង្គទ្រង់តាមរយៈព្រះគ្រីស្ទ ហើយប្រទានការបើកសម្ដែងនោះតាមរយៈព្រះគម្ពីរ។ នេះជាមូលហេតុដែលយើងធ្វើតាមព្រះគម្ពីរ ហើយទទួលយកព្រះគម្ពីរជាសិទ្ធិអំណាចកំពូលរបស់យើង។

ចូរយើងត្រឡប់ទៅនិយាយអំពីកម្មវិធីផែនទីហ្គូហ្គលម្ដងទៀត។ កម្មវិធីផែនទីហ្គូហ្គលនឹងបង្ហាញលោកអ្នកពីទិសដៅ ហើយលើសពីនេះវាផ្ដល់ឲ្យលោកអ្នកនូវការណែនាំជាសម្លេងនៅពេលដែលលោកអ្នកធ្វើដំណើរ។ លោកអ្នកអាចឮសម្លេងដែលបង្កើតដោយកុំព្យូទ័រ។ នេះជាការថតសម្លេងរបស់មនុស្សពិត ប៉ុន្តែវាមិនមែនជាមនុស្សពិតនោះទេ។ វាគ្រាន់តែជាឯកសារជាសម្លេងដែលកម្មវិធីទូរស័ព្ទដាក់បញ្ចូលគ្នាប៉ុណ្ណោះ។

ព្រះគម្ពីរអាចនឹងខុសប្លែកពីកម្មវិធីផែនទីហ្គូហ្គលពីព្រោះយើងមិនបានឮសម្លេងកុំព្យូទ័រចេញពីទំព័រនៃព្រះគម្ពីរនោះទេ (លុះត្រាតែយើងស្ដាប់ព្រះគម្ពីរជាសម្លេង)។ ប៉ុន្តែ ការប្រាស្រ័យទាក់ទងរបស់យើងជាមួយនឹងព្រះគម្ពីរពិតជាមានលក្ខណៈជាបុគ្គលច្រើនជាង។ យើងឮសម្លេងកម្មវិធីផែនទីហ្គូហ្គលតាមរយៈកុំព្យូទ័រ ប៉ុន្តែយើងមិនឮសម្លេងមនុស្សពិតប្រាកដនោះទេ។ យើងប្រហែលជាមិនឮសម្លេងព្រះគម្ពីរតាមរយៈ



Scripture is supreme INDD interior - Khmer 1.9.indd 50 14/8/26 3:55 in the afternoon

កុំព្យូទ័រទេ ប៉ុន្តែយើងឮសម្លេងបុគ្គលម្នាក់យ៉ាងពិតប្រាកដវិញ។ តាមរយៈព្រះវិញ្ញាណបរិសុទ្ធ ព្រះជាម្ចាស់មានព្រះបន្ទូល ទាំងនៅពេលដែលយើងអាន និងអធិប្បាយព្រះបន្ទូលចេញពីព្រះគម្ពីរនោះ។ ព្រះគម្ពីរ គឺជាសិទ្ធិអំណាចកំពូលរបស់យើង ពីព្រោះព្រះគម្ពីរជាព្រះសូរសៀងរបស់ព្រះជាម្ចាស់។

នេះជាមូលហេតុដែលគុណតម្លៃកំពូលនៃព្រះគម្ពីរគឺជាដំណឹងល្អ។ ការអនុវត្តតាមអត្ថបទគម្ពីរដ៏គួរឲ្យធុញទ្រាន់គឺមិនមែនជារឿងគួរឲ្យរីករាយនោះទេ។ ស្រដៀងគ្នានេះដែរ ច្បាប់កីឡាបាល់ទាត់មានសារៈសំខាន់សម្រាប់ការប្រកួត ប៉ុន្តែកីឡាករមិនបានអានច្បាប់នោះ ដោយភាពសប្បាយរីករាយនោះទេ។ ច្បាប់មិនផ្តល់ឲ្យមានជីវិតនោះទេ។ ប៉ុន្តែ ព្រះគម្ពីរមិនគ្រាន់តែជាច្បាប់ ដែលយើងត្រូវតែស្តាប់បង្គាប់តាមនោះទេ។ សិទ្ធិអំណាចរបស់ព្រះគម្ពីរមកពីព្រះជាម្ចាស់ដ៏ល្អវិសេស ដែលការគ្រប់គ្រងរបស់ទ្រង់គឺល្អ។ នៅក្នុងសួនច្បារអេដែន សាតាំងបាននិយាយថា ព្រះជាម្ចាស់ជាអ្នកគ្រប់គ្រងដ៏ឃោរឃៅដែលពួកគេគួរតែប្រឆាំងនឹងការគ្រប់គ្រងរបស់ទ្រង់។ នេះគឺជាការកុហកនៅពេលនោះ ហើយវានៅតែជាការកុហកនាបច្ចុប្បន្ននេះផងដែរ។ សិទ្ធិអំណាចកំពូលរបស់ព្រះជាម្ចាស់ ដែល



Scripture is supreme INDD interior - Khmer 1.9.indd 51 14/8/26 3:55 in the afternoon

បានបើកសម្ដែងឲ្យឃើញតាមរយៈព្រះគម្ពីរ គឺខ្ពង់ខ្ពស់លើសហួសពីគំនិតរបស់យើង ហើយដោយសេចក្ដីស្រឡាញ់នេះ ផ្ដល់សេរីភាព ផ្ដល់ជីវិត និងគ្រប់គ្រងប្រកបដោយសេចក្ដីស្រឡាញ់។ ប្រសិនបើយើងធ្លាប់មានហេតុនាំឲ្យសង្ស័យលើការនេះ នោះយើងអាចសម្លឹងមើលទៅឯឈើឆ្កាង។ នៅលើឈើឆ្កាង យើងឃើញពីកម្ពស់ ជម្រៅ និងទំហំនៃសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ (រ៉ូម ៥:៨)។

ភាពផ្ទុយគ្នានៃសិទ្ធិអំណាចកំពូលគឺការចុះចូល។ ប្រសិនបើតាមរយៈព្រះគម្ពីរបង្ហាញថា ព្រះជាម្ចាស់មានសិទ្ធិអំណាចកំពូល នោះការឆ្លើយតបដ៏ត្រឹមត្រូវរបស់យើង គឺជាការចុះចូលនឹងទ្រង់។ ប៉ុន្តែ យើងគួរចងចាំជានិច្ចថា យើងកំពុងតែចុះចូលនឹងការគ្រប់គ្រងរបស់ព្រះវរបិតាដែលប្រកបដោយសេចក្ដីស្រឡាញ់។



Scripture is supreme INDD interior - Khmer 1.9.indd 52 14/8/26 3:55 in the afternoon

## ការឆ្លុះបញ្ចាំង ឬការពិភាក្សា

១. តើនរណាជាការបើកសម្ដែងរបស់ព្រះជាម្ចាស់? តើការបើកសម្ដែងរបស់ព្រះជាម្ចាស់នៅក្នុងព្រះគម្ពីរទាក់ទងនឹងភាពជាបុគ្គលនេះយ៉ាងដូចម្ដេច?

២. ហេតុអ្វីបានជាសិទ្ធិអំណាចកំពូលមានលក្ខណៈជាបុគ្គល? តើការនេះមានន័យយ៉ាងណាចំពោះយើងដែលជាអ្នកជឿ? តើលោកអ្នកឃើញការនេះកើតឡើងក្នុងជីវិតប្រចាំថ្ងៃរបស់លោកអ្នកដោយរបៀបណា?

៣. តើលោកអ្នកយល់ឃើញការប្រៀបធៀបរវាង «អ្នកនាំរាជសារ និងស្ដេច» មានប្រយោជន៍ដល់ការយល់ដឹងអំពី «ការថ្វាយបង្គំព្រះគម្ពីរ» ដែរទេ? ហេតុអ្វីការនេះមាន ឬក៏គ្មានប្រយោជន៍?



Scripture is supreme INDD interior - Khmer 1.9.indd 53 14/8/26 3:55 in the afternoon

Scripture is supreme INDD interior - Khmer 1.9.indd 54 14/8/26 3:55 in the afternoon

៣

# តើព្រះគម្ពីរមានសិទ្ធិអំណាចកំពូលនៅពេលណា?

## សិទ្ធិអំណាចដែលលាតសន្ធឹងគ្រប់ទីកន្លែង

ជាទូទៅ ឃ្លាដែលថា «ព្រះគម្ពីរចែងថា...» គួរតែបញ្ចប់រាល់ការឈ្លោះប្រកែកគ្នារវាងគ្រីស្ទបរិស័ទ ពីព្រោះយើងត្រូវតែធ្វើតាមអ្វីដែលព្រះគម្ពីរចែង។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយលោកអ្នកទំនងជាដឹងតាមរយៈបទពិសោធន៍កន្លងមកដែលថា អ្វីៗមិនសាមញ្ញយ៉ាងដូច្នោះនោះទេ។ នេះមិនមែនដោយសារតែព្រះគម្ពីរមិនមានសិទ្ធិអំណាចកំពូលនោះទេ។ ប៉ុន្តែយើងត្រូវយល់ឲ្យបានច្បាស់អំពីវិសាលភាពនៃសិទ្ធិអំណាចរបស់ព្រះគម្ពីរ។

### នៅពេលដែលយើងយល់បានយ៉ាងត្រឹមត្រូវ នោះព្រះគម្ពីរមានសិទ្ធិអំណាចកំពូល

សូមគិតអំពីអ្នកនាំសារដែលនាំរាជសារមកពីស្ដេច។ ថ្ងៃមួយ អ្នកនាំសារនិយាយថា៖ «ព្រះរាជា



Scripture is supreme INDD interior - Khmer 1.9.indd 55 14/8/26 3:55 in the afternoon

ទ្រង់បញ្ជាឲ្យគ្រប់គ្នាបើកបរ «នៅខាងស្តាំផ្លូវ» ។ ប៉ុន្តែឧបមាថាលោកអ្នកនិយាយថា៖ «ខ្ញុំគិតថានេះជាពាក្យប្រៀបធៀបមួយ ដើម្បីពណ៌នាអំពីផ្លូវនៃជីវិតដែលយើងឆ្លងកាត់ ហើយឃ្លាថា «ត្រូវប្រកាន់ស្តាំ» ស្តេចមានន័យថា យើងគួរតែដើរតាមផ្លូវដែលយើងជឿថាត្រឹមត្រូវ។ តើលោកអ្នកបានស្តាប់តាមបញ្ជាស្តេចដែរឬទេ? តើលោកអ្នកបានគោរពដល់សិទ្ធិអំណាចនៃព្រះបន្ទូលដែរឬទេ? ច្បាស់ជាអត់ទេ។ ដូចគ្នានេះដែរ ព្រះគម្ពីរមានសិទ្ធិអំណាចកំពូលតែនៅពេលដែលគេយល់បានយ៉ាងត្រឹមត្រូវអំពីព្រះគម្ពីរប៉ុណ្ណោះ។

គ្រីស្ទបរិស័ទស្មោះត្រង់ និងពិតប្រាកដ ដែលមានការប្តេជ្ញាចិត្តខ្ពស់ចំពោះភាពសំខាន់នៃព្រះគម្ពីរអាចមិនយល់ស្របគ្នាអំពីអ្វីដែលព្រះគម្ពីរបង្រៀន។ ដូច្នេះពេលខ្លះនៅពេលដែលនរណាម្នាក់និយាយថា៖ «ព្រះគម្ពីរចែងថា» នោះបុគ្គលម្នាក់ទៀតអាចនឹងឆ្លើយថា៖ «ខ្ញុំមិនយល់ស្របទេ ខ្ញុំជឿថា ព្រះគម្ពីរសំដៅដល់អ្វីផ្សេងពីនេះ»។ បុគ្គលទាំងពីរមានការប្តេជ្ញាចិត្តចំពោះភាពសំខាន់នៃព្រះគម្ពីរដូចគ្នា ប៉ុន្តែពួកគេនៅតែមិនអាចឯកភាពគ្នាបានឡើយ។

ការនេះបង្កើតជាសំណួរថា៖ តើយើងត្រូវធ្វើដូចម្តេច ដើម្បីអាចយល់ព្រះគម្ពីរបានយ៉ាងត្រឹមត្រូវ?



Scripture is supreme INDD interior - Khmer 1.9.indd 56 14/8/26 3:55 in the afternoon

ដើម្បីអាចយល់ព្រះគម្ពីរបានត្រឹមត្រូវ គឺយើងត្រូវសិក្សាវិជ្ជាកាត់ស្រាយព្រះគម្ពីរ (hermeneutics) ដែលជាប្រធានបទមួយផ្សេងទៀតដែលយើងសិក្សាថ្ងៃក្រោយ។ ប៉ុន្តែ សម្រាប់ពេលនេះយើងនឹងលើកឡើងចំណុចសំខាន់នៃសេចក្តីពិតចំនួនបី៖

## អ្វីដែលយើងចាំបាច់ត្រូវដឹងគឺភាពច្បាស់លាស់

មានផ្នែកមួយចំនួនក្នុងព្រះគម្ពីរដែលពិបាកយល់ ហើយមានបញ្ហាខ្លះទៀតដែលពិបាកនឹងដោះស្រាយ។ ប៉ុន្តែ នៅពេលនិយាយអំពីការដើរតាមព្រះគ្រីស្ទ នោះព័ត៌មានសំខាន់ៗគឺច្បាស់លាស់។ កណ្ឌគម្ពីរ ២ពេត្រុស ១:៣-៤ បានចែងថា៖

> «ដ្បិតព្រះចេស្តានៃព្រះបានផ្តល់ឲ្យយើងរាល់គ្នាមានគ្រប់របស់ទាំងអស់ខាងឯជីវិត និងសេចក្តីគោរពប្រតិបត្តិដល់ព្រះ ដោយយើងបានស្គាល់ព្រះអង្គដែលទ្រង់ហៅយើងរាល់គ្នាមកដោយសារសិរីល្អ និងសគុណរបស់ទ្រង់ ដែលដោយសារសេចក្តីទាំងនោះ ទ្រង់បានប្រទានសេចក្តីសន្យាដ៏ធំបំផុត ហើយវិសេសផង មកយើងរាល់គ្នា ដើម្បីឲ្យអ្នករាល់គ្នាបានចំណែកជានិស្ស័យនៃព្រះ ដោយសារសេចក្តីសន្យានោះឯង ដោយបានរួចពីសេចក្តីពុករលួយនៅក្នុងលោកីយ៍នេះដែលកើតអំពីសេចក្តីប៉ងប្រាថ្នា»។



Scripture is supreme INDD interior - Khmer 1.9.indd 57 14/8/26 3:55 in the afternoon

យើងមាន «គ្រប់របស់ទាំងអស់ខាងឯជីវិត និងសេចក្ដីគោរពប្រតិបត្ដិដល់ព្រះ»។ យើងមានការនេះនៅក្នុង «សេចក្ដីសន្យាដ៏ធំបំផុត ហើយវិសេសផង» ក្នុងព្រះគម្ពីរ។ ព្រះជាម្ចាស់មិនបានទុកយើងចោលដោយគ្មានការណែនាំនោះទេ។ បញ្ហារបស់យើងមិនមែនថា យើងខ្វះព័ត៌មាននោះទេ។ បញ្ហារបស់យើងគឺថា យើងមិនធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ការនេះនាំយើងទៅកាន់ចំណុចទីពីររបស់យើង។

## យើងត្រូវចូលទៅកាន់ព្រះគម្ពីរ ដោយចិត្តបន្ទាបខ្លួន

អ្វីដែលសំខាន់បំផុត ដើម្បីអាចយល់ព្រះគម្ពីរឲ្យបានត្រឹមត្រូវ នោះយើងត្រូវមានចិត្តបន្ទាបខ្លួន។ លោកអ្នកមិនត្រូវការសញ្ញាបត្រខាងផ្នែកទេវសាស្ត្រ ឬការយល់ដឹងពីភាសាដើមនោះទេ។ លោកអ្នកត្រូវការតែចិត្តដែលបន្ទាបខ្លួន ដែលត្រៀមខ្លួនរួចជាស្រេចក្នុងការទទួលស្គាល់ពីតម្រូវការ ហើយការចុះចូលជីវិតរបស់លោកអ្នក។

នៅពេលដែលយើងមិនចង់ធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ នោះយើងអាចនឹងផ្លាស់



Scripture is supreme INDD interior - Khmer 1.9.indd 58 14/8/26 3:55 in the afternoon

ប្តូរពាក្យពេចន៍របស់ព្រះគម្ពីរដើម្បីឲ្យត្រូវនឹងគំនិតយើងផ្ទាល់។ យើងអាចសូម្បីតែនឹងផ្លាស់ប្តូរពាក្យពេចន៍របស់ព្រះគម្ពីរ ដោយមិនដឹងខ្លួនផង។ យើងអាចនឹងប្រើប្រាស់វិធីសាស្ត្រល្អៗ ដើម្បីអាចយល់ព្រះគម្ពីរដូចជា៖ ការពិនិត្យមើលប្រវត្តិសាស្ត្រ និងវប្បធម៌នៅសម័យព្រះគម្ពីរជាដើម ប៉ុន្តែយើងប្រើវាដើម្បីផ្លាស់ប្តូរ ឬជៀសវាងនូវអ្វីដែលព្រះគម្ពីរចែង ឬព្រះជាម្ចាស់មានបន្ទូលទៅវិញ។ ឧទាហរណ៍ «អ្នកកាន់ក្រឹត្យវិន័យ» គឺជាមនុស្សដែលផ្តោតខ្លាំងលើក្រឹត្យវិន័យ ហើយពួកគេចង់បង្ហាញថា ពួកគេជួយបន្ថែមដល់សេចក្តីសង្គ្រោះផ្ទាល់ខ្លួនរបស់ខ្លួន។ ដូច្នេះពួកគេផ្តោតទៅលើសេចក្តីបង្គាប់នៅក្នុងព្រះគម្ពីរ ហើយមិនអើពើនឹងសារនៃព្រះគម្ពីរអំពីអសមត្ថភាពពីកំណើតរបស់យើង និងសេចក្តីស្រឡាញ់ប្រកបដោយព្រះគុណរបស់ព្រះជាម្ចាស់នោះទេ។ ម្យ៉ាងវិញទៀត «ពួកសេរីនិយម» គឺជាមនុស្សដែលមានទស្សនៈបើកចំហ ហើយពួកគេមានអារម្មណ៍មិនសុខស្រួលជាមួយនឹងសេចក្តីបង្គាប់បញ្ញាមួយចំនួននៅក្នុងព្រះគម្ពីរនោះទេ ដោយសារសេចក្តីបង្គាប់ទាំងនោះមិនស៊ីគ្នានឹងវប្បធម៌សម័យទំនើប។ ដូច្នេះ ពួកគេមិនអើពើនឹងការទាមទារមួយចំនួននៃព្រះគម្ពីរឡើយ ដោយពួកគេនិយាយថា សេចក្តីបង្គាប់ទាំង



Scripture is supreme INDD interior - Khmer 1.9.indd 59 14/8/26 3:55 in the afternoon

នោះគឺសម្រាប់អ្នករស់នៅក្នុងវប្បធម៌បុរាណ ដែលមិនអាចអនុវត្តសម្រាប់យើងនៅសម័យនេះនោះបានទេ។

## យើងមិននៅតែឯងទេ

ដំណឹងល្អគឺថា យើងមិននៅម្នាក់ឯងនោះទេ នៅពេលដែលយើងអានព្រះគម្ពីរ។ យើងមានរាស្ត្ររបស់ព្រះជាម្ចាស់ដទៃទៀត ពោលគឺគ្រីស្ទបរិស័ទពេញមួយប្រវត្តិសាស្ត្រ ដែលយើងអាចពឹងផ្អែកលើប្រាជ្ញារបស់ពួកគេបាន។ ហើយយើងមានសមាជិកនៅក្នុងក្រុមជំនុំ ដែលយើងអាចពន្យល់ពីអត្ថន័យនៃព្រះគម្ពីរ។ កាន់តែល្អថែមទៀតនោះ យើងមានព្រះជាម្ចាស់ផ្ទាល់គង់នៅជាមួយនឹងយើង។ ព្រះវិញ្ញាណបរិសុទ្ធបំភ្លឺលើព្រះបន្ទូលរបស់ព្រះ ដោយធ្វើឲ្យចិត្តយើងបន្ទាបចុះ ហើយទ្រង់ដកចេញនូវភាពរឹងរូសរបស់យើងទៅចំពោះបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ គ្រីស្ទបរិស័ទដែលជួយយើងឲ្យយល់ព្រះគម្ពីរក៏ជាអំណោយពីព្រះវិញ្ញាណផងដែរ ដោយព្រោះព្រះវិញ្ញាណបានប្រទានឲ្យពួកគេនូវសមត្ថភាពក្នុងការបង្រៀនដល់អ្នកឯទៀតបាន (១កូរិនថូស ១២:៤-១១)។



Scripture is supreme INDD interior - Khmer 1.9.indd 60 14/8/26 3:55 in the afternoon

អ្វីដែលយើងម្នាក់ៗត្រូវធ្វើ គឺធ្វើតាមព្រះគម្ពីរដូចដែលយើងបានយល់។ ឧទាហរណ៍ បើលោកអ្នកគិតថា ព្រះគម្ពីរចែងថា អ្នកជឿនៅក្នុងសេចក្ដីសញ្ញាថ្មីគួរតែរក្សាថ្ងៃអាទិត្យជាថ្ងៃឈប់សម្រាកដោយមិនធ្វើការ នោះលោកអ្នកគួរតែរក្សាថ្ងៃអាទិត្យទុកជាថ្ងៃឈប់សម្រាកដោយមិនធ្វើការចុះ។ ម្យ៉ាងវិញទៀត ប្រសិនបើលោកអ្នកគិតថា ថ្ងៃឈប់សម្រាកត្រូវបានសម្រេចនៅក្នុងការសម្រាកដែលព្រះគ្រីស្ទបានប្រទានឲ្យហើយ នោះលោកអ្នកអាចសម្រាកបានកាន់តែប្រសើរឡើងអំពីអ្វីដែលលោកអ្នកធ្វើនៅថ្ងៃអាទិត្យ។

នេះជាចំណុចដែលសាវ័ក ប៉ុល បានលើកឡើងនៅក្នុងកណ្ឌគម្ពីរ រ៉ូម ជំពូក១៤ «ម្នាក់យល់ថា ថ្ងៃមួយល្អជាងថ្ងៃមួយ ម្នាក់ទៀតយល់ថា ថ្ងៃណាក៏ដូចថ្ងៃណា។ ចូរឲ្យគ្រប់គ្នាជឿប្រាកដក្នុងគំនិតរបស់ខ្លួនចុះ» (ខ.៥)។ សាវ័ក ប៉ុល ប្រាប់យើងកុំឲ្យជជែកវែកញែកលើ «យោបល់របស់គេឡើយ» ( ខ.១)។ សាវ័ក ប៉ុល បារម្ភថា ខ្ញុំអាចប្រព្រឹត្តចំពោះយោបល់របស់អ្នកដោយគ្មានការគោរព អាចជាការលើកទឹកចិត្តដល់អ្នក ឬក៏ដាក់សម្ពាធអ្នកឲ្យធ្វើអ្វីមួយប្រឆាំងនឹងមនសិការរបស់អ្នក។ «មិនត្រូវធ្វើអ្វីឲ្យបងប្អូនណាជំពប់ដួល ឬរវាត



Scripture is supreme INDD interior - Khmer 1.9.indd 61 14/8/26 3:55 in the afternoon

ចិត្តឡើយ» យើងអាចនឹងរារាំងពួកគេពីការធ្វើតាមព្រះគម្ពីរដូចដែលពួកគេយល់ (ខ.១៣-១៥)។

សូមកត់សម្គាល់ថា ការលើកឡើងរបស់សាវ័កប៉ុល នៅក្នុងកណ្ឌគម្ពីររ៉ូម ជំពូក១៤ គឺផ្អែកលើជំនឿលើសិទ្ធិអំណាចខ្ពស់បំផុតនៃព្រះគម្ពីរ។ គឺព្រោះតែព្រះគម្ពីរជាសិទ្ធិអំណាចកំពូលរបស់យើងដែលបុគ្គលម្នាក់ៗគួរតែធ្វើតាមនូវអ្វីដែលពួកគេជឿថា ព្រះគម្ពីរបានបង្រៀន ទោះបីជាអ្នកឯទៀតមិនយល់ស្របជាមួយនឹងយើងក៏ដោយ។ នៅទីបញ្ចប់ យើងត្រូវតែចុះចូលនឹងព្រះគម្ពីរដោយព្រោះព្រះគម្ពីរជាព្រះបន្ទូលរបស់ព្រះជាម្ចាស់។

សូមស្រមៃថា លោកអ្នកកំពុងតែឈរនៅចំពោះព្រះជាម្ចាស់នៅថ្ងៃចុងក្រោយ។ ក្នុងចំណោមពាក្យពេចន៍ខាងក្រោមនេះ តើលោកអ្នកចង់និយាយឃ្លាណាមួយក្នុងចំណោមឃ្លាទាំងនេះ?

- «ខ្ញុំបានមើលឃើញថា គ្រីស្ទបរិស័ទមិនយល់ស្របគ្នាលើបញ្ហានេះ។ ឥឡូវនេះ ខ្ញុំដឹងថា ខ្ញុំបានយល់ខុសទាក់ទងនឹងអ្វីដែលព្រះគម្ពីរបានបង្រៀនខ្ញុំស្ដីពីបញ្ហានេះ។ ប៉ុន្តែ ខ្ញុំបានព្យាយាមអស់ពីសមត្ថភាពរបស់ខ្ញុំ ដើម្បីធ្វើតាមអ្វីដែលខ្ញុំបានយល់ចេញពីអត្ថន័យរបស់បទគម្ពីរនោះ»។



Scripture is supreme INDD interior - Khmer 1.9.indd 62 14/8/26 3:55 in the afternoon

- «ខ្ញុំបានមើលឃើញថា គ្រីស្ទបរិស័ទមិនយល់ស្របគ្នាលើបញ្ហានេះ។ ហើយឥឡូវនេះ ខ្ញុំដឹងថា ការយល់ដឹងរបស់ខ្ញុំពិតជាត្រឹមត្រូវណាស់។ ប៉ុន្តែ ជារឿយៗ ខ្ញុំគ្រាន់តែបានចូលរួមជាមួយនឹងគ្រីស្ទបរិស័ទដទៃទៀត ជាមួយនឹងអ្វីដែលពួកគេកំពុងតែធ្វើប៉ុណ្ណោះ»។
- «ខ្ញុំបានមើលឃើញថា គ្រីស្ទបរិស័ទមិនឯកភាពគ្នាលើបញ្ហានេះ។ ដូច្នេះ ខ្ញុំមានអារម្មណ៍ថា វាមិនមានបញ្ហានោះទេចំពោះអ្វីដែលខ្ញុំបានជ្រើសរើសធ្វើ»។

នៅថ្ងៃនោះ នឹងមានព្រះគុណសម្រាប់អស់អ្នកដែលពិតជាជឿលើព្រះគ្រីស្ទ។ ប៉ុន្តែ បើយើងចង់ឮពាក្យថា «ប្រពៃហើយ បាវល្អស្មោះត្រង់អើយ» (ម៉ាថាយ ២៥:២៣) នោះយើងត្រូវធ្វើតាមព្រះគម្ពីរដូចដែលយើងបានយល់វិញ។

ខ្ញុំមិនមែននិយាយថា លោកអ្នកត្រូវតែយល់យ៉ាងច្បាស់អំពីគំនិតរបស់លោកអ្នកចំពោះគ្រប់ទាំងចំណុចនិងគ្រប់អត្ថបទព្រះគម្ពីរនោះទេ។ វាមិនអីទេក្នុងការធ្វើតាមការបង្រៀនរបស់ក្រុមជំនុំរបស់លោកអ្នក។ ប៉ុន្តែប្រហែលជាមានពេលមួយដែលលោកអ្នកមានមតិខុសគ្នាលើចំណុចណាមួយជាមួយនឹងអ្នកដទៃ។ ដំណោះ



Scripture is supreme INDD interior - Khmer 1.9.indd 63 14/8/26 3:55 in the afternoon

ស្រាយដ៏ល្អបំផុតរបស់លោកអ្នក គឺត្រូវគិតអំពីចំណុចនោះម្តងទៀត។ សូមពិភាក្សាចំណុចនោះជាមួយនឹងអ្នកដឹកនាំក្រុមជំនុំរបស់លោកអ្នក។ ចូរស្វែងយល់ពីហេតុផលសម្រាប់ជំនឿរបស់ពួកគេ។ សូមកុំឆាប់នឹងសន្មតថា លោកអ្នកត្រឹមត្រូវ ហើយពួកគេខុសនោះឡើយ។ សូមបើកចិត្តឲ្យទូលាយថា លោកអ្នកប្រហែលជាអាចមានការយល់ដឹងមិនត្រឹមត្រូវផងដែរ។

សូមចងចាំថា ការបន្ទាបខ្លួន គឺសំខាន់ដើម្បីយល់ដឹងពីព្រះគម្ពីរឲ្យបានត្រឹមត្រូវ។ ប៉ុន្តែ នៅទីបញ្ចប់លោកអ្នកត្រូវតែស្មោះត្រង់នឹងមនសិការរបស់លោកអ្នក។ លោកអ្នកត្រូវតែស្តាប់បង្គាប់តាមព្រះជាម្ចាស់ជាជាងមនុស្ស (កិច្ចការ ៥:២៩) ។ ការនេះមានន័យថា ការធ្វើតាមការបង្រៀននៃព្រះគម្ពីរដូចដែលលោកអ្នកយល់ដឹងអំពីព្រះគម្ពីរ។ ខ្ញុំសង្ឃឹមថា អ្នកដឹកនាំរបស់លោកអ្នកគោរពលើការនេះនៅពេលដែលពួកគាត់យល់កណ្ឌគម្ពីររ៉ូម ជំពូក១៤។

## មានសិទ្ធិអំណាចកំពូលទៅលើអ្វីដែលលើកមកដោះស្រាយ

ព្រះជាម្ចាស់បាន «ផ្តល់ឲ្យយើងរាល់គ្នាមានគ្រប់របស់ទាំងអស់ ខាងឯជីវិត និងសេចក្តីគោរពប្រតិបត្តិ



Scripture is supreme INDD interior - Khmer 1.9.indd 64 14/8/26 3:55 in the afternoon

ដល់ព្រះ» ដូចដែលយើងបានឃើញនៅខាងលើ សេចក្តីសន្យានៃព្រះគម្ពីរ (២ពេត្រុស ១:៣-៤) ។ មានសារៈសំខាន់ណាស់ក្នុងការសង្កត់ធ្ងន់លើពាក្យ «គ្រប់របស់ទាំងអស់»។ គ្មានអ្វីបាត់បង់នោះទេ។ គ្រប់អ្វីទាំងអស់ដែលយើងត្រូវដឹង ដើម្បីអាចរស់នៅក្នុងជីវិតមួយដែលគោរពប្រតិបត្តិដល់ព្រះ បានបើកសម្តែងឲ្យឃើញនៅក្នុងព្រះគម្ពីរ។

ប៉ុន្តែ យើងក៏ត្រូវផ្តោតលើពាក្យ «ខាងឯ» ផងដែរ។ ព្រះគម្ពីរផ្តល់ឲ្យយើងនូវអ្វីគ្រប់យ៉ាងដែលយើងត្រូវការ «*ខាងឯ*ជីវិត និងសេចក្តីគោរពប្រតិបត្តិដល់ព្រះ»។ ព្រះគម្ពីរមិនបានផ្តល់ឲ្យយើងនូវ*អ្វីគ្រប់យ៉ាង*ដែលយើងត្រូវការសម្រាប់អ្វីផ្សេងទៀតនោះទេ។ ព្រះគម្ពីរមិនមែនជាសិទ្ធិអំណាចខ្ពស់បំផុតលើការជួសជុលឡាននោះដែរ។ ព្រះគម្ពីរមិនមែនជាសិទ្ធិអំណាចខ្ពស់បំផុតលើច្បាប់បាល់ទាត់នោះទេ។ ព្រះគម្ពីរមិនបានប្រាប់យើងពីរបៀបដុតនំសូកូឡានោះឡើយ។ ព្រះគម្ពីរមិនបានប្រាប់យើងពីតម្លៃល្អបំផុតរបស់ទូរស័ព្ទថ្មីណាមួយនោះទេ។ មានចំណុចជាច្រើនដែលព្រះគម្ពីរមិនបានរៀបរាប់ប្រាប់ដល់យើង។ សម្រាប់ការទាំងនេះ យើងត្រូវរកមើលនៅកន្លែងផ្សេងទៀត។



Scripture is supreme INDD interior - Khmer 1.9.indd 65 14/8/26 3:55 in the afternoon

ប្រសិនបើព្រះគម្ពីរនិយាយអំពីចំណុចទាំងនោះ នោះព្រះគម្ពីរនឹងមានសិទ្ធិអំណាចខ្ពស់បំផុតនៅក្នុងចំណុចទាំងនោះផងដែរ។ គ្រប់ទាំងអ្វីដែលព្រះគម្ពីរបានចែងគឺមានសិទ្ធិអំណាច។ មនុស្សមួយចំនួននិយាយថា ព្រះគម្ពីរគ្រាន់តែមានសិទ្ធិអំណាចលើប្រធានបទទាក់ទងនឹងជំនឿប៉ុណ្ណោះ ប៉ុន្តែមិនមានសិទ្ធិអំណាចលើវិទ្យាសាស្ត្រ ឬប្រវត្តិសាស្ត្រនោះទេ។ នេះមិនមែនជាការពិតនោះទេ។ ព្រះគម្ពីរមានសិទ្ធិអំណាចលើគ្រប់ទាំងអ្វីដែលព្រះគម្ពីរបញ្ជាក់អះអាង។ ប៉ុន្តែបើលោកអ្នកត្រូវការជួសជុលរថយន្តរបស់លោកអ្នក នោះខ្ញុំសូមណែនាំឲ្យលោកអ្នករកមើលកន្លែងផ្សេង។ លោកអ្នកអាចមើលវីដេអូតាមយូធ្យូប (YouTube) ។ កាន់តែប្រសើរជាងនេះទៅទៀត សូមយករថយន្តរបស់លោកអ្នកទៅឲ្យយានដ្ឋានជួសជុលនៅក្បែរលោកអ្នក ហើយឲ្យពួកគេជួសជុលវាទៅ។

លើកលែងតែ...ព្រះគម្ពីរផ្តល់នូវបរិបទ ឬក្របខណ្ឌដើម្បីដោះស្រាយចំណុចមួយចំនួន ដែលព្រះគម្ពីរមិនបាននិយាយចំៗ។ ព្រះគម្ពីរមិនបាននិយាយអំពីហ្វេសប៊ុក (Facebook) នោះទេ។ សូមជឿខ្ញុំ ខ្ញុំបានពិនិត្យមើលរួចហើយ។ ព្រះគម្ពីរមិនបានប្រាប់លោកអ្នកពីរបៀបបង្ហោះវីដេអូនៅលើកម្មវិធីយូធ្យូប ឬលក់



Scripture is supreme INDD interior - Khmer 1.9.indd 66 14/8/26 3:55 in the afternoon

ផលិតផលនៅលើកម្មវិធីអ៊ីនស្តាក្រាម (Instagram) នោះទេ។ ប៉ុន្តែ ព្រះគម្ពីរបាននិយាយអំពីការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយក្នុងសង្គម។ ព្រះគម្ពីរបានព្រមានយើងកុំឲ្យរស់នៅដើម្បីទទួលបាននូវការទទួលស្គាល់ពីអ្នកដទៃ (ដែលព្រះគម្ពីរហៅថា «ការដែលខ្លាចចំពោះមនុស្ស» សុភាសិត ២៩:២៥)។ ព្រះគម្ពីរបានព្រមានយើងឲ្យប្រឆាំងនឹងការបង្កើតនូវអត្តសញ្ញាណផ្ទាល់ខ្លួនរបស់យើង។ ផ្ទុយទៅវិញ ព្រះគម្ពីរចង្អុលប្រាប់យើងអំពីអត្តសញ្ញាណដែលព្រះជាម្ចាស់បានប្រទានដល់យើងក្នុងព្រះគ្រីស្ទ។ ព្រះគម្ពីររំឭកយើងថា ជីវិតរបស់មនុស្សគឺជាជីវិតដែលរស់នៅក្នុងរូបរាងកាយក្នុងចំណោមក្រុមមនុស្សដែលមើលមកជីវិតរបស់យើងទាំងមូល មិនមែនជាផ្នែកៗនោះទេ។

## សិទ្ធិអំណាចកំពូលនៅក្នុងដែនកំណត់ដែលព្រះគម្ពីរផ្ទាល់បានកំណត់

ប្រសិនបើព្រះគម្ពីរមិនបាននិយាយអំពីបញ្ហាខាងឯវិញ្ញាណ ឬខាងទេវសាស្ត្រយ៉ាងលម្អិតទេ នោះប្រហែលជាមិនសំខាន់សម្រាប់យើងក្នុងការយល់ដឹងពីបញ្ហានោះទេ។ ឧទាហរណ៍ មនុស្សខ្លះជឿថា មានចំណាត់ថ្នាក់ ឬឋានន្តរស័ក្តិខុសៗគ្នារបស់ពួកទេវតា។



Scripture is supreme INDD interior - Khmer 1.9.indd 67 14/8/26 3:55 in the afternoon

ព្រះគម្ពីរបាននិយាយសំដៅលើទេវតាមួយចំនួនថាជា «មហាទេវតា» ដែលហាក់ដូចជាប្រភេទនៃទេវតាដែលត្រួតត្រាលើទេវតាផ្សេងទៀត។ កណ្ឌគម្ពីរ កូឡុស ១:១៦ ចែងថា៖ អ្វីៗទាំងអស់ត្រូវបានបង្កើតឡើងនៅក្នុងព្រះគ្រីស្ទ ដោយរួមទាំង «របស់នៅស្ថានសួគ៌ និងនៅផែនដី ទាំងរបស់ដែលមើលឃើញ ហើយដែលមើលមិនឃើញផង ទោះបើជារាជ្យ ឬអំណាចជាព្រះអម្ចាស់ ឬអំណាចគ្រប់គ្រង ឬអំណាចណាក៏ដោយ»។ នេះបង្ហាញថា រាជ្យអំណាចជាព្រះអម្ចាស់ អំណាចគ្រប់គ្រង និងអំណាចណាក៏ដោយនៅស្ថានសួគ៌អាចជាប្រភេទនៃទេវតាផ្សេងៗគ្នា។

ប្រហែល។ ប៉ុន្តែ ព្រះគម្ពីរមិនបាននិយាយច្បាស់ ឬបង្ហាញជាក់លាក់អំពីការនេះឲ្យបានលម្អិតនោះទេ។ នៅពេលដែលព្រះគម្ពីរមិនបានលើកឡើង វាប្រហែលជាសញ្ញាបញ្ជាក់ថា យើងមិនចាំបាច់ត្រូវដឹងនោះទេ។ សូមចងចាំថា៖ ព្រះជាម្ចាស់ទ្រង់បំពេញកិច្ចការរបស់ទ្រង់ ដោយល្អឥតខ្ចោះ។ ព្រះអង្គបានបញ្ជាក់យ៉ាងច្បាស់នូវអ្វីដែលយើងត្រូវដឹង។ ដូច្នេះ ប្រសិនបើអ្វីមួយមិនច្បាស់លាស់ទេ នោះយើងប្រហែលជាមិនចាំបាច់ដឹងវាទេ។ ក្នុងករណីដូចនេះ អ្វីដែលយើងត្រូវដឹងគឺថា ព្រះជាម្ចាស់យកព្រះទ័យទុកដាក់ចំពោះយើង ដោយ



Scripture is supreme INDD interior - Khmer 1.9.indd 68 14/8/26 3:55 in the afternoon

សារពេលខ្លះទ្រង់បង្ហាញតាមរយៈទេវតា ពេលខ្លះទៀតដោយអង្គទ្រង់ផ្ទាល់ ហើយពេលខ្លះតាមរយៈមនុស្សផ្សេងទៀត។ យើងត្រូវដឹងថា យើងអាចទូលថ្វាយតម្រូវការរបស់យើងទៅកាន់ព្រះជាម្ចាស់ ដោយការអធិស្ឋាន–មិនមែនទៅកាន់ទេវតានោះទេ។

ចំណុចសំខាន់នៅទីនេះគឺថា ដែនកំណត់នៃសិទ្ធិអំណាចរបស់ព្រះគម្ពីរត្រូវបានកំណត់ដោយព្រះគម្ពីរផ្ទាល់។ ព្រះគម្ពីរ (ឬព្រះជាម្ចាស់ដែលមានបន្ទូលតាមរយៈព្រះគម្ពីរ) កំណត់នូវដែនកំណត់នៃសិទ្ធិអំណាចនិងជំនាញដោយខ្លួនឯង។ ចំពោះចំណុចណាដែលព្រះគម្ពីរមិនបានពិភាក្សា នោះយើងត្រូវស្វែងរកចម្លើយនៅកន្លែងផ្សេងទៀត។ ប៉ុន្តែ សម្រាប់អ្វីគ្រប់យ៉ាងដែលព្រះគម្ពីរបញ្ជាក់អះអាង នោះព្រះគម្ពីរគឺមានសិទ្ធិអំណាចកំពូល។ ការនេះនាំយើងត្រឡប់ទៅរកគំនិតជាមូលដ្ឋានមួយគឺ៖ នៅពេលណាដែលយើងត្រូវសម្រេចចិត្តរវាងអ្វីដែលព្រះគម្ពីរបានចែង និងអ្វីផ្សេងទៀតបាននិយាយ នោះយើងតែងតែជ្រើសរើសព្រះគម្ពីរ។



Scripture is supreme INDD interior - Khmer 1.9.indd 69 14/8/26 3:55 in the afternoon

## ការឆ្លុះបញ្ចាំង ឬការពិភាក្សា

១) តើការដែលដឹងថាលោកអ្នកមាន «គ្រប់របស់ទាំងអស់ ខាងឯជីវិត និងសេចក្តីគោរពប្រតិបត្តិដល់ព្រះ [ដើម្បីរស់នៅក្នុងជីវិតដែលកោតខ្លាចព្រះ]» ធ្វើឲ្យលោកអ្នកមានអារម្មណ៍កាន់តែប្រសើរឡើងដោយរបៀបណា? តើព្រះជាម្ចាស់ប្រទានដល់លោកអ្នកនូវអ្វីដែលលោកអ្នកត្រូវការតាមរយៈព្រះគម្ពីរយ៉ាងដូចម្តេច?

២) តើការខ្វះការបន្ទាបខ្លួន និងការចុះចូល អាចបណ្តាលឲ្យបុគ្គលណាម្នាក់ផ្លាស់ប្តូរអត្ថន័យនៃពាក្យពេចន៍ក្នុងព្រះគម្ពីរយ៉ាងដូចម្តេច? តើលោកអ្នកអាចរកឧទាហរណ៍មួយបានឬទេ?

៣) សូមគិតអំពីគ្រូបង្រៀនពីរ ឬបីនាក់ដែលទទួលការដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធ និងរបៀបដែលពួកគេបានជួយលោកអ្នកឲ្យបានយល់ព្រះគម្ពីរកាន់តែប្រសើរឡើង។ សូមអរគុណដល់ព្រះជាម្ចាស់សម្រាប់គ្រូៗទាំងនេះ។ តើមានអ្វីជាក់លាក់ខ្លះ ដែលលោកអ្នកគិតថាមានប្រយោជន៍ ឬទទួលការលើកទឹកចិត្តអំពីរបៀបដែលពួកគាត់បានបង្រៀន?



Scripture is supreme INDD interior - Khmer 1.9.indd 70 14/8/26 3:55 in the afternoon

## ៤

# ហេតុអ្វីបានជាសិទ្ធិអំណាចកំពូលនៃព្រះគម្ពីរសំខាន់?

## សិទ្ធិអំណាចតែមួយគត់

ការទាំងអស់នេះគឺគួរឲ្យចាប់អារម្មណ៍ណាស់ ប៉ុន្តែលោកអ្នកប្រហែលជាកំពុងតែគិតថា តើវាពិតជាសំខាន់មែនឬ? តើហេតុអ្វីបានជាមានភាពចម្រូងចម្រាសទាំងអស់នេះកើតឡើង? តើហេតុអ្វីបានជាសិទ្ធិអំណាចកំពូលនៃព្រះគម្ពីរជាគោលលទ្ធិដ៏សំខាន់? ចម្លើយគឺ៖ នៅគ្រាដ៏សំខាន់ៗក្នុងប្រវត្តិសាស្ត្រនៃក្រុមជំនុំ សិទ្ធិអំណាចកំពូលនៃព្រះគម្ពីរបានក្លាយជាបញ្ហាដ៏សំខាន់មួយរួចទៅហើយ។ ហើយសព្វថ្ងៃនេះ ក៏មានបញ្ហាដូចគ្នាដែរ។

គេអាចសង្ខេបការគិតរបស់ក្រុមកំណែទម្រង់ប្រូតេស្តង់មកត្រឹមពាក្យ «សូឡា» (‘solas’) ចំនួនប្រាំ។ ពាក្យ «សូឡា» មកពីពាក្យជាភាសាឡាតាំងដែលមានន័យថា «តែមួយគត់»។ យើងជឿថា យើងទទួល



Scripture is supreme INDD interior - Khmer 1.9.indd 71 14/8/26 3:55 in the afternoon

បានការសង្គ្រោះដោយសារព្រះគ្រីស្ទតែមួយគត់ តាមរយៈជំនឿតែមួយគត់ ដោយសារព្រះគុណតែមួយគត់ ហើយយើងធ្វើតាមព្រះគម្ពីរតែមួយគត់។ ហើយការទាំងនេះនាំមកនូវសិរីល្អដល់ព្រះជាម្ចាស់តែមួយគត់។ «ព្រះគម្ពីរតែមួយគត់» គឺជារបៀបមួយផ្សេងទៀតដើម្បីពិពណ៌នាអំពីសិទ្ធិអំណាចកំពូលនៃព្រះគម្ពីរ៖ ព្រះគម្ពីរតែមួយគត់គឺជាសិទ្ធិអំណាចកំពូលរបស់យើង។

ប៉ុន្តែ «ព្រះគម្ពីរតែមួយគត់» មិនមានន័យថា «មានតែព្រះគម្ពីរ» នោះទេ។ យើងមិនបាននិយាយថា «មានតែព្រះគម្ពីរ ហើយគ្មានអ្វីផ្សេងទៀតនោះទេ»។ ផ្ទុយទៅវិញ យើងកំពុងតែនិយាយថា «គ្មានអ្វីមួយលើសពីព្រះគម្ពីរ ឬប្រៀបស្មើនឹងព្រះគម្ពីរឡើយ»។ មានប្រភពនៃសិទ្ធិអំណាចផ្សេងៗទៀតដែលយើងគោរពឲ្យតម្លៃផងដែរ។ នៅពេលដែលយើងគិតអំពីព្រះជាម្ចាស់ ជាញឹកញាប់យើងតែងកត់សម្គាល់នូវប្រភពនៃចំណេះដឹងបួនយ៉ាង៖

- ហេតុផល
- បទពិសោធន៍
- ប្រពៃណី
- ព្រះគម្ពីរ



Scripture is supreme INDD interior - Khmer 1.9.indd 72 14/8/26 3:55 in the afternoon

ប្រភពចំណេះដឹងទាំងបួនគឺមានសារៈសំខាន់ណាស់។ សិទ្ធិអំណាចកំពូលនៃព្រះគម្ពីរមិនមែនមានន័យថា យើងបោះបង់ចោលហេតុផល បទពិសោធន៍ ឬប្រពៃណីនោះទេ។

- យើងគោរពសិទ្ធិអំណាចនៃហេតុផលដោយប្រើប្រាស់ការសិក្សាខាងផ្នែកវិទ្យាសាស្ត្រ ប្រវត្តិសាស្ត្រ វប្បធម៌បុរាណ សង្គមមនុស្ស និងចិត្តសាស្ត្រ។ យើងបដិសេធគំនិតណាដែលមិនប្រកបដោយវិចារណញ្ញាណ មិនសមហេតុផល ឬទាស់ប្រឆាំងគ្នា។
- យើងគោរពសិទ្ធិអំណាចនៃបទពិសោធន៍។ យើងចង់ឲ្យការគិតរបស់យើងស៊ីគ្នានឹងជីវិតពិត ហើយអាចអនុវត្តជាក់ស្តែងបាន។ ហើយជារឿយៗ យើងពឹងផ្អែកលើញាណរបស់យើងដើម្បីដឹកនាំយើងនៅក្នុងកិច្ចការប្រចាំថ្ងៃរបស់យើង។
- យើងគោរពសិទ្ធិអំណាចនៃប្រពៃណី ពីព្រោះយើងឲ្យតម្លៃលើគំនិតយោបល់ផ្សេងៗរបស់គ្រីស្ទបរិស័ទដទៃទៀតមកពីច្រើនសតវត្សរ៍មកហើយ។ គ្រីស្ទបរិស័ទទាំងនេះបានពេញដោយព្រះវិញ្ញាណបរិសុទ្ធ ដូចជាយើងផងដែរ។ យើង



Scripture is supreme INDD interior - Khmer 1.9.indd 73 14/8/26 3:55 in the afternoon

> មិនមែនជាមនុស្សដំបូងគេដែលបានគិតយ៉ាងស៊ីជម្រៅអំពីប្រធានបទជាក់លាក់មួយចំនួននោះទេ ដូច្នេះយើងក៏ចង់រៀនពីអ្វីដែលអ្នកឯទៀតៗបាននិយាយ និងបានធ្វើកន្លងមកផងដែរ។

ហេតុផល បទពិសោធន៍ និងប្រពៃណីទាំងអស់គួរតែសំខាន់សម្រាប់យើង។ មនុស្សម្នាក់ៗមានកម្រិតនៃសិទ្ធិអំណាចជាក់លាក់នៅក្នុងរបៀបដែលយើងគិត និងប្រព្រឹត្ត។ ប៉ុន្តែ ព្រះគម្ពីរតែងតែមានចំណាត់ថ្នាក់ខ្ពស់បំផុត។ ដូចដែលលោក ខេវីន វ៉ានហ៊ូហ្សឺរ (Kevin Vanhoozer) និយាយថា «ព្រះគម្ពីរមិនមែនជាប្រភពតែមួយគត់ដែលគេប្រើនៅក្នុងទេវវិទ្យានោះទេ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ គឺព្រះគម្ពីរ*តែមួយគត់*ដែលមាន*សិទ្ធិអំណាចកំពូល* និងដំបូងគេនៅក្នុងទេវវិទ្យា»។[១៣]

---

១៣ លោក Kevin J. Vanhoozer, *Biblical Authority After Babel: Retrieving the Solas in the Spirit of Mere Protestant Christianity* (Grand Rapids, MI: Brazos, ឆ្នាំ២០១៦), ទំព័រ១១១។



Scripture is supreme INDD interior - Khmer 1.9.indd 74 14/8/26 3:55 in the afternoon

តើយើងនឹងធ្វើអ្វីនៅពេលដែលយើងជួបប្រទះនឹងគំនិតផ្ទុយគ្នា? ចុះបើអ្វីដែលព្រះគម្ពីរបង្រៀនមិនស៊ីនឹងបទពិសោធន៍របស់ខ្ញុំ ឬការអះអាងខាងវិទ្យាសាស្ត្រថ្មីបំផុតនោះ? ជាដំបូង យើងគួរតែពិនិត្យមើលថា គំនិតផ្ទុយគ្នាទាំងនេះអាចនឹងសម្រុះសម្រួលគ្នាបានឬទេ។ យើងគួរតែអានព្រះគម្ពីរម្តងទៀត ហើយពិនិត្យមើលថា តើយើងអាចយល់ពីគំនិតនោះតាមវិធីផ្សេងទៀតបានឬក៏អត់។ នេះមិនមែនជាសញ្ញាមួយនៃភាពទន់ខ្សោយនៅក្នុងទេវវិទ្យារបស់យើងនោះទេ។ ផ្ទុយទៅវិញ នេះជាសញ្ញាមួយដែលបង្ហាញពីទំនុកចិត្ត និងការបន្ទាបខ្លួន។ យើងមានទំនុកចិត្តថា ព្រះគម្ពីរគឺជាសេចក្តីពិត ដូច្នេះយើងអាចនឹងសួរសំណួរពិបាកៗបាន។ យើងក៏មានការបន្ទាបខ្លួនល្មម ដើម្បីនឹងទទួលស្គាល់ថា យើងប្រហែលជាកំពុងតែអានព្រះគម្ពីរមិនបានត្រឹមត្រូវផងដែរ។

ឧទាហរណ៍ ប្រពៃណីអាចដើរតួនាទីដូចជាសម្លេងរោទ៍ ដើម្បីប្រាប់យើងនៅពេលដែលការយល់ដឹងរបស់យើងអំពីព្រះគម្ពីរស្ថិតក្នុងទិសដៅខុស។ ឧបមាថា ការយល់ដឹងរបស់លោកអ្នកអំពីព្រះគម្ពីរមិនស្រុបនឹងគោលជំនឿ និងការប្រកាសជំនឿនៃក្រុមជំនុំរបស់លោកអ្នក។ ឬឧបមាថា ការយល់ដឹងរបស់លោកអ្នក



Scripture is supreme INDD interior - Khmer 1.9.indd 75 14/8/26 3:55 in the afternoon

មិនស្របនឹងរបៀបដែលគ្រីស្ទបរិស័ទភាគច្រើនក្នុងប្រវត្តិសាស្ត្រអានអត្ថបទព្រះគម្ពីរណាមួយនោះទេ។ ប្រហែលជាលោកអ្នកត្រឹមត្រូវ ហើយអ្នកផ្សេងទៀតខុស។ នោះជាអ្វីដែលបានកើតឡើងក្នុងអំឡុងពេលនៃកំណែទម្រង់ប្រូតេស្តង់ នៅពេលដែលអ្នកកែទម្រង់បានរកឃើញដំណឹងល្អដ៏ពិតឡើងវិញ។ ពួកគេបានកែការបង្រៀនព្រះគម្ពីរសញ្ញាថ្មីថា យើងបានផ្សះផ្សាជាមួយនឹងព្រះជាម្ចាស់តាមរយៈជំនឿតែមួយគត់នៅក្នុងព្រះរាជកិច្ចរបស់ព្រះគ្រីស្ទ។ ប៉ុន្តែ សម្រាប់ស្ថានភាពភាគច្រើន ប្រសិនបើលោកអ្នកមិនយល់ស្របតាមគោលជំនឿ និងការប្រកាសជំនឿនៃក្រុមជំនុំរបស់លោកអ្នក នោះទំនងជាខុសហើយ ហើយលោកអ្នកត្រូវកែប្រែចិត្តគំនិតរបស់ខ្លួនវិញ។ ខ្ញុំលើកទឹកចិត្តលោកអ្នកឲ្យគិតឲ្យបានហ្មត់ចត់មុននឹងលោកអ្នកអះអាងថា មានគំនិតថ្មីទាស់ប្រឆាំងនឹងគោលជំនឿដើមនៃជំនឿគ្រីស្ទបរិស័ទគណៈនិកាយប្រូតេស្តង់។

## លោក កាលីលេអូ និងតម្រូវការក្នុងការគិតឡើងវិញអំពីការបង្រៀននៃព្រះគម្ពីរ

តារាវិទូជនជាតិអ៊ីតាលីលោក កាលីលេអូ កាលីលេ (Galileo Galilei) (ឆ្នាំ១៥៦៤-១៦៤២



Scripture is supreme INDD interior - Khmer 1.9.indd 76 14/8/26 3:56 in the afternoon

នៃគ.ស.) បានអះអាងថា ផែនដីផ្លាស់ទីជុំវិញព្រះអាទិត្យនៅពេលមួយនៅក្នុងប្រវត្តិសាស្រ្ត ដែលក្រុមជំនុំរ៉ូម៉ាំងកាតូលិកបានបង្រៀនថា ផែនដីគឺជាចំណុចកណ្តាលនៃសកលលោក។ សំណេររបស់គាត់ត្រូវស៊ើបអង្កេតដោយ «ក្រុមបង្ក្រាបអ្នកវង្វេងជំនឿ» (The Inquisition) ។ «ក្រុមបង្ក្រាបអ្នកវង្វេងជំនឿ» គឺជាក្រុមមួយដែលព្យាយាមស្វែងរក និងលុបបំបាត់សេចក្តីបង្រៀនខុសឆ្គងនៅក្នុងក្រុមជំនុំកាតូលិក។

លោក កាលីលេអូ បានអះអាងថា គំនិតរបស់គាត់គឺស្របនឹងព្រះគម្ពីរ ហើយថាព្រះគម្ពីរត្រូវការកាត់ស្រាយឡើងវិញ។ ប៉ុន្តែ ក្រុមជំនុំកាតូលិកបានខូចបាត់ទៅហើយ ហើយត្រូវជំទាស់ដោយក្រុមកំណែទម្រង់ប្រូតេស្តង់។ ក្រុមជំនុំកាតូលិកបានគិតថា ស្ថានការណ៍នោះគឺជាសញ្ញាមួយនៃសេចក្តីបង្រៀនខុសឆ្គងរបស់ពួកប្រូតេស្តង់។ ក្រុមជំនុំកាតូលិកបាននិយាយថា ខ្លួនមានសិទ្ធិអំណាចក្នុងការប្រកាសពីអ្វីដែលព្រះគម្ពីរបានបង្រៀន។ ហេតុដូច្នេះហើយ ពួកគេជឿថា លោក កាលីលេអូ គ្មានសិទ្ធិក្នុងការជំទាស់នឹងការបង្រៀនរបស់ពួកគេនោះទេ។

ដូច្នេះហើយ នៅឆ្នាំ១៦១៦ «ក្រុមបង្ក្រាបអ្នកវង្វេងជំនឿ» បានប្រកាសថា លោក កាលីលេអូ និង



Scripture is supreme INDD interior - Khmer 1.9.indd 77 14/8/26 3:56 in the afternoon

គំនិតរបស់គាត់ដែលថា ផែនដីវិលជុំវិញព្រះអាទិត្យ គឺជាគំនិតដ៏ «ល្ងីល្ងើ និងមិនសមហេតុផល» ។ ពួកគេបានប្រកាសថា គំនិតនោះជាគំនិត «ដ៏ខុសឆ្គងដោយបើកចំហ ព្រោះវាផ្ទុយនឹងការបង្រៀនជាច្រើននៃព្រះគម្ពីរបរិសុទ្ធ»។ លោក កាលីលេអូ នៅតែមិនមានគ្រោះថ្នាក់អ្វីនោះទេ មួយរយៈពេលក្រោយមក។ ប៉ុន្តែនៅឆ្នាំ១៦៣២ គាត់បានបោះពុម្ពសៀវភៅមួយដែលមានចំណងជើងថា «ការសន្ទនាអំពីប្រព័ន្ធ ដ៏សំខាន់ពីរនៃពិភពលោក» *(Dialogue Concerning the Two Chief World Systems)*។ សៀវភៅនេះបានគ្រាន់តែរៀបរាប់អំពីទស្សនៈចំនួនពីរ ដោយសាមញ្ញប៉ុណ្ណោះ។ ប៉ុន្តែ មេដឹកនាំកាតូលិកបានសម្រេចថា វាជាសកម្មភាពសម្ងាត់មួយរបស់លោក កាលីលេអូ ដើម្បីផ្សព្វផ្សាយគំនិតរបស់គាត់។ លោក កាលីលេអូ បានរងការចោទប្រកាន់ពី «ក្រុមបង្ក្រាបអ្នកវង្វេងជំនឿ» ក្នុងឆ្នាំ១៦៣៣។ ពួកគេបានរកឃើញថា គាត់មានពិរុទ្ធ ហើយគាត់បានចំណាយពេលសេសសល់ពេញមួយជីវិតរបស់គាត់រស់នៅក្រោមការឃុំខ្លួនក្នុងផ្ទះ ដោយមិនអាចចាកចេញពីផ្ទះរបស់គាត់បានឡើយ។

សព្វថ្ងៃនេះ គ្មាននរណាម្នាក់គិតថា ព្រះអាទិត្យធ្វើដំណើរជុំវិញផែនដីនោះទេ។ វាជាការពិតដែលព្រះគម្ពីរ



Scripture is supreme INDD interior - Khmer 1.9.indd 78 14/8/26 3:56 in the afternoon

និយាយអំពីព្រះអាទិត្យរះពីជើងមេឃម្ខាង ហើយដើរវង់ទៅដល់ជើងមេឃម្ខាងទៀត (ទំនុកតម្កើង ១៩:៦)។ ប៉ុន្តែ យើងទាំងអស់គ្នានិយាយបែបនេះជាការបញ្ចេញមតិផ្ទាល់ប៉ុណ្ណោះ។ កណ្ឌគម្ពីរ ទំនុកតម្កើង ជំពូក១៩ គឺជាកំណាព្យ ហើយកំណាព្យមានលំនាំផ្ទាល់ខ្លួន ជាពិសេសក្នុងការប្រើពាក្យប្រៀបធៀប និងរូបភាព។ ប៉ុន្តែ កំណាព្យនៅតែអាចប្រាស្រ័យទាក់ទងនូវព័ត៌មានពិតជាមួយនឹងសិទ្ធិអំណាចពិតផងដែរ។[១៤] លើសពីនេះទៅទៀត ភាសាអំពីព្រះអាទិត្យរះគឺមិនត្រឹមតែប្រើក្នុងកំណាព្យប៉ុណ្ណោះទេ។ ឧទាហរណ៍ ការព្យាករណ៍ពីអាកាសធាតុនៅលើទូរស័ព្ទរបស់លោកអ្នកក៏មានពេលវេលាដែល «ព្រះអាទិត្យរះ» ផងដែរ។ យើងនិយាយបែបនេះ ដោយព្រោះតាមទស្សនៈរបស់យើង វាហាក់ដូចជាព្រះអាទិត្យរះ។ នេះប្រហែលជាមិនមែនជាភាសាខាងផ្នែកវិទ្យាសាស្ត្រនោះទេ ប៉ុន្តែវានៅតែជាមធ្យោបាយដ៏មានប្រយោជន៍ដើម្បីពិពណ៌នាអំពីរបៀបដែលយើងជួបជារៀងរាល់ព្រឹក។ ការប្រើប្រាស់ភាសា

---

១៤ សូមមើលសៀវភៅនិពន្ធដោយ៖ លោក C. S. Lewis, "The Language of Religion," ក្នុង *C. S. Lewis: Essay Collection and Other Short Pieces,* កែសម្រួលដោយ៖ លោក Lesley Walmsley (London: HarperCollins, ឆ្នាំ២០០០), ទំព័រ២៥៥-២៦៦។



Scripture is supreme INDD interior - Khmer 1.9.indd 79 14/8/26 3:56 in the afternoon

នេះមិនមែនមានន័យថា យើងជឿលើប្រព័ន្ធព្រះអាទិត្យដែលមានផែនដីនៅកណ្តាលនោះទេ។

លោក កាលីលេអូ និយាយត្រូវ៖ គេអាចកាត់ស្រាយព្រះគម្ពីរតាមរបៀបមួយដែលស៊ីគ្នានឹងរបកគំហើញនៃតារាសាស្ត្រ។ ការស្រាវជ្រាវរបស់គាត់មិនបានធ្វើឲ្យយើងជ្រើសរើសរវាងវិទ្យាសាស្ត្រ និងព្រះគម្ពីរនោះទេ។ ប៉ុន្តែ វាពិតជាបានធ្វើឲ្យយើងជ្រើសរើសរវាងការយល់ខុស និងការយល់ត្រឹមត្រូវអំពីព្រះគម្ពីរ។

សិទ្ធិអំណាចកំពូលនៃព្រះគម្ពីរអាចតម្រូវឲ្យយើងនិយាយផ្ទុយនឹងការអះអាងរបស់វិទ្យាសាស្ត្រ។ ប៉ុន្តែជម្រើសដំបូងរបស់យើងគួរតែពិនិត្យមើលថា តើការលើកឡើងរបស់ព្រះគម្ពីរ និងការលើកឡើងរបស់វិទ្យាសាស្ត្រអាចសម្រុះសម្រួលជាមួយគ្នាបានឬក៏អត់។ ពេលខ្លះ ការនេះមានន័យថា យើងបានយល់ខុសអំពីអ្វីដែលគម្ពីរបានចែង។

នៅពេលដែលយើងត្រូវជ្រើសរើស នោះយើងត្រូវជ្រើសរើសយកព្រះគម្ពីរ។ នៅពេលដែលមានជំនឿពីរទាស់ប្រឆាំងនឹងគ្នា នោះយើងត្រូវជឿលើព្រះគម្ពីរ។ នៅពេលដែលមានរបៀបពីរផ្សេងគ្នាក្នុងការជ្រើសរើស នោះយើងត្រូវជ្រើសរើសធ្វើតាមព្រះគម្ពីរ។ ហេតុផល



Scripture is supreme INDD interior - Khmer 1.9.indd 80 14/8/26 3:56 in the afternoon

បទពិសោធន៍ និងប្រពៃណី គឺជាដៃគូដ៏*ល្អ*របស់ព្រះគម្ពីរ។ ប៉ុន្តែ ប្រសិនបើយើងអនុញ្ញាតឲ្យការទាំងនោះ*ប្រកួតប្រជែង*ជាមួយនឹងព្រះគម្ពីរ នោះបញ្ហាមួយចំនួននឹងកើតឡើងជាមិនខាន។

## ព្រះគម្ពីរទល់នឹងប្រពៃណី

ព្រះគម្ពីរទល់នឹងប្រពៃណីគឺជាបញ្ហាចម្បងមួយក្នុងអំឡុងពេលកំណែទម្រង់ប្រូតេស្តង់។ ក្រុមជំនុំកាតូលិកនាមជ្ឈិមសម័យបានទទួលស្គាល់សិទ្ធិអំណាចនៃព្រះគម្ពីរដោយរីករាយ។ ប៉ុន្តែ ពួកគេក៏បានលើកតម្កើងប្រពៃណីនៃក្រុមជំនុំកាតូលិកស្មើនឹងព្រះគម្ពីរផងដែរ។ តាមពិតទៅ គេបានដាក់ព្រះគម្ពីរនៅក្រោមសិទ្ធិអំណាចនៃក្រុមជំនុំកាតូលិកតាមវិធីពីរផ្សេងគ្នា។

ទីមួយ ពួកគេបាននិយាយថា មានតែក្រុមជំនុំកាតូលិកប៉ុណ្ណោះដែលអាចពន្យល់ព្រះគម្ពីរដោយសិទ្ធិអំណាច។ ក្រុមជំនុំកាតូលិកបានជឿថា ព្រះគម្ពីរគឺមិនមានភាពច្បាស់លាស់សម្រាប់មនុស្សសាមញ្ញធម្មតាអាចយល់បាននោះទេ។ ដោយសារពេលខ្លះ មានទស្សនៈខុសៗគ្នាលើព្រះគម្ពីរ នោះក្រុមជំនុំកាតូលិកបាននិយាយថា មានតែពួកគេទេដែលអាចផ្តល់ការបកស្រាយប្រកបដោយសិទ្ធិអំណាចបាន។ គេបានទទួល



Scripture is supreme INDD interior - Khmer 1.9.indd 81 14/8/26 3:56 in the afternoon

ស្គាល់ជាផ្លូវការនៃព្រះគម្ពីរមានសិទ្ធិអំណាចកំពូល ប៉ុន្តែជាក់ស្តែងព្រះគម្ពីរមិនមានសិទ្ធិអំណាចពិតប្រាកដនោះទេ។ នៅពេលដែលក្រុមជំនុំកាតូលិកបាននិយាយថា មានតែពួកគេទេដែលអាចបកស្រាយព្រះគម្ពីរបាន ប៉ុន្តែតាមការពិតគឺជាប្រពៃណីរបស់ក្រុមជំនុំកាតូលិកទៅវិញទេដែលមានសិទ្ធិអំណាចកំពូលនោះ។

ទីពីរ ក្រុមជំនុំកាតូលិកបាននិយាយថា ព្រះវិញ្ញាណបរិសុទ្ធបន្តមានបន្ទូលតាមរយៈក្រុមជំនុំកាតូលិក។ ការនេះបានអនុញ្ញាតឲ្យបង្កើតនូវគោលលទ្ធិមួយដែលព្រះគម្ពីរមិនបានគាំទ្រដោយផ្ទាល់នោះឡើយ។ ឧទាហរណ៍ គោលលទ្ធិស្តីពីស្ថានជម្រះបាប (purgatory) គឺជាជំនឿដែលថា មនុស្សភាគច្រើននឹងទៅកន្លែងធ្វើទារុណកម្មបណ្តោះអាសន្ននៅពេលដែលពួកគេស្លាប់ទៅ ដូច្នេះព្រលឹងរបស់ពួកគេអាចទទួលការសម្អាតសិនមុនពេលចូលនគរស្ថានសួគ៌បាន។ គោលលទ្ធិនេះគឺគ្មានមូលដ្ឋាននៅក្នុងព្រះគម្ពីរទាល់តែសោះ។ ប៉ុន្តែ វាបានក្លាយជាការបង្រៀនផ្លូវការរបស់ក្រុមជំនុំកាតូលិកទៅហើយ។

សព្វថ្ងៃនេះ ក្រុមជំនុំកាតូលិកនៅតែលើកតម្កើងប្រពៃណីទំនៀមទម្លាប់របស់ពួកគេឲ្យនៅស្មើនឹងព្រះគម្ពីរ។ សេចក្តីថ្លែងការណ៍ផ្លូវការនៃគោលជំនឿរបស់



Scripture is supreme INDD interior - Khmer 1.9.indd 82 14/8/26 3:56 in the afternoon

ក្រុមជំនុំរ៉ូម៉ាំងកាតូលិក ដែលជា*សៀវភៅសំណួរចម្លើយខ្លីៗទាក់ទងនឹងគោលលទ្ធិរបស់ក្រុមជំនុំកាតូលិក*បានលើកឡើងថា «មានវិធីប្រាស្រ័យទាក់ទងពីរផ្សេងគ្នា» សម្រាប់ព្រះជាម្ចាស់ក្នុងការបើកសម្ដែងសេចក្ដីពិតរួមមាន៖ ព្រះគម្ពីរដ៏វិសុទ្ធ និងប្រពៃណីដ៏វិសុទ្ធ។[១៥] ក្រុមជំនុំកាតូលិកមានតួនាទីក្នុងការទំនាក់ទំនង និងពន្យល់ពីអ្វីដែលព្រះជាម្ចាស់បើកសម្ដែង។ នេះមានន័យថា ក្រុមជំនុំកាតូលិក «មិនពឹងផ្អែកលើព្រះគម្ពីរដ៏វិសុទ្ធតែមួយគត់សម្រាប់ភាពប្រាកដប្រជាអំពីសេចក្ដីពិតទាំងអស់ដែលព្រះជាម្ចាស់បានបើកសម្ដែងមកនោះទេ។ ទាំងព្រះគម្ពីរ និងប្រពៃណីត្រូវតែទទួលយកនិងលើកតម្កើងដោយការគោរព និងភក្តីភាពស្មើគ្នា» ។[១៦] សូមកត់សម្គាល់ថា *សៀវភៅសំណួរចម្លើយខ្លីៗ*ទាក់ទងនឹងគោលលទ្ធិនេះលើកឡើងថា សិទ្ធិអំណាចក្នុងការបកស្រាយព្រះគម្ពីរជាកម្មសិទ្ធិរបស់ក្រុមជំនុំកាតូលិក «តែមួយគត់» ។ «ការបកស្រាយព្រះបន្ទូលរបស់ព្រះជាម្ចាស់យ៉ាងស្មោះត្រង់ គឺជាកិច្ចការដែលបានប្រគល់ឲ្យតែចំពោះក្រុមគ្រូបង្រៀនផ្លូវការរបស់ក្រុមជំនុំ

---

១៥ ដកស្រង់ចេញពីសៀវភៅ Catechism of the Catholic Church, កែសម្រួលលើកទី២, កថាខណ្ឌ, ទំព័រ៨០-៨១។

១៦ ដកស្រង់ចេញពីសៀវភៅ Catechism, កថាខណ្ឌ, ទំព័រ៨២។



Scripture is supreme INDD interior - Khmer 1.9.indd 83 14/8/26 3:56 in the afternoon

កាតូលិក (Magisterium of the Church) ដែលរួមមានសម្តេចប៉ាប និងពួកអភិបាលទាំងអស់រួមជាមួយគ្នាតែប៉ុណ្ណោះ»។[១៧]

គ្រាដ៏សំខាន់មួយនៅក្នុងសម័យកំណែទម្រង់បានកើតឡើង នៅពេលដែលលោក ម៉ាធិន លូសើរ (Martin Luther) បានភ្ញាក់រលឹកថា គាត់ត្រូវតែធ្វើការជ្រើសរើសរវាងការបង្រៀនរបស់ព្រះគម្ពីរ និងការបង្រៀនរបស់ក្រុមជំនុំកាតូលិក។ ដំបូងឡើយ គាត់មិនមានគម្រោងនឹងចាប់ផ្តើមក្រុមជំនុំថ្មីមួយនោះទេ។ គាត់សង្ឃឹមថានឹងកែប្រែក្រុមជំនុំកាតូលិកដែលមានស្រាប់។ ប៉ុន្តែ នៅពេលដែលគាត់ត្រូវធ្វើការជ្រើសរើស នោះគាត់បានជ្រើសរើសយកព្រះគម្ពីរ។ នេះគឺជាឧទាហរណ៍នៃសិទ្ធិអំណាចកំពូលនៃព្រះគម្ពីរ។

ក្រុមជំនុំត្រូវ «បានស្អាងឡើងលើជើងជញ្ជាំងនៃពួកសាវ័ក និងពួកហោរា ហើយព្រះយេស៊ូវគ្រីស្ទនោះឯង ទ្រង់ជាថ្មជ្រុងយ៉ាងឯក» (អេភេសូរ ២:២០)។ «ពួកសាវ័ក» គឺជាសក្ខីកម្មដ៏សំខាន់នៃព្រះគម្ពីរសញ្ញាថ្មី។ រីឯពាក្យ «ពួកហោរា» គឺជារបៀបទូទៅមួយ ដើម្បីនិយាយសំដៅទៅលើព្រះគម្ពីរសញ្ញា

---

១៧ ដកស្រង់ចេញពីសៀវភៅ Catechism, កថាខណ្ឌ ទំព័រ១០០ មានបន្ថែមសេចក្តីពន្យល់។



Scripture is supreme INDD interior - Khmer 1.9.indd 84 14/8/26 3:56 in the afternoon

ចាស់។ ក្រុមជំនុំបានស្អាងឡើងដោយព្រះគម្ពីរ មិនមែនព្រះគម្ពីរបានស្អាងឡើងដោយក្រុមជំនុំនោះទេ។ អ្នកប្រាជ្ញខាងព្រះគម្ពីរលោក ស្ទីវផាន ឌែមស្ទើរ (Stephen Dempster) បានលើកឡើងថា «ក្រុមជំនុំគ្រីស្ទបរិស័ទបានកើតឡើង ដោយព្រះគម្ពីរនៅក្នុងដៃ»។[១៨] លោក ស្ទីវផាន បានរំលេចនូវគោលគំនិតជាប្រវត្តិសាស្ត្រមួយ គឺថា៖ ក្រុមជំនុំក្នុងព្រះគម្ពីរសញ្ញាថ្មីបានប្រើប្រាស់ព្រះគម្ពីរសញ្ញាចាស់ ហើយរស់នៅក្រោមសិទ្ធិអំណាចនៃព្រះគម្ពីរសញ្ញាចាស់នោះ។ ប៉ុន្តែការពិតជាប្រវត្តិសាស្ត្រនេះគាំទ្រដល់សេចក្តីពិតខាងទេវសាស្ត្រមួយដែលថា៖ ព្រះគម្ពីរបង្កើតក្រុមជំនុំ មិនមែនក្រុមជំនុំបង្កើតព្រះគម្ពីរនោះទេ។

---

១៨ លោក Stephen G. Dempster, “Canon and Old Testament Interpretation,” ការស្វែងយល់អំពីកណ្ឌគម្ពីរសញ្ញាចាស់ក្នុង *Hearing the Old Testament: Listening for God’s Address,* កែសម្រួលដោយ៖ លោក Craig G. Bartholomew និងលោក David J. H. Beldman (Grand Rapids, MI: Eerdmans, ឆ្នាំ២០១២), ទំព័រ១៥៩។



Scripture is supreme INDD interior - Khmer 1.9.indd 85 14/8/26 3:56 in the afternoon

## សសរនៃសេចក្ដីពិត

ខគម្ពីរចម្បងដែលទេវវិទូរបស់កាតូលិកប្រើនៅពេលការពារសិទ្ធិអំណាចស្មើគ្នានៃប្រពៃណីនោះគឺ កណ្ឌគម្ពីរ ១ធីម៉ូថេ ៣:១៥។ ខគម្ពីរនេះពណ៌នាអំពី «ពួកជំនុំ» ថាជា «សសរ ហើយជាជើងចង្កល់របស់សេចក្ដីពិត»។ ក្រុមជំនុំកាតូលិកបានអះអាងថា នេះគឺដោយសារតែក្រុមជំនុំរ៉ូម៉ាំងកាតូលិកបានផ្ទៀងផ្ទាត់នូវអ្វីដែលត្រឹមត្រូវ និងអ្វីដែលមនុស្សគួរជឿ។

ប៉ុន្តែ លោក ខិលវិន (Calvin) បានលើកឡើងថា ក្រុមជំនុំមិនមែនជាសសររបស់សេចក្ដីពិត ដោយព្រោះតែក្រុមជំនុំ*សម្រេចចិត្ត*ថា អ្វីដែលជាសេចក្ដីពិតនោះទេ។ មានតែព្រះជាម្ចាស់ទេ ដែលសម្រេចថា អ្វីទៅជាសេចក្ដីពិត ហើយព្រះអង្គប្រទានសេចក្ដីពិតនោះដល់យើងតាមរយៈបទគម្ពីរ។ «វាជាការប្រមាថដ៏គម្រក់មួយដែលថា ព្រះបន្ទូលរបស់ព្រះមិនមានភាពប្រាកដប្រជាទេ លុះត្រាតែព្រះបន្ទូលនោះទទួលបានភាពប្រាកដប្រជាពីមនុស្សសិន»។ ផ្ទុយទៅវិញ ក្រុមជំនុំគឺជាសសររបស់សេចក្ដីពិត ពីព្រោះក្រុមជំនុំ*ប្រកាស*ពីអ្វីដែលព្រះជាម្ចាស់បានមានបន្ទូល ដោយធ្វើឲ្យប្រាកដថា សម្លេងរបស់ព្រះជាម្ចាស់នៅតែឮនៅក្នុងពិភពលោកនេះ។ លោក ខិលវិន បានលើកឡើងថា «ក្រុមជំនុំ គឺជា



Scripture is supreme INDD interior - Khmer 1.9.indd 86 14/8/26 3:56 in the afternoon

សសរនៃសេចក្តីពិត ពីព្រោះតាមរយៈព័ន្ធកិច្ចរបស់ក្រុមជំនុំ សេចក្តីពិតទទួលបានការរក្សាទុក និងប្រកាសចេញទៅក្រៅ»។

ព្រះជាម្ចាស់បានផ្ទុកផ្តាក់សេចក្តីពិតរបស់ទ្រង់ដល់យើងជាទំនុកចិត្តដ៏ពិសិដ្ឋណាស់។ សេចក្តីពិតមិនត្រូវការពង្រីក ឬបន្ថែមបន្ថយនោះទេ ប៉ុន្តែគួរតែការពារ និងប្រកាសសេចក្តីពិតវិញ។ «ដូច្នេះ ក្រុមជំនុំរក្សាសេចក្តីពិតពាក់ព័ន្ធនឹងមនុស្សជាតិ ដោយព្រោះក្រុមជំនុំជាអ្នកប្រកាសសេចក្តីពិតតាមរយៈការអធិប្បាយ ហើយក្រុមជំនុំផ្ទាល់ត្រូវរក្សាសេចក្តីពិតឲ្យបានបរិសុទ្ធ គ្រប់លក្ខណ៍ ហើយហុចបន្តសេចក្តីពិតនោះទៅមនុស្សជំនាន់ក្រោយៗទៀត» ។[១៩]

---

១៩ លោក John Calvin, *Calvin's Commentaries: The Second Epistle of Paul the Apostle to the Corinthians and the Epistles to Timothy, Titus, and Philemon*, កែសម្រួលដោយ៖ លោក David W. Torrance and Thomas F. Torrance, បកប្រែដោយ៖ លោក T. A. Smail (Edinburgh: Oliver and Boyd, ឆ្នាំ១៩៦៤), ទំព័រ២៣១-២៣២។



Scripture is supreme INDD interior - Khmer 1.9.indd 87 14/8/26 3:56 in the afternoon

## ព្រះគម្ពីរទល់នឹងហេតុផល

បើសិទ្ធិអំណាចនៃប្រពៃណីទំនៀមទម្លាប់ទាស់នឹងសិទ្ធិអំណាចកំពូលនៃព្រះគម្ពីរនៅសម័យកាលកំណែទម្រង់ នោះគឺជាសិទ្ធិអំណាចនៃហេតុផលដែលជំទាស់នឹងសិទ្ធិអំណាចកំពូលនៃព្រះគម្ពីរនៅក្នុង «សម័យបំភ្លឺគំនិតរបស់លោកខាងលិច» (The Enlightenment)។ សម័យបំភ្លឺគំនិតរបស់លោកខាងលិច គឺជាចលនាខាងផ្នែកបញ្ញាដែលកែតម្រង់ពិភពលោកនាសម័យទំនើបរបស់យើងដោយយកហេតុផលរបស់មនុស្សដាក់នៅកណ្ដាលនៃទស្សនៈពិភពលោករបស់យើង។

កាលខ្ញុំនៅក្មេង ខ្ញុំចាំបានថាមានគេប្រាប់ខ្ញុំក្នុងអំឡុងពេលប្រជុំសិស្សសាលាអំពីអ្វីដែល «ពិតជា» បានកើតឡើងនៅឯកន្លែងដែលមនុស្សប្រាំពាន់នាក់ទទួលបានអាហារគ្រប់ៗគ្នា។ លោកអ្នកប្រហែលជាចាំបានថា ព្រឹត្តិការណ៍នេះ គឺជាពេលដែលព្រះយេស៊ូវបានប្រទានអាហារដោយការអស្ចារ្យដល់មនុស្សប្រុសប្រាំពាន់នាក់ នេះមិនរាប់ស្ត្រី និងកុមារផង។ ព្រះអង្គមាននំប៉័ងតែប្រាំដុំ និងត្រីពីរកន្ទុយប៉ុណ្ណោះ។ យ៉ាងហោចណាស់ នោះជាអ្វីដែលព្រះគម្ពីរបានចែងមកនៅក្នុងកណ្ឌគម្ពីរ ម៉ាថាយ ១៤:១៣-២១;



Scripture is supreme INDD interior - Khmer 1.9.indd 88 14/8/26 3:56 in the afternoon

ម៉ាកុស ៦:៣២-៤៤; លូកា ៩:១០-១៧; និង យ៉ូហាន ៦:១-១៣។

ប៉ុន្តែ គ្រូរបស់ខ្ញុំមានការពន្យល់ខុសពីនេះ។ គាត់បាននិយាយថា មនុស្សគ្រប់គ្នាបានយកអាហារមក ប៉ុន្តែគ្មាននរណាម្នាក់ចង់យកអាហាររបស់ពួកគេចេញទេ ដោយសារតែពួកគេមិនចង់ចែករំលែកវាជាមួយនឹងមនុស្សប្រាំពាន់នាក់ផ្សេងទៀតទេ។ ប៉ុន្តែ នៅពេលដែលក្មេងប្រុសម្នាក់នោះបានចែករំលែកអាហារថ្ងៃត្រង់របស់គាត់ នោះមនុស្សគ្រប់គ្នាមានអារម្មណ៍ខ្មាសអៀន ហើយក៏ចាប់ផ្តើមចែករំលែកផងដែរ។ ការពន្យល់នេះភ្ជាប់មកជាមួយនឹងមេរៀនខាងផ្នែកសីលធម៌ច្បាស់លាស់មួយគឺ៖ យើងគួរតែចែករំលែកអ្វីដែលយើងមាន ហើយតាមរយៈការធ្វើបែបនេះ នោះយើងអាចលើកទឹកចិត្តអ្នកដទៃឲ្យមានចិត្តសប្បុរសផងដែរ។

ប៉ុន្តែ ការបកស្រាយដ៏ឆ្លាតវៃនេះ មិនស៊ីគ្នានឹងអ្វីដែលព្រះគម្ពីរចែងនោះទេ។ សាច់រឿងស្តីពីដំណឹងល្អទាំងអស់បង្ហាញយ៉ាងច្បាស់នូវព្រឹត្តិការណ៍នេះថាជាការអស្ចារ្យមួយដ៏មានឥទ្ធិពល។ តាមពិត មានតែលោក យ៉ូហាន ទេដែលនិយាយអំពីនំប៉័ងប្រាំដុំ និងត្រីពីរកន្ទុយដែលក្មេងប្រុសម្នាក់បានឲ្យ។ កណ្ឌគម្ពីរដំណឹងល្អបីផ្សេងទៀតមិនបាននិយាយអំពីគាត់ទាល់



Scripture is supreme INDD interior - Khmer 1.9.indd 89 14/8/26 3:56 in the afternoon

តែសោះ។ ហើយសាច់រឿងស្តីពីដំណឹងល្អកំពុងរំលេចចេញនូវចំណុចសំខាន់ជាងនេះ ដែលជាដំណឹងដ៏ប្រសើរជាង គឺថា៖ ព្រះយេស៊ូវ គឺជាស្តេចដ៏ជាអ្នកគង្វាលដែលផ្គត់ផ្គង់ដល់រាស្ត្ររបស់ទ្រង់។

ដូច្នេះ តើអ្វីដែលបានជំរុញឲ្យមានការបំភ្លៃនេះចេញពីអត្ថន័យដ៏ច្បាស់លាស់របស់ព្រះគម្ពីរ? ហេតុផលនោះគឺថា សិទ្ធិអំណាចនៃហេតុផលរបស់មនុស្សកំពុងត្រូវគេលើកតម្កើងខ្ពស់ជាងសិទ្ធិអំណាចនៃព្រះគម្ពីរ។ វិទ្យាសាស្ត្រមិនអាចពន្យល់អំពីរបៀបដែលនំប៉័ងប្រាំដុំអាចផលិតអាហារសម្រាប់មនុស្សជាងប្រាំពាន់នាក់បានឡើយ។ ជាការពិតណាស់ ហេតុផលរបស់យើងប្រាប់យើងថា រឿងនេះមិនអាចកើតឡើងបាននោះទេ។ ប៉ុន្តែ ពេលនោះវាពិតជាបានកើតឡើងមែន។

នេះមិនមែនមានន័យថា គ្រីស្ទបរិស័ទមិនមានហេតុផលនោះទេ។ ជំនឿមិនមែនជាការធ្វើពុតថា គំនិតដែលមិនសមហេតុផលជាគំនិតដែលសមហេតុផលទេ។ ប៉ុន្តែ ជំនឿទទួលស្គាល់ថា មានអ្វីៗកើតមានឡើងច្រើនជាងអ្វីដែលយើងអាចមើលឃើញនឹងភ្នែករបស់យើងទៅទៀត។ ជំនឿទទួលស្គាល់ថា មានអ្វីដែលមនុស្សមិនអាចយល់បាន ឬពន្យល់បាន។ ជំនឿទទួលស្គាល់ពិភពអធិធម្មជាតិជាមួយនឹងព្រះដ៏ពេញ



Scripture is supreme INDD interior - Khmer 1.9.indd 90 14/8/26 3:56 in the afternoon

ដោយការអស្ចារ្យ។ ជាការពិតណាស់ ការដែលគិតថា ព្រះជាម្ចាស់ដែលបានបង្កើតពិភពលោកពីភាពទទេ អាចធ្វើការអស្ចារ្យជាច្រើននៅក្នុងពិភពលោករបស់ទ្រង់ គឺពិតជារឿងមួយដែលសមហេតុផលបំផុតដែលយើងអាចគិតយល់បាន។

## ព្រះគម្ពីរទល់នឹងបទពិសោធន៍

ប្រពៃណី និងហេតុផល គឺជាបញ្ហាចម្បងក្នុងអំឡុងសម័យកាលកំណែទម្រង់ និងសម័យបំភ្លឺគំនិតរបស់លោកខាងលិច។ ប៉ុន្តែ សព្វថ្ងៃនេះការគំរាមកំហែងដ៏ចម្បងទាក់ទងនឹងសិទ្ធិអំណាចកំពូលនៃព្រះគម្ពីរ គឺជាសិទ្ធិអំណាចនៃបទពិសោធន៍របស់យើង។

ថ្មីៗនេះ មិត្តភក្តិរបស់ខ្ញុំឈ្មោះ សំ (មិនមែនឈ្មោះពិតរបស់គាត់ទេ) បានទូរស័ព្ទមកខ្ញុំ ហើយប្រាប់ខ្ញុំថា គាត់នឹងចាកចេញពីប្រពន្ធរបស់គាត់។ គាត់បាននិយាយថា៖ «ខ្ញុំបានជួបអ្នកថ្មីហើយ។ យើងសមគ្នាណាស់ ហើយពួកយើងធ្វើឲ្យគ្នាសប្បាយចិត្តទៅវិញទៅមក»។

ខ្ញុំបានសួរគាត់ថា៖ «ចុះចំណែកឯធីតា ដែលជាប្រពន្ធរបស់ឯង?»



Scripture is supreme INDD interior - Khmer 1.9.indd 91 14/8/26 3:56 in the afternoon

គាត់បានឆ្លើយថា៖ «អ្វីៗមិនល្អទេរវាងយើងទាំងពីរនាក់មួយរយៈកន្លងមកនេះ។ ថ្ងៃណាមួយនាងនឹងយល់ថា ការបែកគ្នានេះ គឺល្អបំផុតសម្រាប់ពួកយើងទាំងពីរនាក់»។

ខ្ញុំក៏បានសួរគាត់ថា៖ «ចុះចំណែកឯព្រះជាម្ចាស់វិញ?

គាត់ឆ្លើយថា៖ «ខ្ញុំដឹងថា ការធ្វើដូចនេះគឺមិនស័ក្តិសមទេ ប៉ុន្តែខ្ញុំប្រាកដថា ព្រះជាម្ចាស់ទ្រង់យល់។ ការនេះហាក់ដូចជាត្រឹមត្រូវណាស់សម្រាប់ខ្ញុំ»។

លោក សំ បានគិតថា អារម្មណ៍របស់គាត់សំខាន់ជាងសិទ្ធិអំណាចនៃព្រះគម្ពីរទៅទៀត។

អស់រយៈពេលជាច្រើនទសវត្សរ៍កន្លងមកនេះ របៀបដែលមនុស្សនិយាយអំពីបញ្ហាខាងសីលធម៌ ឬក្រមសីលធម៌មួយចំនួននៅក្នុងវប្បធម៌របស់យើងបានផ្លាស់ប្តូរ។ សព្វថ្ងៃនេះ វាក្លាយជារឿងសាមញ្ញទៅហើយដែលយើងឮនៅតាមសារព័ត៌មានស្តីពីស្ត្រីមានជំងឺរ៉ាំរ៉ៃម្នាក់ រៀបរាប់អំពីការឈឺចាប់របស់នាង។ នាងនិយាយទាំងអារម្មណ៍ចង់បញ្ចប់ជីវិតរបស់នាងទៀតផង។ អ្នកសម្ភាសន៍សុំឲ្យនាងពន្យល់ពីអារម្មណ៍របស់នាង។ ស្ត្រីនោះនិយាយថា៖ «ខ្ញុំចង់ឲ្យរដ្ឋាភិបាលកែប្រែច្បាប់ ដើម្បីឲ្យអ្នកនៅជុំវិញខ្ញុំអាចបញ្ចប់ការឈឺចាប់



Scripture is supreme INDD interior - Khmer 1.9.indd 92 14/8/26 3:56 in the afternoon

នេះដោយស្របច្បាប់ ដោយបញ្ចប់ជីវិតរបស់ខ្ញុំ» ។ ជាញឹកញាប់ នេះជារបៀបដែលគេលើកឡើងអំពីបញ្ហាខាងសីលធម៌នាសព្វថ្ងៃនេះ។ រឿងរ៉ាវនៃការតយុទ្ធក្នុងការឈឺចាប់បានក្លាយជាហេតុផលដ៏សំខាន់បំផុតដើម្បីផ្លាស់ប្តូរសីលធម៌នៅក្នុងវប្បធម៌របស់យើង។ គេបានលើកឡើងពីសាច់រឿងទាំងនេះ ហើយមិនមានការជំទាស់ណាមួយនោះទេ។ «វាគឺជាហេតុផលទូទៅក្នុងពេលបច្ចុប្បន្ននេះដែលថា «ការនេះច្បាស់ជាត្រឹមត្រូវប្រសិនបើវាមានអារម្មណ៍ថាត្រឹមត្រូវ»។ បទពិសោធន៍ផ្ទាល់ខ្លួន គឺសំខាន់ជាងព្រះគម្ពីរនៅក្នុងវប្បធម៌របស់យើង ហើយពេលខ្លះការគិតបែបនេះបានរីករាលដាលទៅដល់ក្រុមជំនុំផងដែរ។

ប្រាកដណាស់ សាច់រឿងពីការឈឺចាប់មួយចំនួនគឺគួរធ្វើឲ្យយើងមានចិត្តអាណិតអាសូរ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ រឿងទាំងនោះមិនមានមូលដ្ឋានសមស្រប ដើម្បីផ្លាស់ប្តូរច្បាប់ ឬប្រព្រឹត្តអំពើផិតក្បត់នោះឡើយ។ ការជឿថាព្រះគម្ពីរមានសិទ្ធិអំណាចកំពូលមានន័យថា ព្រះគម្ពីរដឹកនាំជំនឿ ការប្រព្រឹត្ត និងសីលធម៌របស់យើង។ អារម្មណ៍ ឬបទពិសោធន៍ផ្ទាល់ខ្លួនរបស់យើងមិនបានដឹកនាំយើងនោះទេ។ ពេលខ្លះខ្ញុំមានអារម្មណ៍ថា ចង់បើកឡានបុកម៉ូតូដែលជិះចូល



Scripture is supreme INDD interior - Khmer 1.9.indd 93 14/8/26 3:56 in the afternoon

កាត់មុខឡានរបស់ខ្ញុំភ្លាមៗ។ ប៉ុន្តែ នោះមិនមានន័យថា វាជារឿងត្រឹមត្រូវនោះទេ។

នេះគឺជាបញ្ហា៖ បទពិសោធន៍របស់យើងមិនមែនជាអ្នកនាំផ្លូវដែលអាចទុកចិត្តបាននោះទេ។ នៅក្នុងកណ្ឌគម្ពីររ៉ូម ជំពូក១ សាវ័ក ប៉ុល បានរៀបរាប់ឡើងវិញនូវរឿងរ៉ាវស្ដីពីការធ្លាក់ចូលទៅក្នុងអំពើបាបរបស់មនុស្សជាតិម្ដងទៀត។ យើងបានជ្រើសរើសថ្វាយបង្គំវត្ថុដែលព្រះជាម្ចាស់បានបង្កើត ជាជាងថ្វាយបង្គំព្រះដែលបង្កើតអ្វីៗអស់នោះវិញ (ខ.២៥)។ សាវ័ក ប៉ុល ពន្យល់អំពីលទ្ធផលនៃការនេះ។ ការគិតរបស់យើងបានទទួលរងផលប៉ះពាល់។ ខ.២២ ចែងថា៖ «គេអួតខ្លួនថា មានប្រាជ្ញា បានជាគេត្រឡប់ទៅជាល្ងង់ល្ងើវិញ»។ យើងនៅតែមានខួរក្បាលដ៏មានឥទ្ធិពល។ សូមពិចារណាអំពីអ្វីៗទាំងអស់ដែលមនុស្សបានរកឃើញ និងបានបង្កើតឡើង។ ប៉ុន្តែ ការគិតរបស់យើងបានលេចចេញជារូបរាងដោយបំណងប្រាថ្នារបស់យើង។ នោះមានន័យថា យើងប្រើបញ្ញារបស់យើងដើម្បីបង្ហាញអំពីភាពត្រឹមត្រូវនៃសកម្មភាពបះបោររបស់យើង ឬបង្កើតវិធីផ្សេងទៀត ដើម្បីមើលទៅកាន់ពិភពលោកដែលមិនអើពើនឹងកាតព្វកិច្ចរបស់យើងចំពោះព្រះជាម្ចាស់។



Scripture is supreme INDD interior - Khmer 1.9.indd 94 14/8/26 3:56 in the afternoon

ហើយមិនត្រឹមតែហេតុផលរបស់យើង ដែលរងផលប៉ះពាល់នោះទេ ប៉ុន្តែ បំណងចិត្តរបស់យើងក៏រងផលប៉ះពាល់ផងដែរ។ ខ.២៤ ចែងថា៖ «ហេតុនោះបានជាព្រះទ្រង់ប្រគល់គេទៅឯសេចក្តីស្មោកគ្រោកតាមចិត្តគេប្រាថ្នាចង់បាន ឲ្យបានបង្អាប់ដល់រូបកាយគេទៅវិញទៅមក»។ សព្វថ្ងៃនេះ ក្តីសង្ឃឹម ភាពភ័យខ្លាចសេចក្តីប៉ងប្រាថ្នា និងអារម្មណ៍របស់យើងបានច្របូកច្របល់អស់ទៅហើយ។ យើងលែងមានអ្នកនាំផ្លូវទៅកាន់សេចក្តីពិត ឬសេចក្តីល្អដែលអាចទុកចិត្តបាន។ ត្រឹមតែជាអ្វីដែលធ្វើឲ្យយើងមានអារម្មណ៍ល្អ នោះមិនមែនមានន័យថា វាល្អនោះទេ។ ខ្ញុំបានឃើញមិត្តភក្តិជិតស្និទ្ធខ្ញុំពីរនាក់រងការឈឺចាប់ដោយសារជំងឺម្យ៉ាងហៅថា ជំងឺធុំអាហារ (anorexia ជាជំងឺម្យ៉ាងដែលរំខានដល់ការទទួលទានអាហារ។ ដូច្នេះអ្នកមានបញ្ហានេះមិនចង់ញ៉ាំអាហារ ហើយមានសភាពស្គមស្គាំង និងឈឺជាទម្ងន់)។ ពួកយើងបានយំចំពោះការឈឺចាប់ដែលពួកគេកំពុងតែឆ្លងកាត់។ ពួកគេមានអារម្មណ៍ថា ធាត់។ ប៉ុន្តែ អារម្មណ៍របស់ពួកគេមិនអាចទុកចិត្តបានទេ។ បើគ្មានអ្នកណាសួរពីអារម្មណ៍របស់ពួកគេទេ នោះពួកគេអាចនឹងបង្អត់ខ្លួនឯងរហូតដល់ស្លាប់។



Scripture is supreme INDD interior - Khmer 1.9.indd 95 14/8/26 3:56 in the afternoon

រឿងស្រដៀងគ្នានេះក៏អាចកើតឡើងនៅក្នុងក្រុមជំនុំផងដែរ។ ខ្ញុំស្គាល់យុវនារីម្នាក់ដែលមានបុរសម្នាក់បានទៅជួបនាងនៅក្រុមជំនុំ។ បុរសវ័យក្មេងនោះបានប្រាប់នាងថា ព្រះជាម្ចាស់បានមានបន្ទូលថា ពួកគេគួរតែរៀបការនឹងគ្នា។ ជាការល្អ យុវនារីម្នាក់នេះមានភាពក្លាហាននិយាយថា «ប៉ុន្តែ ព្រះជាម្ចាស់មិនបានមានបន្ទូលដូច្នោះមកកាន់ខ្ញុំផង!»

ខ្ញុំមិនគិតថា បុរសម្នាក់នោះមានចេតនាព្យាយាមបោកប្រាស់នាងទេ ទោះបីវាអាចទៅរួចក៏ដោយ។ ខ្ញុំសង្ស័យថា គាត់បានបកស្រាយសេចក្ដីប៉ងប្រាថ្នារបស់គាត់ថាជាសារមកពីព្រះទៅវិញ។ ប្រហែលជាគាត់កំពុងតែអធិស្ឋាន ហើយគាត់បន្តគិតអំពីស្ត្រីម្នាក់នេះ។ ដូច្នេះ គាត់ជឿថា ព្រះជាម្ចាស់កំពុងមានបន្ទូលថា នាងនិងគាត់គួរតែរស់នៅជាមួយគ្នា។ ចំពោះគាត់ ការនេះបានបញ្ជាក់ថា នោះគឺជាព្រះជាម្ចាស់បានមានបន្ទូលមកកាន់គាត់។ ប៉ុន្តែ បទពិសោធន៍របស់គាត់មិនគួរឲ្យទុកចិត្តនោះទេ។

មនុស្សខ្លះមានអារម្មណ៍ថា ទទួលនូវការត្រាស់ហៅឲ្យបម្រើព័ន្ធកិច្ចក្រុមជំនុំ។ ពិតណាស់ នៅក្រុមជំនុំមួយចំនួន ការត្រាស់ហៅគឺជាសេចក្ដីតម្រូវមួយ។ ប៉ុន្តែក្រុមជំនុំដែលឈ្លាសវៃនឹងធ្វើការល្បងលការត្រាស់



Scripture is supreme INDD interior - Khmer 1.9.indd 96 14/8/26 3:56 in the afternoon

ហៅនោះ។ ពួកគេសាកលមើលថាអ្នកនោះមានចរិតលក្ខណៈ និងអំណោយទានសម្រាប់តួនាទីដែរឬទេ។ ការមានបទពិសោធន៍ក្នុងការត្រាស់ហៅគឺមានតម្លៃណាស់ ប៉ុន្តែសេចក្តីតម្រូវដែលមានចែងនៅក្នុងព្រះគម្ពីរ គឺជាសិទ្ធិអំណាចកំពូលវិញ។

សិទ្ធិអំណាចកំពូលនៃព្រះគម្ពីរលើបទពិសោធន៍ផ្ទាល់ខ្លួនមិនមែនមានន័យថា យើងតែងតែព្រងើយកន្តើយនឹងបទពិសោធន៍នោះទេ។ ប៉ុន្តែ យើងត្រូវការព្រះគម្ពីរដើម្បីបកស្រាយអារម្មណ៍របស់យើង។ យើងអាចមានបទពិសោធន៍ពិតអំពីព្រះ ប៉ុន្តែនៅតែអាចនឹងយល់មិនបានត្រឹមត្រូវ។ ជាថ្មីម្តងទៀត នេះជាកន្លែងដែលសិទ្ធិអំណាចកំពូលនៃព្រះគម្ពីរមានសារៈសំខាន់ខ្លាំង។ ព្រះគម្ពីរបកស្រាយពីបទពិសោធន៍ មិនមែនបទពិសោធន៍បកស្រាយពីព្រះគម្ពីរនោះទេ។ នៅពេលដែលបទពិសោធន៍ និងព្រះគម្ពីរមិនស្របគ្នា នោះអាចបណ្តាលមកពីកត្តាពីរ៖ ទី១. លោកអ្នកយល់ខុសពីព្រះគម្ពីរ ទី២. លោកអ្នកយល់ខុសពីបទពិសោធន៍របស់លោកអ្នក។ កត្តាទាំងពីរ គឺអាចទៅរួច។ ដូច្នេះ សូមពិនិត្យមើលអ្វីដែលព្រះគម្ពីរបានចែងម្តងទៀត។ ប៉ុន្តែត្រូវប្រយ័ត្នព្រោះដូចដែលយើងដឹងហើយថា យើងអាច



Scripture is supreme INDD interior - Khmer 1.9.indd 97 14/8/26 3:56 in the afternoon

ផ្លាស់ប្តូរអត្ថន័យព្រះគម្ពីរ។ វាទំនងជាងដែលថា លោកអ្នកយល់ខុសពីបទពិសោធន៍របស់ខ្លួន។

សេចក្តីប៉ងប្រាថ្នាចង់ចាកចេញពីប្រពន្ធកូនរបស់លោកអ្នក មិនមែនជាអំណោយទាននោះទេ។ វាមិនបានមកជាមួយនឹងព្រះពររបស់ព្រះជាម្ចាស់នោះឡើយ តែវាជាសេចក្តីល្បួង និងជាការជំរុញចិត្តដែលមកពីអារក្សសាតាំង។ ភាពអស់សង្ឃឹមដែលធ្វើឲ្យនរណាម្នាក់ចង់បញ្ចប់ជីវិតរបស់ខ្លួនមិនបានបង្ហាញថា ច្បាប់គួរតែផ្លាស់ប្តូរនោះទេ។ ផ្ទុយទៅវិញ វាបង្ហាញថា មនុស្សដែលរងការឈឺចាប់ត្រូវការការកម្សាន្តចិត្ត និងសេចក្តីសង្ឃឹមដែលមកតាមរយៈដំណឹងល្អវិញ។

លោកគ្រូគង្វាល ជេ. ស៊ី. រ៉ាយល៍ (J. C. Ryle) ធ្លាប់បានលើកឡើងថា «លក្ខណៈចម្បងនៅក្នុងការផ្សាយដំណឹងល្អ *គឺជាសិទ្ធិអំណាចកំពូលនៃព្រះគម្ពីរបរិសុទ្ធ*។ ព្រះគម្ពីរគឺជាច្បាប់តែមួយគត់នៃសេចក្តីជំនឿ និងការអនុវត្តនៃសេចក្តីជំនឿ។ ព្រះគម្ពីរ គឺជាខ្នាតរង្វាស់តែមួយគត់នៃសេចក្តីពិត។ ហើយព្រះគម្ពីរគឺជាចៅក្រមតែមួយគត់ដែលកាត់ក្តីលើភាពចម្រូងចម្រាស»។ គាត់បានបន្តលើកឡើងទៀតថា៖



Scripture is supreme INDD interior - Khmer 1.9.indd 98 14/8/26 3:56 in the afternoon

«សិទ្ធិអំណាចកំពូលនៃព្រះគម្ពីរ គឺជាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់ប្រព័ន្ធរបស់យើង។ សូមបង្ហាញអ្វីដែលបានសរសេរចុះយ៉ាងច្បាស់លាស់នៅក្នុងសៀវភៅនោះដល់ពួកយើង ហើយទោះបីជាវាពិបាកទទួលយកសម្រាប់យើងក៏ដោយ ក៏យើងនឹងទទួលយកជឿលើ ហើយចុះចូលនឹងការនោះដែរ។ សូមបង្ហាញអស់ទាំងសេចក្ដីជំនឿរបស់យើងដែលទាស់ប្រឆាំងនឹងសៀវភៅនោះ ហើយទោះបីជាវាហាក់ដូចជាល្អ សមហេតុផល ស្រស់ស្អាត និងគួរឲ្យចង់បានក៏ដោយ ក៏យើងនឹងមិនទទួលយកវាឡើយ ទោះក្នុងតម្លៃណាក៏ដោយ។ សេចក្ដីបង្រៀននោះអាចមានការឯកភាពពីបិតានៃពួកជំនុំជំនាន់ដើម អ្នកប្រាជ្ញ និងអ្នកនិពន្ធខាងកាតូលិកផ្សេងៗទៀត។ សេចក្ដីបង្រៀននោះអាចនឹងទទួលបានគេកោតសរសើរដោយសារហេតុផល ទស្សនវិជ្ជា វិទ្យាសាស្ត្រ បទពិសោធន៍ខាងក្នុងប្រាជ្ញារបស់មនុស្ស ឬមនសិការសកលរបស់មនុស្សជាតិទាំងមូល។ ការនោះគ្មានន័យអ្វីទេ។ ផ្ទុយទៅវិញ ពួកគេបានផ្ដល់ឲ្យយើងនូវអត្ថបទព្រះគម្ពីរធម្មតាពីរបីប៉ុណ្ណោះ។ ប្រសិនបើអ្វីមួយមិនមាននៅក្នុងព្រះគម្ពីរទេ ហើយមិនអាចដកស្រង់ចេញពីព្រះគម្ពីរបានទេ មិនមានច្បាស់លាស់ ឬក៏វាមិនស្របនឹងព្រះគម្ពីរ នោះយើងនឹងមិនទទួលយកនោះឡើយ។ វាប្រៀបដូចជាផ្លែឈើដែលព្រះជាម្ចាស់ហាមឃាត់នោះដែរ ពោលគឺយើងមិនហ៊ាន



Scripture is supreme INDD interior - Khmer 1.9.indd 99 14/8/26 3:56 in the afternoon

> ប៉ះពាល់ទេ ក្រែងយើងត្រូវស្លាប់។ ជំនឿរបស់យើងពឹងផ្អែកទាំងស្រុងលើព្រះគម្ពីរ ឬសេចក្ដីពិតចេញពីព្រះគម្ពីរ។ ព្រះគម្ពីរ គឺជាថ្មដាហើយអ្វីៗផ្សេងទៀតប្រៀបដូចជាខ្សាច់វិញ»។[២០]

ប្រយោគចុងក្រោយរបស់លោកគ្រូ រ៉ាយល៍ សំដៅដល់រឿងប្រៀបប្រដូចដែលព្រះយេស៊ូវបានមានបន្ទូលនៅក្នុងកណ្ឌគម្ពីរ ម៉ាថាយ ៧:២៤-២៧៖

> «ដូច្នេះ អស់អ្នកណាដែលឮពាក្យរបស់ខ្ញុំទាំងនេះ ហើយប្រព្រឹត្តតាម ខ្ញុំនឹងធៀបអ្នកនោះដូចជាមនុស្សប៉ិនប្រយ័ត្ន ដែលសង់ផ្ទះខ្លួននៅលើថ្ម រួចភ្លៀងធ្លាក់មក ទឹកក៏ជន់ឡើង ហើយខ្យល់បក់ប៉ះនឹងផ្ទះនោះ តែមិនបានរលំទេ ពីព្រោះបានសង់នៅលើថ្ម ឯអស់អ្នកណាដែលឮពាក្យរបស់ខ្ញុំទាំងនេះ តែមិនប្រព្រឹត្តតាម អ្នកនោះត្រូវធៀបដូចជាមនុស្សល្ងង់ ដែលសង់ផ្ទះខ្លួននៅលើខ្សាច់វិញ រួចភ្លៀងធ្លាក់មក ទឹកក៏ជន់ឡើង ហើយខ្យល់បក់ប៉ះនឹងផ្ទះនោះ ផ្ទះនោះក៏រលំទៅ ហើយមានការខូចខាតជាធំ»។

---

២០ លោក J. C. Ryle, "Evangelical Religion," *Knots Untied* (London: Hunt, ឆ្នាំ១៨៧៧, កែសម្រួលលើកទី១០, ឆ្នាំ១៨៨៥), ទំព័រ៣-៤។ ច្បាប់ដើម។



Scripture is supreme INDD interior - Khmer 1.9.indd 100 14/8/26 3:56 in the afternoon

ប្រាជ្ញាដ៏ពិតមានន័យថា យើងអនុវត្តតាមបន្ទូលរបស់ព្រះយេស៊ូវ។ ទំនុកចិត្តពិតប្រាកដទាំងនៅក្នុងការរស់នៅ និង នៅក្នុងសេចក្តីស្លាប់ដែលកើតចេញមកពីការសង់ជីវិតរបស់លោកអ្នកលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ប៉ុណ្ណោះ។ ប្រភពផ្សេងៗទៀតនៃសិទ្ធិអំណាចអាចមានប្រយោជន៍សម្រាប់ជីវិតយើង។ ប៉ុន្តែ ប្រសិនបើលោកអ្នកសង់ជីវិតរបស់លោកអ្នកលើប្រភពទាំងនោះ នោះវាប្រៀបដូចជាការសង់ផ្ទះលើខ្សាច់ដូច្នោះដែរ។ ប្រភពទាំងនោះនឹងមិនអាចធន់នឹងព្យុះនៃជីវិត ឬទឹកជំនន់នៃសេចក្តីស្លាប់បានឡើយ។

សិទ្ធិអំណាចកំពូលនៃព្រះគម្ពីរមិនមែនជាច្បាប់ដែលដាក់មកលើយើង ដោយមេដឹកនាំផ្តាច់ការណាម្នាក់នោះទេ។ ពាក្យពេចន៍នៅក្នុងព្រះគម្ពីរ គឺជាព្រះបន្ទូលរបស់ព្រះយេស៊ូវដ៏ជាអ្នកគង្វាលដ៏ល្អ ដែលទ្រង់បានលះបង់ព្រះជន្មសម្រាប់រាស្ត្រទ្រង់ (យ៉ូហាន ១០:១១)។ ហើយសិទ្ធិអំណាចកំពូលនៃព្រះគម្ពីរ គឺជាថ្មដែលយើងអាចសាងសង់ដោយទំនុកចិត្ត និងជាថ្មដែលផ្តល់នូវគ្រឹះដ៏រឹងមាំសម្រាប់អនាគត។



Scripture is supreme INDD interior - Khmer 1.9.indd 101 14/8/26 3:56 in the afternoon

## ការឆ្លុះបញ្ចាំង ឬការពិភាក្សា

១) តើយើងអាចគោរពសិទ្ធិអំណាចនៃហេតុផល បទពិសោធន៍ ប្រពៃណី និងព្រះគម្ពីរដោយរបៀបណា? តើសិទ្ធិអំណាចមួយណាដែលជាធម្មតាពឹងផ្អែកភាគច្រើនទាំងនៅក្នុងគ្រួសារ ការងារ ឬក្រុមជំនុំរបស់លោកអ្នក?

២) តើអ្វីជាបញ្ហាដ៏ចម្បងជាងគេនៅក្នុងចំណោមបញ្ហាចម្បងផ្សេងទៀតក្នុងអំឡុងសម័យកំណែទម្រង់? តើវានៅតែជាបញ្ហាឬទេនៅក្នុងបរិបទសព្វថ្ងៃនេះ?

៣) តើលោកអ្នកអាចគិតពីបញ្ហាខាងសីលធម៌មួយដែលគេកំពុងតែពិភាក្សាសព្វថ្ងៃនេះដែលពឹងផ្អែកជាចម្បងលើមនោសញ្ចេតនា និងអារម្មណ៍បានឬទេ? ហេតុអ្វីបានជាធ្វើដូច្នេះខុស? តើសៀវភៅនេះបានផ្លាស់ប្តូរការយល់ដឹងរបស់លោកអ្នកស្តីពីបញ្ហា ដែលបានលើកយកមកពិភាក្សាយ៉ាងដូចម្តេចខ្លះ? តើផ្នែកណាខ្លះនៃព្រះគម្ពីរដែលហាក់ដូចជាដោះស្រាយបញ្ហាខាងលើនេះបានច្បាស់លាស់បំផុត?



Scripture is supreme INDD interior - Khmer 1.9.indd 102 14/8/26 3:56 in the afternoon

ទី៥

# តើសិទ្ធិអំណាចកំពូលនៃព្រះគម្ពីរដំណើរការយ៉ាងដូចម្ដេច?

## សិទ្ធិអំណាចដ៏មានឥទ្ធិពល

សិទ្ធិអំណាចកំពូលនៃព្រះគម្ពីរ គឺជាកិរិយាសព្ទ មិនមែនជានាមនោះទេ។ មែនហើយ! ខ្ញុំដឹងថា វាមិនសូវត្រូវនឹងវេយ្យាករណ៍ពីព្រោះ «សិទ្ធិអំណាចកំពូល» តាមពិតទៅគឺជានាមអរូបី។ ប៉ុន្តែ វាគឺជាទេវវិទ្យាដ៏ល្អ។ ព្រះបន្ទូលមានព្រះជន្មគង់នៅហើយសកម្មផង។ ព្រះជាម្ចាស់កំពុងផ្លាស់ប្ដូរជីវិតរបស់យើងតាមរយៈដំណើរការនៃព្រះបន្ទូល ទ្រង់ស្ដារសិទ្ធិអំណាចកំពូលរបស់ទ្រង់ដែលផ្ដល់ដោយព្រះជន្មទ្រង់មកលើដួងចិត្តយើងឡើងវិញ។

គេអាចគិតអំពីសិទ្ធិអំណាចកំពូលនៃព្រះគម្ពីរក្នុងទម្រង់អសកម្ម ដែលប្រៀបដូចជាព្រះគម្ពីរគឺជាវចនានុក្រមមួយក្បាល ឬជាសៀវភៅច្បាប់មួយក្បាលប៉ុណ្ណោះ។ យើងប្រហែលជាគិតថា ព្រះគម្ពីរគ្រាន់តែ



Scripture is supreme INDD interior - Khmer 1.9.indd 103 14/8/26 3:56 in the afternoon

ផ្ដល់ព័ត៌មានតែប៉ុណ្ណោះ ប៉ុន្ដែគ្មានអ្វីលើសពីនោះទេ។ មែនហើយ យើងអាចមើលឃើញថា ព្រះគម្ពីរមានផ្ទុកនូវព័ត៌មានសំខាន់ៗ ពោលគឺជាព័ត៌មានមកពីព្រះជាម្ចាស់ដែលមានសក្ដានុពលក្នុងការផ្លាស់ប្ដូរជីវិតបាន ប៉ុន្ដែទោះជាយ៉ាងណា នោះនៅតែជាព័ត៌មានដដែល។ ពេលខ្លះ វាហាក់ដូចជាយើងទៅវិញទេជាអ្នកសកម្មនោះ។ យើងអានព្រះគម្ពីររបស់យើង ហើយប្រមូលព័ត៌មាន ហើយប្រហែលជាយកទៅអនុវត្តទៀតផង។ ប៉ុន្ដែ យើងមើលឃើញព្រះគម្ពីរថាអសកម្មវិញ។

ប៉ុន្ដែ សូមចាំថា៖ «សិទ្ធិអំណាចកំពូលនៃព្រះគម្ពីរ» មានន័យថា ជាសិទ្ធិអំណាចកំពូលនៃព្រះជាម្ចាស់ដែលកំពុងមានបន្ទូល និងកំពុងតែធ្វើសកម្មភាពតាមរយៈព្រះគម្ពីរ។ ហើយព្រះជាម្ចាស់មិនមែនអសកម្មនោះទេ។ ព្រះជាម្ចាស់មិនគ្រាន់តែគង់នៅតែមួយកន្លែង ដើម្បីរង់ចាំឲ្យយើងសួរនូវសំណួរអំពីព្រះបន្ទូលរបស់ទ្រង់ប៉ុណ្ណោះទេ។

## ព្រះជាម្ចាស់នៅតែមានបន្ទូលតាមរយៈព្រះគម្ពីរ

ព្រះវិញ្ញាណបរិសុទ្ធមិនត្រឹមតែសកម្មនៅពេលដែលគេសរសេរព្រះគម្ពីរឡើងប៉ុណ្ណោះឡើយ។ ប៉ុន្ដែ ព្រះអង្គក៏សកម្មនៅសព្វថ្ងៃនេះ នៅពេលដែលយើងអាន និង



Scripture is supreme INDD interior - Khmer 1.9.indd 104 14/8/26 3:56 in the afternoon

អធិប្បាយតាមព្រះគម្ពីរផងដែរ។ ព្រះវិញ្ញាណស្វែងរកយើងតាមរយៈព្រះបន្ទូល។ ព្រះវិញ្ញាណបើកភ្នែកខ្វាក់របស់យើងឲ្យមើលឃើញ ហើយធ្វើឲ្យចិត្តដ៏ត្រជាក់របស់យើងឲ្យរលាយ ធ្វើឲ្យយើងអាចស្ដាប់ឮព្រះសូរសៀងព្រះជាម្ចាស់ ហើយឆ្លើយតបដោយជំនឿ។ នេះជារបៀបដែលព្រះទ្រង់បានប្រទានជីវិតខាងឯវិញ្ញាណជាលើកដំបូងដល់មនុស្ស។ ដំណើរការនេះត្រូវគេហៅថា «ការកើតជាថ្មី» ឬ «កំណើតថ្មី» ។ ហើយព្រះអង្គបន្តធ្វើដូច្នោះសម្រាប់យើងជាគ្រីស្ទបរិស័ទ នៅពេលដែលយើងអានព្រះគម្ពីរដោយចិត្តបន្ទាបខ្លួន។ លោកគ្រូ បាវីក (Bavinck) បានលើកឡើងថា៖

> ព្រះគម្ពីរមិនសុំជំនួយពីនរណាម្នាក់ ដើម្បីបង្កើនការទទួលស្គាល់ និងការគ្រប់គ្រងនោះឡើយ។ ព្រះគម្ពីរក៏មិនត្រូវការអំណាចដ៏ខ្លាំងពូកែពីរដ្ឋាភិបាលណាមួយនោះដែរ។ ព្រះគម្ពីរមិនត្រូវការការគាំទ្រពីក្រុមជំនុំនោះទេ។ ព្រះគម្ពីរក៏មិនប្រើប្រាស់អំណាច និងការស៊ើបអង្កេតនោះដែរ។ ព្រះគម្ពីរមិនចង់គ្រប់គ្រងដោយប្រើកម្លាំង និងដោយហិង្សានោះទេ ប៉ុន្តែព្រះគម្ពីរស្វែងរកការទទួលស្គាល់ ដោយស្ម័គ្រពីចិត្ត និងដោយចេញពីឆន្ទៈ។ ដូច្នេះហើយ ព្រះគម្ពីរអាចទទួលបានការទទួលស្គាល់ តាមរយៈកិច្ចការនៃព្រះវិញ្ញាណ



Scripture is supreme INDD interior - Khmer 1.9.indd 105 14/8/26 3:56 in the afternoon

> បរិសុទ្ធបាន។ ព្រះគម្ពីរការពារសិទ្ធិអំណាចខ្លួនឯងផ្ទាល់។[២១]

វាមិនគ្រាន់តែការពិត កាលពីអតីតកាលនោះទេ ដែលព្រះជាម្ចាស់បានប្រើប្រាស់អ្នកនិពន្ធជាច្រើនដើម្បីនឹងសរសេរគំនិតរបស់ទ្រង់ចុះនៅក្នុងព្រះគម្ពីរ។ ហើយ យើង ក៏នៅ តែ ឃើញ ថែម ទៀត លើ ការ នេះ។ សូម្បីតែសព្វថ្ងៃនេះ ព្រះជាម្ចាស់ក៏នៅតែមានបន្ទូលតាមរយៈព្រះគម្ពីរក្នុងរបៀបមួយដ៏មានឥទ្ធិពល និងមានទំនាក់ទំនងជាមួយនឹងយើងដោយផ្ទាល់ផងដែរ។ កណ្ឌគម្ពីរ ហេព្រើរ ៣:៧-១១ បានដកស្រង់ចេញពីកណ្ឌគម្ពីរ ទំនុកតម្កើង ជំពូក៩៥ ហើយសន្និដ្ឋានថា នោះជាព្រះបន្ទូលនៃព្រះ។ គ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលនៅត្រង់ចំណុចនេះទេ។ ប៉ុន្តែ កណ្ឌគម្ពីរហេព្រើរបានផ្ដើមសម្រង់សម្ដីនោះ ដោយពាក្យទាំងនេះថា៖ «ហេតុនោះព្រះវិញ្ញាណបរិសុទ្ធមានបន្ទូលថា...» (គកស១៦)។ សូមកត់ចំណាំអំពីការប្រើកិរិយាសព្ទបច្ចុប្បន្នកាល។

២១ លោក Herman Bavinck, *Reformed Dogmatics, ភាគ១៖ Prolegomena,* កែសម្រួលដោយ៖ លោក John Bolt, បកប្រែដោយ៖ លោក John Vriend (Grand Rapids, MI: Baker Academic, ឆ្នាំ២០០៣), ទំព័រ៤៦៣។



Scripture is supreme INDD interior - Khmer 1.9.indd 106 14/8/26 3:56 in the afternoon

កណ្ឌគម្ពីរហេព្រើរមិនមែនផ្ដើមថា៖ «ហេតុនោះ ព្រះវិញ្ញាណបរិសុទ្ធធ្លាប់បានមានបន្ទូលកាលពីអតីតកាលថា...» នោះទេ។ ប៉ុន្តែ គឺដូច្នេះវិញថា៖ «ហេតុនោះ ព្រះវិញ្ញាណបរិសុទ្ធមានបន្ទូល»–នៅទីនេះ ឥឡូវនេះ។ នេះហើយជាមូលហេតុដែលកណ្ឌគម្ពីរហេព្រើរចែងអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ថា «រស់នៅ ហើយពូកែ (សកម្ម)» (ហេព្រើរ ៤:១២)។ វាមិនមែនថា ព្រះជាម្ចាស់គ្រាន់តែមានបន្ទូលទៅកាន់មនុស្សជាតិកាលពីអតីតកាលនោះទេ ទោះបើនេះជាការពិតក៏ដោយ។ រាល់ពេលដែលយើងអាន ឬអធិប្បាយចេញពីព្រះគម្ពីរ នោះយើងប្រកាសថា ព្រះជាម្ចាស់កំពុងតែមានបន្ទូលហើយ។ ខណៈនោះ ព្រះជាម្ចាស់កំពុងតែមានបន្ទូលមកកាន់លោកអ្នកដោយផ្ទាល់ តាមរយៈព្រះបន្ទូលទ្រង់ដោយព្រះវិញ្ញាណរបស់ទ្រង់។

## ព្រះជាម្ចាស់នៅតែធ្វើការតាមរយៈបទគម្ពីរ

ព្រះជាម្ចាស់មិនត្រឹមតែនៅមានបន្ទូលតាមរយៈព្រះគម្ពីរនោះទេ ប៉ុន្តែព្រះអង្គក៏នៅតែធ្វើការតាមរយៈព្រះបន្ទូលទ្រង់ផងដែរ។ នេះជារបៀបដែលសាច់រឿងបានចាប់ផ្ដើមឡើង៖ «ឯផែនដីបានខូច ហើយនៅទទេ មានសុទ្ធតែងងឹតនៅគ្របលើជម្រៅទឹក» (លោកុប្បត្តិ ១:២)។ ប៉ុន្តែ បន្ទាប់មកសាច់រឿងនោះបន្ថែមទៀត



Scripture is supreme INDD interior - Khmer 1.9.indd 107 14/8/26 3:56 in the afternoon

ថា «ព្រះវិញ្ញាណនៃព្រះក៏រេរានៅពីលើទឹក»។ ឃ្លានេះ គឺពោរពេញដោយលទ្ធភាពជាច្រើនដែលអាចកើតមានឡើង។ យើងអាចនិយាយបានថា មានអ្វីមួយអាចនឹងកើតមានឡើង។ បន្ទាប់មក មានអ្វីមួយពិតជាកើតមានឡើងមែនគឺៈ ព្រះជាម្ចាស់មានបន្ទូល។ កណ្ឌគម្ពីរ លោកុប្បត្តិ ១:៣ បានចែងថាៈ «នោះព្រះទ្រង់មានបន្ទូលថា ចូរឲ្យមានពន្លឺឡើង ដូច្នេះពន្លឺក៏មានឡើង»។ ព្រះជាម្ចាស់ធ្វើការតាមរយៈព្រះបន្ទូលទ្រង់។ ព្រះអង្គមានបន្ទូលមួយព្រះឱស្ឋ នោះពន្លឺក៏មកជំនួសភាពងងឹត។ ព្រះជាម្ចាស់ញែកពន្លឺពីងងឹតចេញ ដោយដាក់ឈ្មោះពន្លឺថាជា «ថ្ងៃ» និងងងឹតថាជា «យប់» (លោកុប្បត្តិ ១:៤-៥)។ ព្រះជាម្ចាស់បាននាំមកនូវសណ្ដាប់ធ្នាប់ជំនួសឲ្យភាពរញ៉េរញ៉ៃតាមរយៈព្រះបន្ទូលទ្រង់។ យើងមើលឃើញគំរូដូចគ្នានេះនៅថ្ងៃទី១ ដល់ថ្ងៃទី៣ នៃការបង្កើត។ ព្រះជាម្ចាស់មានព្រះបន្ទូល ហើយភាពគ្មានរូបរាងនៃអ្វីៗដែលព្រះជាម្ចាស់បានបង្កើត ដែលបានរៀបចំឲ្យមានសណ្ដាប់ធ្នាប់ និងដាក់ឈ្មោះឲ្យវា។ នៅថ្ងៃទី៤ ដល់ថ្ងៃទី៦ គំរូនោះផ្លាស់ប្ដូរបន្តិចបន្តួច។ ឥឡូវនេះ ព្រះជាម្ចាស់កំពុងតែបំពេញភាពទទេស្អាតនៃអ្វីៗដែលព្រះជាម្ចាស់បានបង្កើតដោយផ្កាយ ព្រះចន្ទ ត្រី សត្វស្លាប សត្វពាហនៈ និងមនុស្សជាដើម។ ប៉ុន្តែ ជាថ្មីម្ដងទៀត ព្រះអង្គធ្វើបែប



Scripture is supreme INDD interior - Khmer 1.9.indd 108 14/8/26 3:56 in the afternoon

នេះតាមរយៈព្រះបន្ទូលរបស់ទ្រង់។ ព្រះអង្គមានបន្ទូល ហើយពិភពលោកក៏បានកើតមានឡើង។

គំរូនេះបានកើតឡើងជាច្រើនលើកច្រើនសារ នៅក្នុងដំណើររឿងនៃព្រះគម្ពីរ។ ព្រះជាម្ចាស់ប្រទាន ជីវិតដល់រាស្ត្រទ្រង់តាមរយៈព្រះបន្ទូលទ្រង់។ ព្រះអង្គ បង្កើតប្រវត្តិសាស្ត្រតាមរយៈហោរារបស់ទ្រង់។ ព្រះអង្គ ចម្រើននគររបស់ព្រះគ្រីស្ទឡើង តាមរយៈការប្រកាស ដំណឹងល្អ។ ព្រះអង្គបាននាំជីវិតទៅកាន់ដួងចិត្តដែល បានស្លាប់ខាងឯវិញ្ញាណ តាមរយៈព្រះបន្ទូលទ្រង់។ ពិតណាស់ ការប្រែចិត្តជឿ គឺប្រៀបដូចជាការបង្កើត របស់ព្រះជាម្ចាស់ផងដែរ។ កណ្ឌគម្ពីរ ២កូរិនថូស ៤:៥-៦ សាវ័ក ប៉ុល បានលើកឡើងថា «យើងខ្ញុំមិន ប្រកាសប្រាប់ពីខ្លួនយើងខ្ញុំទេ គឺពីព្រះគ្រីស្ទយេស៊ូវ ជា ព្រះអម្ចាស់វិញ ហើយក៏រាប់ខ្លួនយើងខ្ញុំ ថាជាបាវបំរើ របស់អ្នករាល់គ្នា ដោយព្រោះព្រះយេស៊ូវដែរ ដ្បិតគឺ ជាព្រះ ដែលមានបន្ទូលបង្គាប់ ឲ្យមានពន្លឺភ្លឺចេញពី សេចក្ដីងងឹត ទ្រង់បានបំភ្លឺមកក្នុងចិត្តយើងខ្ញុំ ឲ្យយើង ខ្ញុំមានរស្មីពន្លឺនៃដំណើរស្គាល់សិរីល្អរបស់ព្រះ ដែល នៅព្រះភក្ត្រនៃព្រះយេស៊ូវគ្រីស្ទ»។ ដូចជាព្រះជាម្ចាស់ បានមានព្រះបន្ទូល ដើម្បីបង្កើតពន្លឺដល់ផែនដីដែល ពេញដោយភាពងងឹតនេះដែរ ព្រះជាម្ចាស់ក៏មានបន្ទូល



Scripture is supreme INDD interior - Khmer 1.9.indd 109 14/8/26 3:56 in the afternoon

ពីសារនៃដំណឹងល្អ ដើម្បីនាំពន្លឺដល់សេចក្ដីងងឹតដែលនៅក្នុងចិត្តយើងផងដែរ។ ព្រះអង្គបានរៀបចំភាពរញ៉េរញ៉ៃរបស់យើងឲ្យមានសណ្ដាប់ធ្នាប់ ហើយបំពេញភាពទទេស្អាតរបស់យើងដោយព្រះបន្ទូលទ្រង់ នៅពេលដែលយើងឮព្រះបន្ទូលដោយអំណាចនៃព្រះវិញ្ញាណ។

ព្រះជាម្ចាស់តែងតែធ្វើការតាមរយៈព្រះបន្ទូលទ្រង់។

ព្រះសូរសៀងរបស់ព្រះអម្ចាស់នៅលើផ្ទៃទឹក

កណ្ឌគម្ពីរទំនុកតម្កើង ជំពូក២៩ គឺជាការពណ៌នាដ៏អស្ចារ្យនៃសកម្មភាពនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់។

១ នែ អស់ទាំងកូននៃព្រះដ៏មានឥទ្ធិឫទ្ធីអើយ
ចូរសរសើរព្រះយេហូវ៉ា
ចូរសរសើរព្រះយេហូវ៉ាថា
ទ្រង់មានសិរីល្អ ហើយនឹងព្រះចេស្ដា
២ ចូរសរសើរពីសិរីល្អនៃព្រះយេហូវ៉ាឲ្យសមនឹងព្រះនាមទ្រង់
ចូរពាក់គ្រឿងលម្អបរិសុទ្ធ នាំគ្នាថ្វាយបង្គំដល់
ព្រះយេហូវ៉ាចុះ។
៣ ព្រះសូរសៀងនៃព្រះយេហូវ៉ាខ្ទរតាមទឹក
ព្រះដ៏មានសិរីល្អទ្រង់បញ្ចេញផ្គរលាន់
គឺព្រះយេហូវ៉ាទ្រង់គង់លើទឹកធំ
៤ ព្រះសូរសៀងរបស់ព្រះយេហូវ៉ាមានអំណាច



Scripture is supreme INDD interior - Khmer 1.9.indd 110 14/8/26 3:56 in the afternoon

ព្រះសូរសៀងនៃព្រះយេហូវ៉ាមានឫទ្ធានុភាព
៥ ព្រះសូរសៀងរបស់ព្រះយេហូវ៉ាក៏បំបាក់ដើមតាត្រៅ
អើ ព្រះយេហូវ៉ាទ្រង់បំបាក់កំទេចដើមតាត្រៅ
នៅភ្នំល្បាណូន
៦ ទ្រង់បណ្តាលឲ្យដើមទាំងនោះបោលលោត ដូចជាកូនគោ
ហើយឲ្យភ្នំល្បាណូន នឹងភ្នំស៊ីរានបោល ដូចជាគោព្រៃស្ទាវ
៧ ព្រះសូរសៀងនៃព្រះយេហូវ៉ាធ្វើឲ្យមាន
អណ្តាតភ្លើងផុសឡើង
៨ ព្រះសូរសៀងរបស់ព្រះយេហូវ៉ាធ្វើឲ្យទីរហោស្ថានញ័រកក្រើក
ព្រះយេហូវ៉ាទ្រង់អង្រួនទីរហោស្ថានកាដេស
៩ ព្រះសូរសៀងរបស់ព្រះយេហូវ៉ាធ្វើឲ្យក្តាន់ញី សំរាលកូនមក
ក៏ជំរុះស្លឹកឈើនៅព្រៃអស់រលីង
ហើយនៅក្នុងព្រះវិហារនៃទ្រង់ នោះសព្វសារពើ
ក៏បន្លឺឡើងថា «ស្រីសួស្តី»
១០ ព្រះយេហូវ៉ាទ្រង់បានគង់នៅវេលាជំនន់លោកីយ៍
អើ ព្រះយេហូវ៉ាទ្រង់គង់ជាព្រះមហាក្សត្រ
នៅអស់កល្បជានិច្ច
១១ ព្រះយេហូវ៉ាទ្រង់នឹងចម្រើនកម្លាំងដល់រាស្ត្រទ្រង់
ព្រះយេហូវ៉ាទ្រង់នឹងប្រទានពរដល់រាស្ត្រទ្រង់
ឲ្យបានសេចក្តីសុខសាន្តត្រាណ។

កណ្ឌគម្ពីរ ទំនុកតម្កើង ជំពូក២៩នេះ ចាប់ផ្តើមដោយការអំពាវនាវឲ្យថ្វាយសិរីល្អដល់ព្រះអម្ចាស់ (ខ.១-២)។ ការអំពាវនាវនេះ គឺជាលទ្ធផលនៃឫទ្ធានុភាព និងភាពអស្ចារ្យនៃព្រះបន្ទូលព្រះជាម្ចាស់ (ខ.៤) ដែលបានពណ៌នាថាជា ផ្គរលាន់ (ខ.៣)។



Scripture is supreme INDD interior - Khmer 1.9.indd 111 14/8/26 3:56 in the afternoon

«ទឹកធំ» នៅក្នុង ខ.៣ ទំនងជាសំដៅទៅលើទឹកដែលគ្មានសណ្ដាប់ធ្នាប់នៃការបង្កើតនៅក្នុងកណ្ឌគម្ពីរលោកុប្បត្តិ ១:២។ ព្រះជាម្ចាស់អាចគ្រប់គ្រងទឹកទាំងនោះតាមរយៈព្រះបន្ទូលទ្រង់។ ព្រះយេស៊ូវបានធ្វើដូច្នេះនៅពេលដែលទ្រង់មានបន្ទូលទៅកាន់រលក ហើយរលកក៏បានស្ងប់ភ្លាម (ម៉ាកុស ៤:៣៩)។ ឫទ្ធានុភាពនៅក្នុងព្រះបន្ទូលទ្រង់ គឺជាឧបករណ៍ដែលព្រះអង្គប្រើដើម្បីធ្វើការនៅក្នុងពិភពលោកនេះ។ បន្ទាប់មក អ្នកនិពន្ធកណ្ឌគម្ពីរទំនុកតម្កើងប្រើឧទាហរណ៍ស្ដីពីការរញ្ជួយដី។ ដើមឈើបានបំបាក់ដូចជាមែកឈើតូចៗ (ខ.៥, ៩) ហើយប្រជាជាតិទាំងមូលត្រូវបានកក្រើកដូចជាពួកគេកំពុងបំបោលកូនគោ (ខ.៦ និងខ.៨)។ ដូច្នេះក្នុងចំណោមរាស្ត្ររបស់ព្រះជាម្ចាស់ ព្រះបន្ទូលទ្រង់នាំមកនូវការសរសើរតម្កើង៖ «នៅក្នុងព្រះវិហារនៃទ្រង់នោះសព្វសារពើ ក៏បន្លឺឡើងថា «ស្រីសួស្តី» (ខ.៩)។

នៅចុងបញ្ចប់នៃកណ្ឌគម្ពីរទំនុកតម្កើងនេះ ព្រះបានធ្វើឲ្យទឹកដ៏ច្របូកច្របល់ប្រែជាស្ងប់ ហើយបានទាក់ទាញរាស្ត្ររបស់ទ្រង់តាមរយៈព្រះបន្ទូលទ្រង់។ នេះជារបៀបដែលព្រះជាម្ចាស់ជាក្សត្រនៅក្នុងពិភពលោករបស់ទ្រង់។ ដូច្នេះ ខ.១០ ចែងថា «ព្រះយេហូវ៉ាទ្រង់បានគង់នៅវេលាជំនន់លោកីយ៍ អើ ព្រះយេហូវ៉ា



Scripture is supreme INDD interior - Khmer 1.9.indd 112 14/8/26 3:56 in the afternoon

ទ្រង់គង់ជាព្រះមហាក្សត្រនៅអស់កល្បជានិច្ច» ។ នេះជាដំណឹងល្អសម្រាប់រាស្ត្ររបស់ទ្រង់ ពីព្រោះភាពជាក្សត្ររបស់ព្រះជាម្ចាស់តាមរយៈព្រះបន្ទូលនៃព្រះនាំមកនូវកម្លាំង ព្រះពរ និងសេចក្ដីសុខសាន្ត (ខ.១១)។

ចំណុចសំខាន់សម្រាប់យើងនោះគឺថា ព្រះជាម្ចាស់ធ្វើការតាមរយៈព្រះបន្ទូលទ្រង់ ដ្បិតតាមរយៈព្រះបន្ទូលរបស់ទ្រង់ គឺព្រះជាម្ចាស់ស្ដារនូវភាពជាក្សត្រដែលប្រកបដោយសេចក្ដីស្រឡាញ់នៃទ្រង់ឡើងវិញ។

ការមួយដែលព្រះជាម្ចាស់ធ្វើតាមរយៈព្រះបន្ទូលទ្រង់ គឺផ្ដល់ព័ត៌មានដល់យើង។ ព្រះបន្ទូលទ្រង់គឺជាសេចក្ដីពិត (យ៉ូហាន ១៧:១៧)។ ព្រះអង្គមានបន្ទូលប្រាប់យើងអំពីចរិតលក្ខណៈរបស់ទ្រង់។ ព្រះអង្គមានបន្ទូលអំពីភាពបរិសុទ្ធ ចេស្ដា ឫទ្ធានុភាព សេចក្ដីស្រឡាញ់ និងសេចក្ដីយុត្តិធម៌របស់ទ្រង់។ ព្រះអង្គមានបន្ទូលប្រាប់សាច់រឿងអំពីរបៀបដែលព្រះអង្គបានរក្សាសេចក្ដីសង្គ្រោះរបស់យើងតាមរយៈការយកកំណើតជាមនុស្ស ការមានព្រះជន្មរស់នៅ ការសុគត ការមានព្រះជន្មរស់ឡើងវិញ និងការយាងទៅឯស្ថានសួគ៌របស់ព្រះគ្រីស្ទវិញ។ ព្រះជាម្ចាស់មានបន្ទូលប្រាប់យើងថា យើងត្រូវឆ្លើយតបដោយជំនឿ និងការប្រែចិត្ត។ ព្រះអង្គ



Scripture is supreme INDD interior - Khmer 1.9.indd 113 14/8/26 3:56 in the afternoon

មានបន្ទូលប្រាប់យើងអំពីអាកប្បកិរិយាដែលរាស្ត្រទ្រង់ដែលព្រះអង្គត្រូវមាន។

ប៉ុន្តែ ព្រះបន្ទូលព្រះជាម្ចាស់ធ្វើការច្រើនជាងការដែលគ្រាន់តែផ្តល់ព័ត៌មានដល់យើងទៅទៀត។ តាមរយៈព្រះបន្ទូលទ្រង់៖

- ព្រះជាម្ចាស់នាំមកនូវជីវិតដល់ព្រលឹងដែលស្លាប់។
- ព្រះជាម្ចាស់ធានាដល់រាស្ត្ររបស់ទ្រង់។
- ព្រះជាម្ចាស់នាំគ្រីស្ទបរិស័ទដែលវង្វេងចេញឲ្យត្រឡប់មកវិញ។
- ព្រះជាម្ចាស់ផ្តល់កម្លាំងដល់រាស្ត្រទ្រង់សម្រាប់ការបម្រើ។
- ព្រះជាម្ចាស់បន្ទាបអ្នកខ្លាំងពូកែចុះ ហើយលើកអ្នកតូចទាបឡើង។
- ព្រះជាម្ចាស់ស្តារព្រះរាជ្យរបស់ទ្រង់ឡើងវិញ។

ដូច្នេះ សិទ្ធិអំណាចកំពូលនៃព្រះគម្ពីរមិនមែនជាគំនិតអសកម្មនោះទេ។ ព្រះគម្ពីរ គឺជាប្រភពនៃសេចក្តីពិតដែលមានសិទ្ធិអំណាចកំពូល ប៉ុន្តែព្រះគម្ពីរ គឺលើសជាងវចនានុក្រមដ៏អស្ចារ្យ ឬសព្វវចនាធិប្បាយ



Scripture is supreme INDD interior - Khmer 1.9.indd 114 14/8/26 3:56 in the afternoon

មួយក្បាលទៅទៀត (encyclopaedia)។ សិទ្ធិអំណាចកំពូលនៃព្រះគម្ពីរក៏ពណ៌នាអំពីចលនាដ៏សកម្មមួយផងដែរ។ សិទ្ធិអំណាចកំពូលនេះ ពណ៌នាអំពីរបៀបដែលព្រះជាម្ចាស់កំពុងតែស្អាងរាជ្យទ្រង់ឡើងវិញលើរាស្ត្ររបស់ទ្រង់តាមរយៈព្រះបន្ទូលទ្រង់។

អ្វីដែលសំខាន់នោះគឺថា *ព្រះជាម្ចាស់កំពុងតាំងអង្គទ្រង់ជាកំពូលក្នុងចិត្តរបស់យើងតាមរយៈព្រះគម្ពីរ*។ ព្រះជាម្ចាស់ទ្រង់ផ្លុំខ្យល់ជីវិតចូលក្នុងចិត្តយើងតាមរយៈព្រះបន្ទូល និងព្រះចេស្ដានៃព្រះវិញ្ញាណទ្រង់។ ព្រះវិញ្ញាណបានប្រទានជីវិតថ្មីក្នុងការឆ្លើយតបថ្មីចំពោះបទគម្ពីរ។ យើងមានការយល់ដឹង និងបំណងចិត្តថ្មីអំពីព្រះជាម្ចាស់ក្នុងការស្ដាប់បង្គាប់ទ្រង់ តាមរយៈកំណើតថ្មីនេះ។ បំណងចិត្តថ្មីនេះ ទទួលបានកម្លាំងពីការអាន និងការស្ដាប់ព្រះបន្ទូល។ តាមរយៈព្រះបន្ទូលយើងស្ដាប់ឮព្រះសូរសៀងរបស់ព្រះគ្រីស្ទ ទ្រង់បញ្ជាក់ប្រាប់យើងអំពីព្រះគុណដល់យើង។ យើងចាប់ផ្ដើមទទួលអារម្មណ៍ថា យើងជាសមាជិកម្នាក់នៃគ្រួសាររបស់ព្រះ។ តាមរយៈព្រះបន្ទូល យើងមានអារម្មណ៍ថា យើងមានទំនាក់ទំនងជាមួយនឹងព្រះជាម្ចាស់តាមរយៈព្រះគ្រីស្ទ។ ជាលទ្ធផល យើងមានកម្លាំងក្នុងការបម្រើទ្រង់។ ព្រះបន្ទូលបង្ហាញឲ្យយើងឃើញពីអំពើ



Scripture is supreme INDD interior - Khmer 1.9.indd 115 14/8/26 3:56 in the afternoon

បាបរបស់យើង ហើយរំឭកយើងពីការអត់ទោសដល់អ្នកដទៃ។ ព្រះគម្ពីរធ្វើឲ្យយើងរបួស ហើយក៏ព្យាបាលយើងឡើងវិញ។ ព្រះគម្ពីរលាតត្រដាងពីយើង ហើយក៏គ្របបាំងយើងវិញដែរ។ ចំណេះដឹងរបស់យើងអំពីព្រះជាម្ចាស់មានការកើនឡើង។ សេចក្តីស្រឡាញ់របស់យើងចំពោះព្រះជាម្ចាស់កាន់តែស៊ីជម្រៅឡើង។ ការស្តាប់បង្គាប់របស់យើងចំពោះព្រះជាម្ចាស់កាន់តែខ្ជាប់ខ្ជួន តាមរយៈព្រះបន្ទូលផងដែរ។ ព្រះជាម្ចាស់បានស្តារសិទ្ធិអំណាចកំពូលរបស់ទ្រង់លើជីវិតរបស់យើងឡើងវិញ តាមរយៈព្រះបន្ទូលទ្រង់។

ការទាំងអស់នេះមានសារៈសំខាន់នៅពេលដែលយើងគិតអំពីរបៀបយើងរស់នៅ ដែលឆ្លើយតបទៅនឹងគោលលទ្ធិនៃសិទ្ធិអំណាចកំពូលរបស់ព្រះគម្ពីរ។ តើអ្វីជាការឆ្លើយតបរបស់យើង? ដំបូង យើងគួរស្តាប់បង្គាប់តាមព្រះគម្ពីរគ្រប់ពេលវេលា និងគ្រប់កាលៈទេសៈដោយគ្មានការដោះសារ ឬការសម្របសម្រួលឡើយ។ យើងត្រូវប្តេជ្ញាចិត្តនៅចំពោះព្រះជាម្ចាស់ នោះយើងក៏ត្រូវប្តេជ្ញាក្នុងការរក្សាព្រះបន្ទូលទ្រង់ដែរ ព្រោះព្រះគម្ពីរគឺជាសិទ្ធិអំណាចកំពូលរបស់យើង។

ប៉ុន្តែ នៅពេលដែលយើងព្យាយាមធ្វើតាមព្រះបន្ទូល នោះព្រះជាម្ចាស់នឹងផ្លាស់ប្រែចិត្តយើងតាមរយៈ



Scripture is supreme INDD interior - Khmer 1.9.indd 116 14/8/26 3:56 in the afternoon

ព្រះបន្ទូលទ្រង់។ សិទ្ធិអំណាចកំពូលនៃព្រះគម្ពីរដំណើរការតាមវិធីពីរយ៉ាង៖

- យើងស្ដាប់បង្គាប់តាមព្រះបន្ទូលដែលយើងឮ។
- ព្រះបន្ទូលដែលយើងឮបានចាប់យកចិត្ត និងធ្វើឲ្យយើងលង់ចិត្ត។

សៀវភៅសព្វវចនាធិប្បាយ និងសៀវភៅក្បួនច្បាប់មួយចំនួន គឺមានអត្ថប្រយោជន៍ណាស់។ បើលោកអ្នកចង់ដឹងអំពីអ្វីមួយ នោះលោកអ្នកអាចពិនិត្យមើលនៅក្នុងសៀវភៅសព្វវចនាធិប្បាយ។ បើលោកអ្នកចង់ដឹងពីច្បាប់កីឡា នោះលោកអ្នកអាចមើលក្នុងសៀវភៅច្បាប់ស្ដីពីកីឡាបាន។ ប៉ុន្ដែ មនុស្សមិនអានសៀវភៅសព្វវចនាធិប្បាយ ឬសៀវភៅច្បាប់សម្រាប់ការកម្សាន្តនោះទេ។ លោកអ្នកមិនអានមួយថ្ងៃមួយជំពូកនោះទេ។ មនុស្សភាគច្រើនមិនធ្វើបែបនេះឡើយ។ បើព្រះគម្ពីរគ្រាន់តែជាសៀវភៅសព្វវចនាធិប្បាយខាងផ្នែកសាសនា ឬសៀវភៅច្បាប់ នោះជាការមានប្រយោជន៍ដែលមានព្រះគម្ពីរមួយក្បាលនៅលើធ្នើរដាក់សៀវភៅរបស់លោកអ្នក។ ពេលខ្លះ លោកអ្នកអាចគ្រាន់តែយកវាចុះមកអាន ហើយរកមើលព័ត៌មានមួយចំនួន។ ប៉ុន្ដែ



Scripture is supreme INDD interior - Khmer 1.9.indd 117 14/8/26 3:56 in the afternoon

ទាក់ទងទៅនឹងព្រះគម្ពីរលោកអ្នកនឹងមិនអាចអាន ឬក៏ស្តាប់ការពន្យល់ព្រះគម្ពីរដូចដែលលោកអ្នកអានសៀវភៅសព្វវចនាធិប្បាយ ឬក៏សៀវភៅច្បាប់នោះទេ ដែលនេះមានន័យថា លោកអ្នកអានព្រះគម្ពីរដោយមានការយកចិត្តទុកដាក់។

ប៉ុន្តែ ពិតណាស់ សិទ្ធិអំណាចកំពូលនៃព្រះគម្ពីរគឺប្រៀបដូចជាសកម្មភាពមួយ។ ព្រះជាម្ចាស់កំពុងតែនាំយើងចូលទៅក្នុងទំនាក់ទំនងជាមួយនឹងទ្រង់យ៉ាងសកម្ម ហើយទ្រង់កំពុងតែកសាងរាជ្យទ្រង់លើជីវិតរបស់យើងឡើងវិញតាមរយៈព្រះបន្ទូលទ្រង់។ ព្រះអង្គមិនធ្វើកិច្ចការនេះ ដោយគ្រាន់តែស្រែកប្រកាសពីក្រឹត្យវិន័យទ្រង់នោះទេ។ ពិតមែន ព្រះគម្ពីរបង្ហាញយើងឲ្យឃើញពីបំណងព្រះទ័យរបស់ព្រះជាម្ចាស់មែន ប៉ុន្តែព្រះអង្គមានបន្ទូលតាមរយៈព្រះគម្ពីរ ដើម្បីហៅយើងឲ្យមកជិត ហើយយកឈ្នះលើដួងចិត្តរបស់យើង។ ព្រះគម្ពីរគឺជាសំបុត្រនៃសេចក្តីស្រឡាញ់ពីព្រះគ្រីស្ទមកកាន់កូនក្រមុំរបស់ទ្រង់ ពោលគឺជាសំបុត្រដើម្បីបញ្ជាក់ប្រាប់សារជាថ្មីនូវសេចក្តីស្រឡាញ់របស់ទ្រង់ដល់យើង និងដើម្បីទទួលបានសេចក្តីស្រឡាញ់ពីយើងវិញ។ ព្រះជាម្ចាស់ក្លាយជាសិទ្ធិអំណាចកំពូលនៅក្នុងចិត្តយើង មិនមែនដោយការបង្ខិតបង្ខំឲ្យយើងចុះចូលនោះទេ



Scripture is supreme INDD interior - Khmer 1.9.indd 118 14/8/26 3:56 in the afternoon

ប៉ុន្តែដោយការផ្លាស់ប្តូរបំណាងចិត្តយើងក្នុងលក្ខណៈ ដែលស្រទន់ និងដោយការបំពេញនូវសេចក្តីស្រឡាញ់ ដល់យើងវិញ។ ហេតុនេះ យើងត្រូវអានព្រះគម្ពីរជា រៀងរាល់ថ្ងៃ៖ ដើម្បីបានឮព្រះទ្រង់មានបន្ទូលដោយ សេចក្តីស្រឡាញ់មកកាន់យើង នោះយើងមានកម្លាំង នឹងបម្រើទ្រង់។

សិទ្ធិអំណាចកំពូលនៃព្រះគម្ពីរ ពាក់ព័ន្ធនឹងការ បង្កើតសិទ្ធិអំណាចកំពូលរបស់ទ្រង់លើជីវិតយើង តាម រយៈព្រះគម្ពីរ។ សូមឲ្យបទពិសោធន៍ទាំងនេះបានជា របស់លោកអ្នក ហើយនិងខ្ញុំខណៈដែលយើងចូលទៅ កាន់ព្រះបន្ទូលព្រះជាម្ចាស់ ដោយការបន្ទាបខ្លួនចុះចូល រហូតដល់ថ្ងៃដែលយើងនឹងជួបព្រះអម្ចាស់ ដែលជាអ្នក និពន្ធព្រះគម្ពីរមុខទល់នឹងមុខ។



Scripture is supreme INDD interior - Khmer 1.9.indd 119 14/8/26 3:56 in the afternoon

## ការឆ្លុះបញ្ចាំង ឬការពិភាក្សា

១) តើនៅក្នុងអត្ថន័យណាដែលសិទ្ធិអំណាចកំពូលនៃព្រះគម្ពីរជាកិរិយាសព្ទ (ពាក្យ «បង្ហាញពីអំពើ») ហើយមិនមែនជានាម?

២) «រាល់ពេលដែលយើងអាន ឬអធិប្បាយចេញពីព្រះគម្ពីរ នោះយើងប្រកាសថា ព្រះជាម្ចាស់កំពុងតែមានបន្ទូលហើយ»។ តើការនេះណែនាំ (ឬផ្លាស់ប្ដូរ) អាទិភាពរបស់លោកអ្នក ឬគ្រួសាររបស់លោកអ្នកយ៉ាងដូចម្ដេចខ្លះ?

៣) «ព្រះជាម្ចាស់តែងតែធ្វើការតាមរយៈព្រះបន្ទូលទ្រង់»។ នៅក្នុងពិភពលោកដែលពោរពេញទៅដោយ «ភាពរឹករវរ» នៃប្រព័ន្ធផ្សព្វផ្សាយសង្គម តើលោកអ្នកមានអារម្មណ៍ថា សេចក្ដីពិតនេះនាំមកនូវស្ថិរភាព និងការកម្សាន្តចិត្តយ៉ាងដូចម្ដេចខ្លះ? តើផ្នែកណាខ្លះនៃព្រះគម្ពីរដែលលោកអ្នកឧស្សាហ៍លើកយកមកសម្រាប់ជាការកម្សាន្តចិត្ត និងការដឹកនាំ?

៤) តើលោកអ្នកអាចគិតដល់វេលាមួយ ដែលព្រះជាម្ចាស់បានជំទាស់នឹងសកម្មភាពរបស់លោកអ្នកតាមរយៈព្រះបន្ទូលទ្រង់ដែរឬទេ? តើឥរិយាបថរបស់លោកអ្នកជាចំណុចមួយដែលចុះចូលជាមួយនឹងការបង្រៀនរបស់ព្រះគម្ពីរដែរឬទេ? ហេតុអ្វី?



Scripture is supreme INDD interior - Khmer 1.9.indd 120 14/8/26 3:56 in the afternoon

# លិបិក្រមតាមព្រះគម្ពីរ

## សញ្ញាចាស់


### លោកុប្បត្តិ

១:២ . . . . . . . . . . . . . . . ១០៧, ១១២
១:៣ . . . . . . . . . . . . . . . ១០៨
១:៤-៥ . . . . . . . . . . . ១០៨

### ទំនុកតម្កើង

១៩:៦ . . . . . . . . . . . . . . ៧៨
១៩:១-២ . . . . . . . . . . ១១១
២៩:១-១១ . . . . . . . . . ១១០-១១១
២៩:៣ . . . . . . . . . . . . . ១១១
២៩:៤ . . . . . . . . . . . . . . ១១១
២៩:៥ . . . . . . . . . . . . . . ១១២
២៩:៩ . . . . . . . . . . . . . . ១១២
២៩:៦ . . . . . . . . . . . . . . ១១២
២៩:៨ . . . . . . . . . . . . . . ១១២
២៩:៩ . . . . . . . . . . . . . . ១១២
២៩:១០ . . . . . . . . . . . . ១១២
២៩:១១ . . . . . . . . . . . . ១១៣

### សុភាសិត

២៩:២៥ . . . . . . . . . . . . ៦៧

### សាស្តា

៤:១២ . . . . . . . . . . . . . ៣៧


## សញ្ញាថ្មី


### ម៉ាថាយ

៧:២៤-២៧ . . . . . . . . ១០០
១៤:១៣-២១ . . . . . . ៨៨
១៤:២២-៣៣ . . . . . ៣៥
២៥:២៣ . . . . . . . . . . . ៦៣
២៨:១៨ . . . . . . . . . . . . ៤២

### ម៉ាកុស

៤:៣៩ . . . . . . . . . . . . . ១១២
៦:៣២-៤៤ . . . . . . . . ៨៨

### លូកា

៩:១០-១៧ . . . . . . . . . ៨៨


Scripture is supreme INDD interior - Khmer 1.9.indd 121 14/8/26 3:56 in the afternoon

### យ៉ូហាន

១:១ ...............៣២, ៣២
១:១៤...............៣៣
៣:៣-៦...........៣៤
៦:១-១៣..........៨៨
១០:១១...........១០១
១៤:២៥-២៦.......៤៤
១៧:១៧ ..........១១៣

### កិច្ចការ

៥:២៩..............៦៤

### រ៉ូម

១:១-៤ ...........៨, ១៩
១:១៨..............៣៣
៥:៨ ...............៥២

### ១កូរិនថូស

១២:៤-១១.........៦០

### ២កូរិនថូស

៤:៥-៦ ...........១០៩
៤:៦ ...............៣៤

### អេភេសូរ

២:២០ .............៨៤

### កូឡុស

១:១៦..............៦៨
១:១៨..............៤៣

### ១ធីម៉ូថេ

១:១១..............១០
៣:១៥..............៨៦

### ២ធីម៉ូថេ

៣:១៦.............២៩, ៣៦, ៤២

### ទីតុស

៣:៥-៦............៣៤

### ហេព្រើរ

១:៣...............៣២
៣:៧-១១..........១០៦
៤:១២ .............១០៧

### ២ពេត្រុស

១:៣-៤............៥៧, ៦៥
១:២១ .............៣៧

### ១យ៉ូហាន

១:១ ...............៣២


Scripture is supreme INDD interior - Khmer 1.9.indd 122 14/8/26 3:56 in the afternoon

Scripture is supreme INDD interior - Khmer 1.9.indd 123 14/8/26 3:56 in the afternoon